00812206



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 01-Jun-2012, 08:18
CMS/CFO: Sann Rada

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី ជំនុំជម្រះក្តីនៅដំណាក់កាលដំបូង

## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២**

**ម៉ោង ០៩:០០ នាទី**

**សវនាការលើកទី៦៦**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន

ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*

ចៅក្រម យ៉ា សុខន

ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*

ចៅក្រម យូរ ឧត្តរា

ចៅក្រម ធូ មណី (បម្រុង)

ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោកស្រី សែ កុលវុឌ្ឍី

លោក ឌុច ផារី

លោក ម៉ាតេអូ គ្រីប៉ា
*(Mr.Matteo CRIPPA)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វ៉េង ហ៊ត់

លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល
*(Mr. Vincent de wilde d'ESTMAEL)*

លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*

លោក ឌេល លីសាក់ (*Mr. Dale LYSAK*)

**ជនជាប់ចោទ៖**

លោក នួន ជា

លោក ខៀវ សំផន

លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ម៉ៃខល ផេសមិន

*(Mr. Michiel PESTMAN)*

លោក ហ្សាស្ពើ ប៉ៅ*(Mr Jasper PAUW)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោក សំ សុគង់

លោក ឡោ ជុនធី

លោក ហុង គឹមសួន

លោក វ៉េន ពៅ

លោកស្រី ទី ស្រ៊ីនណា

លោកស្រី ស៊ីន សុវ៉ន

លោកស្រី ឡូរ៍ ដេសហ្វកស៍

*(Ms.Laure DESFORGES)*

លោក បាណាបេ ណេគ្វី

*(Mr. Barnabé NEKUIE)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

**បញ្ជីឈ្មោះអ្នកនិយាយ៖**

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែន៍ | បារាំង |
| លោក វ៉េង ហ៊ត់ | ខ្មែរ |
| លោក វាំងសង់ វ៉ាយដ៍ ដេស្មាឯល | បារាំង |
| លោក សុន អរុណ | ខ្មែរ |
| លោក ម៉ៃខល ផេសមិន | អង់គ្លេស |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោកស្រី អង់តា ហ្គីសសេ | បារាំង |
| លោក នី កន (TCW-487) | ខ្មែរ |
| លោក សគឹម ល្មុត (TCW-583) | ខ្មែរ |

# ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី÷ លោក នី កន** (TCW-487)

សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៍ ផ្ដើមពី៖ ..... ទំព័រ ៣

សួរដោយ លោក សុន អរុណ ផ្ដើមពី៖ ..... ទំព័រ ៥

សួរដោយ លោក ម៉ៃខល ផេសមិន ផ្ដើមពី៖ ..... ទំព័រ ១៩

សួរដោយ លោក អាង ឧត្ដម ផ្ដើមពី៖ ..... ទំព័រ ៣៥

សួរដោយ លោក គង់ សំអុន ផ្ដើមពី៖ ..... ទំព័រ ៤៦

សួរដោយ កញ្ញា អង់តា ហ្គីសសេ ផ្ដើមពី៖ ..... ទំព័រ ៥៣

**ការសួរសំណួរទៅសាក្សី÷ លោក សគីម លម្នុត** (TCW-583)

សួរដោយប្រធានអង្គជំនុំ ផ្ដើមពី៖ ..... ទំព័រ ៦៤

សួរដោយ លោក វ៉េង ហ៊ត់ ផ្ដើមពី៖ ..... ទំព័រ ៦៧

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០០:២៤]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ កិច្ចដំណើរការសវនាការនៅថ្ងៃនេះ គឺបន្តស្តាប់សក្ខីកម្មសាក្សីឈ្មោះ នី កន ដែលពីម្សិលមិញអង្គជំនុំជម្រះបានជម្រាបជូនភាគី និង សាធារណជនថានឹង-- ព្រឹកនេះនឹងចាប់ផ្តើមដោយក្រុមមេធាវីការពារក្តី ដែលនឹងអាចចាប់ផ្តើមដោយ មេធាវីការពារក្តី នួន ជា មុនក្រុមមេធាវីការពារក្តីឯទៀត ប៉ុន្តែទំនងជាអង្គជំនុំជម្រះ ចៅក្រមនៃអង្គជំនុំ ជម្រះអាចមានសំណួរមួយចំនួន។ ដូច្នេះអង្គជំនុំជម្រះនឹងផ្តល់វេទិកាទៅចៅក្រមនៃអង្គជំនុំជម្រះដើម្បី មានឱកាសក្នុងការតាំងសំណួរមួយចំនួនចំពោះសាក្សីរូបនេះ។

លោក ឌុច ផារី តើស្ថានភាពលោក អៀង សារី យ៉ាងម៉េចដែរ ហើយនៅថ្ងៃនេះ?

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន ជនជាប់ចោទ អៀង សារី មានវត្តមាននៅបន្ទប់ឃុំខ្លួននៅខាងក្រោម បន្ទប់សាលសវនាការ។ លោក អៀង សារី បានលះបង់សិទ្ធិមានវត្តមាននៅចំពោះមុខអង្គជំនុំជម្រះ។ ហើយលិខិតលះបង់សិទ្ធិរបស់គាត់បានប្រគល់ដល់ក្រឡាបញ្ជីរួចហើយ។ សូមអរគុណលោកប្រធាន។

[០៩:០២:១៨]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អង្គជំនុំជម្រះបានទទួលពាក្យសុំរបស់ជនជាប់ចោទ អៀង សារី នៅថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០១២ សុំលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ដោយសុំតាម ដានកិច្ចដំណើរការសវនាការពីចម្ងាយតាមរយៈប្រព័ន្ធសោតទស្សន៍ពីបន្ទប់ឃុំខ្លួនមួយ ក្រោមបន្ទប់ សវនាការនេះសម្រាប់រយៈពេលពេញមួយថ្ងៃនេះ ដោយមូលហេតុបញ្ហាសុខភាពមិនអាចអង្គុយតាម ដានកិច្ចដំណើរការសវនាការដោយផ្ទាល់បាន។

អង្គជំនុំជម្រះយល់ឃើញថា នៅពេលនេះជនជាប់ចោទ អៀង សារី លះបង់សិទ្ធិមានវត្តមានក្នុង បន្ទប់សវនាការដោយផ្ទាល់ តែគាត់អាចតាមដានកិច្ចដំណើរការសវនាការពីបន្ទប់មួយស្ថិតនៅក្រោម

បន្ទប់សវនាការនេះតាមរយៈឧបករណ៍សោតទស្សន៍ និងអាចសម្រួលទំនាក់ទំនងជាមួយនឹងក្រុមមេធាវីការពារក្តីរបស់គាត់បាន។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ អៀង សារី ដែលបានស្នើសុំលះបង់សិទ្ធិចូលរួមក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ឲ្យគាត់នៅតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះត្រឹម តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលសវនាការពេញមួយថ្ងៃនេះ។

បង្គាប់ឲ្យបុគ្គលិកផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់ចោទ អៀង សារី អាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយពេញមួយថ្ងៃនេះ។

[០៩:០៣:៥០]

តទៅនេះគឺនីតិវិធីនៃការបន្តការពិភាក្សាដេញដោលចំពោះសាក្សី ហើយអង្គជំនុំជម្រះសូមសួរទៅចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូង ថាតើអស់លោក លោកស្រីមានសំណួរត្រូវសួរដល់សាក្សីរូបនេះដែរឬទេ? ប្រសិនមានសូមអញ្ជើញបាទ!

សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ឡាវែន!

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

សូមអរគុណលោកប្រធាន។ មុននឹងសួរសំណួរបន្ថែមមួយចំនួនទៅកាន់សាក្សីរូបនេះ ខ្ញុំចង់ផ្តល់ការបំភ្លឺមួយចំនួន ពាក់ព័ន្ធទៅនឹងឯកសារដែលត្រូវបានប្រើប្រាស់កាលពីម្សិលមិញនេះដោយសហព្រះរាជអាជ្ញា ដើម្បីចោទសួរសំណួរទៅកាន់សាក្សី។ ឯកសារនោះគឺជាទូរលេខ 306 និង 307 ដែលមានលេខ D252.12 ហើយនិងតេឡេ-- ទូរលេខ 71 ដែលមានលេខ D252.13។ ទូរលេខនេះរាយការណ៍អំពីដំណើរការនៃទស្សនកិច្ចរបស់គណៈប្រតិភូយូហ្គោស្លាវីនៅកម្ពុជាប្រជាធិបតេយ្យ។ ទូរលេខនេះ ត្រូវបានចុះហត្ថលេខាដោយឈ្មោះ កន។ ដូច្នេះ ខ្ញុំចង់គូរបញ្ជាក់ថា នេះគឺជាអត្ថបទចម្លងនៃទូរលេខដែលយើងទើបបានទទួល។ យើងមានកាលបរិច្ឆេទទទួលឯកសារនេះ។ ទូរលេខ 306 និង 307 ត្រូវបានទទួលនៅថ្ងៃទី១២ និងថ្ងៃទី១៥ ខែមីនា ឆ្នាំ៧៨ ហើយទូរលេខ 71 ត្រូវបានទទួលនៅថ្ងៃទី១៥ ខែមីនា ឆ្នាំ១៩៧៨។ ហើយទូរលេខនេះ គឺមានដាក់បញ្ជីឈ្មោះអ្នកដែលត្រូវទទួលឯកសារនេះ ហើយក្នុងចំណោមបញ្ជីឈ្មោះនេះ គឺមានឈ្មោះ អ៊ំ ហើយមាន អ៊ំនួន, បងវ៉ាន់, បងវន ហើយមានចម្លងជូនមន្ទីរ និងឯកសារផងដែរ។ នេះជាការបញ្ជាក់បំភ្លឺបន្ថែមដល់សាធារណជន និងភាគីទាំងអស់ ហើយជាពិសេស គឺសម្រាប់ខាងសហព្រះរាជអាជ្ញាផងដែរ។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែរ៍៖**

**ស៖** លោកសាក្សី ខ្ញុំចង់សួរសំណួរមួយចំនួន ដែលជាសំណួរខ្លីៗទេ។ សំណួរដំបូងនោះ គឺពាក់ព័ន្ធនឹងតួនាទី របស់លោក ខៀវ សំផន។

[០៩:០៦:៤០]

ក្នុងអំឡុងពេលលោកបំពេញការងារនៅក្រសួងការបរទេស តើលោកធ្លាប់មាន-- លោកធ្លាប់បានទំនាក់ទំនងជាមួយលោក ខៀវ សំផន ដែរឬទេ? ហើយបើទំនាក់ទំនង តើក្នុងកាលៈទេសៈបែបណា?

**លោក នី កន៖**

**ឆ៖** សូមគោរពលោកប្រធាន និងអង្គសវនាការទាំងមូល។ ចំពោះសំណួរអម្បាញ់មិញនេះ ខ្ញុំសូមបញ្ជាក់ជូន គឺខ្ញុំនៅក្នុងក្របខ័ណ្ឌក្រសួងការបរទេស ហើយរចនាសម្ព័ន្ធនៃក្រសួងការបរទេស វាមានលំដាប់វាដូចបានជម្រាបម្សិលមិញបន្តបន្ទាប់មកហើយ គឺវាត្រូវឆ្លងតាមថ្នាក់ ហ្នឹងទីមួយ។ ហើយទីពីរ គឺអ្នកគ្រប់គ្រងក្រសួង គឺមានតា អៀង សារី។ ដូច្នោះ ខ្ញុំមិនអាច ឬមានការប្រាស្រ័យទាក់ទងអីជាមួយលោក ខៀវ សំផន ទេបាទ។ សូមអស់។

**ស៖** លោក នី កន លោកបានបញ្ជាក់ថា លោកជាអ្នកទទួលបន្ទុកខាងពិធីការ ហើយក្នុងឋានៈនេះ គឺលោកត្រូវទទួលគណៈប្រតិភូបរទេស។ តើក្នុងចំណោមគណៈប្រតិភូបរទេសនោះ មានអ្នកណាទៅជួបលោក ខៀវ សំផន ទេ? ហើយនៅពេលដែលគណៈប្រតិភូទៅជួបនោះ តើលោកមានទំនាក់ទំនងជាមួយនឹងលោក ខៀវ សំផន ដែរទេ?

**ឆ៖** សូមបញ្ជាក់ជូន គឺភ្ញៀវបរទេសភាគច្រើន ដែលខ្ញុំបានទទួល គឺជាភ្ញៀវបរទេសថ្នាក់ទាប ឬថ្នាក់កាសែតអីម្តងម្កាល។ ដូច្នេះ បើនិយាយតួនាទីភ្ញៀវបរទេសបែបហ្នឹង គឺមិន-- តាមដែលខ្ញុំចាំ គឺមិនមានការប្រាស្រ័យទាក់ទង ឬទៅជួបលោក ខៀវ សំផន ទេ បាទ។

[០៩:០៩:២៨]

**ស៖** តើលោកមានធ្លាប់បានឃើញលោក ខៀវ សំផន នៅតាមផ្លូវនៅក្រសួងការបរទេសទេ?

**ឆ៖** ជម្រាបបាទ។ ខ្ញុំមិនបានឃើញទេបាទ។

**ស៖** លោក នី កន តើលោកអាចជម្រាបអង្គជំនុំជម្រះបានទេ ថាតើអ្នកណាជាអ្នកទទួលបន្ទុក

ក្រសួងការបរទេស នៅពេលដែលលោក អៀង សារី គាត់ធ្វើដំណើរការចេញក្រៅ តើអ្នកណាជាអ្នកជំនួសមុខងាររបស់ អៀង សារី?

**ឆ៖** សូមជម្រាបជូន ពេលវេលាវាវែងឆ្ងាយ ខ្ញុំចាំមិនអស់។ តែបើតាមលំដាប់នៃរចនាសម្ព័ន្ធនុំងគឺមានតែឈ្មោះ ហុង ដែលទទួលបន្តបាទ។ ហ្នឹងខាងអ្នកទទួលបន្ត ហើយក្រៅពីហ្នឹងខាងមន្ទីរហ្នឹងមានតែលោក ជាម ដដែលបាទ។

**ស៖** នៅពេលដែលលោកនិយាយថាឈ្មោះ ហុង តើជា សួរ ហុង ហៅ សាឡុត បាន ហ្នឹងមែនទេ?

[០៩:១១:១៥]

**ឆ៖** ឈ្មោះដែលខ្ញុំស្គាល់ហ្នឹង គឺឈ្មោះ ហុង ហៅ សួរ ហុង តែ សាឡុត បាន នេះមិនដែលឮទេបាទ។ ព្រោះឈ្មោះវាមានច្រើន ហើយឈ្មោះពេលនុំងគេមិនដែលយកឈ្មោះប្រាកដប្រជាអីយកមកដាក់ទេបាទ។

**ស៖** តើលោកដឹងទេថា គាត់ហ្នឹងគឺជាប្អូនរបស់ ប៉ុល ពត?

**ឆ៖** ប្រវត្តិរូបពេលនុំងសុទ្ធតែជាប្រវត្តិរូបដែលមិនចំហ។ ដូច្នោះខ្ញុំមិនដឹងទេ មិនដឹងច្បាស់ថាសាច់ញាតិអីយ៉ាងម៉េចអត់ដឹងទេបាទ។

**ស៖** លោក នី កន ខ្ញុំចង់និយាយអំពីផ្នែកពាក់ព័ន្ធទៅនឹងជំនាញរបស់លោក គឺខាងឃោសនាអប់រំ លោកមានបទពិសោធន៍ច្រើនខាងផ្នែកឃោសនាអប់រំនេះ។ តើលោកមានស្គាល់ឈ្មោះ យុន យ៉ាត ទេ?

**ឆ៖** ឈ្មោះ យ៉ាត ហ្នឹងគឺជាឈ្មោះ តាមខ្ញុំយល់ៗ តាមខ្ញុំដឹង បើមិនខុសទេគឺមានតែជាប្រពន្ធរបស់លោក សុន សេន បាទ។

[០៩:១៣:១៩]

**ស៖** តើលោកស្រី យុន យ៉ាត នេះគាត់ទទួលបន្ទុកខាងផ្នែកអ្វីដែរ នៅក្នុងកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** របៀបរបបធ្វើការងារពេលនោះ គឺដូចខ្ញុំបញ្ជាក់ជូនអង្គសវនាការ គឺដាច់ដោយឡែកពីគ្នារវាងថ្នាក់ក្រោមថ្នាក់លើ។ ដូច្នេះខ្ញុំរហូតដល់ថ្ងៃនេះ ខ្ញុំមិនច្បាស់ថាគាត់ទទួលនាទីអីច្បាស់លាស់ទេបាទ។

**ស៖** តើលោកទទួលបញ្ជាពីអ្នកណាដែរពាក់ព័ន្ធនឹងខាងឃោសនាអប់រំនេះ?

**ឆ៖** សូមជម្រាបជូន រចនាសម្ព័ន្ធពេលនោះបើតាមខ្ញុំយល់ គឺជារចនាសម្ព័ន្ធ ដោយឡែកៗគ្នា មិនមានខ្សែបណ្ដោយអីច្បាស់លាស់ទេ។ គឺមានតែក្រសួងដែលមានមន្ទីរ ប្រធានមន្ទីរចាត់ចែងឲ្យធ្វើ មិនមែនទៅតាមក្រសួងឃោសនាការអី មករកបុគ្គលខ្ញុំជាអ្នកឃោសនាអី អត់មានទេបាទ។ ដូច្នេះសរុប ដើម្បីឲ្យងាយយល់ គឺខ្ញុំទទួលពីមន្ទីរបាទ។

**ស៖** ខ្ញុំសូមសួរសំណួរចុងក្រោយ។ តើលោកបានដឹងអំពីការស្លាប់របស់បងប្រុសរបស់លោក គឺលោក សុន សេន និងលោកស្រី យុន យ៉ាត ទេ? តើលោកដឹងទេ?

**ឆ៖** ជម្រាបជូន។ ខ្ញុំដឹងតាមការនិយាយតៗគ្នាមកប្រាប់ខ្ញុំ។ តែការស្លាប់នេះ ដោយរឿងអី ហេតុផលអី នរណាជាអ្នកសម្លាប់រហូតថ្ងៃនេះ ខ្ញុំមិនច្បាស់។ ពីព្រោះដើម្បីអង្គសវនាការយល់ គឺពេល ដែលសង្គ្រាមចុងក្រោយជិតចប់នេះ ការប្រាស្រ័យទាក់ទងគ្នាលែងបានហើយ។ ខ្ញុំនៅចុងម្ខាង អាចប្រើ ពាក្យថា ខាងត្បូង ឯបង-- គ្រួសារបងខ្ញុំនៅខាងចុងខាងជើង ហើយនៅក្របខ័ណ្ឌខាងលើ។ ដូច្នេះខ្ញុំអត់ មានដឹងអីទាំងអស់ ស្រាប់តែមានដំណឹងផ្សាយតាមប្រជាជនមកថា ស្លាប់អស់ហើយ។ នេះជារឿង ពិត។ ដូច្នោះ ការប្រាស្រ័យទាក់ទងគ្នាក៏មិនបាន រួចហើយអ្នកដែលនៅជិតអី យកដំណឹងអីមកប្រាប់ ជាក់ស្ដែងក៏មិនមានច្បាស់លាស់ តែដឹងថាស្លាប់ទាំងអស់បាទ។ នេះសូមជម្រាបជូនប៉ុណ្ណឹងបាទ។

[០៩:១៧:២៨]

**ចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

លោកប្រធាន ខ្ញុំមិនមានសំណួរទៀតទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ បាទ ជាកិច្ចបន្តអង្គជំនុំជម្រះសូមផ្ដល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្ដី**

**សួរដោយលោក សុន អរុណ៖**

សូមគោរពអង្គសវនាការ។ សូមគោរពលោកប្រធាន!

**ស៖** សួស្ដីលោក នី កន សាក្សី។ ខ្ញុំឈ្មោះ សុន អរុណ មេធាវីរបស់លោក នួន ជា។ ជាដំបូង ខ្ញុំសូមមានសំណួរមួយចំនួនដើម្បីសួរលោក។ កាលពីម្សិលមិញ ម្សិលម្ង៉ៃ លោកបានឆ្លើយជម្រាបទៅ

ព្រះរាជអាជ្ញា និងខាងដើមបណ្ដឹងរដ្ឋប្បវេណីរួចអស់មួយចំនួនធំហើយ។ លោកបានមានប្រសាសន៍ជម្រាបថា លោកបានចូលបដិវត្តន៍ប្រាកដប្រជានៅឆ្នាំ១៩៧០ ពិតអ៊ីចឹងមែនទេ?

[០៩:១៩:00]

**លោក នី កន៖**

**ឆ៖** បាទ សូមឆ្លើយ។ ការចូលរួមក្នុងចលនាតស៊ូពិតប្រាកដប្រជា ហើយបានប្រឡូកនេះគឺ ឆ្នាំ៧០-- ក្រោយឆ្នាំ៧០បាទ។

**ស៖** អរគុណ--

**ឆ៖** ឆ្នាំ៧០បាទ។

**ស៖** សូមអរគុណ។ ពីមុនឆ្នាំ១៩៧០ លោកបាននិយាយប្រាប់ទៅ អង្គសវនាការថា លោកបានធ្វើការមិនៗចូលប្រឡូកចំតួជា សមាជិករបស់បដិវត្តន៍អីទេ គ្រាន់តែជាឃោសនាតៗខ្សឹបៗគ្នាតាំងពីឆ្នាំ១៩៦៦ រហូតដល់ ១៩៧០។ រយៈពេល-- ខ្ញុំសូមសួរថា រយៈពេលនុ៎ង លោកធ្វើជាគ្រូបង្រៀន លោកមានដែលឮថាពេលនុ៎ងមានជនបរទេសជិតខាង គេចូលមកនៅទឹកដីខ្មែរ ឬក៏ៗមកធ្វើ បង្កើតជាអសន្តិសុខ ឬក៏ធ្វើឱ្យខ្មែរហ្នឹងមានការពុល មានការច្របូលច្របល់ខ្លះ មិនធំដុំទេ តាំងពីឆ្នាំមួយពាន់--ទសវត្សន៍ឆ្នាំ៦០។ ប៉ុន្តែលោកបានចូលធ្វើការជាគ្រូបង្រៀនពេលហ្នឹង ខ្ញុំជឿថាលោកបានមានការចេះដឹងជ្រៅជ្រះ ហើយក៏យល់ច្រើន។ តើមានឮអ៊ីចឹងខ្លះទេ ពីមុនមក?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ។ សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្នាឯល៖**

សូមអរគុណលោកប្រធាន។ ជម្រាបសួរលោក លោកស្រីចៅក្រម។ យើងបានស្ដាប់ឮសំណួរយ៉ាងវែង ដោយមានការបញ្ជាក់អះអាងពីវត្តមានរបស់ជនបរទេសដោយអត់មានការបញ្ជាក់ឱ្យបានច្បាស់ទេ។ សូមឱ្យរៀបចំសំណួរឱ្យបានត្រឹមត្រូវ ឱ្យបានខ្លី ហើយឱ្យបានច្បាស់ថា ចង់សួរពីអី? ពីព្រោះថាសំណួរនេះដូចជាសំណួរនាំមុខអ៊ីចឹង។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅព្រះរាជអាជ្ញា។ ខ្ញុំសួរវែង ឬសួរខ្លី នៅលើសាក្សីអាចឆ្លើយបានឬមិនបាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់សហ-- តំណាងសហព្រះរាជអាជ្ញាគ្មានប្រសិទ្ធភាព។ អង្គជំនុំជម្រះត្រូវការស្តាប់ចម្លើយសាក្សីតបទៅនឹងសំណួររបស់មេធាវីអម្បាញ់មិញនេះ។ សូមសាក្សីឆ្លើយតបទៅនឹងសំណួរនេះ!

**លោក នី កន៖**

**ឆ៖** ខ្ញុំសូមឆ្លើយជូន ហើយចម្លើយរបស់ខ្ញុំនេះ វាអាចត្រូវតាមសំណួរទាំងស្រុង ឬមិនត្រូវ អាហ្នឹងតាមជាក់ស្តែង។ ក្នុងពេលដែលខ្ញុំមានឋានៈជាគ្រូបង្រៀន ហើយការហៅថាចូលរួមការឃោសនាអីចុះឡើង ពេលនុ៎ងមិនទាន់មានដឹងថាមានជនបរទេសអីមកតាំងនៅអីទេ អត់មានដឹងអីប្រាកដប្រជាអីទេ បាទ។

**សួរដោយលោក សុន អរុណ៖**

**ស៖** លុះមកដល់ឆ្នាំ១៩៧០ លោកបានចូលក្នុងបដិវត្តន៍ប្រាកដប្រជាដោយមាន-- ដោយយោងទៅតាម-- លោកមានប្រសាសន៍ពីម្សិល ម្សិលមិញម្សិលម៉្ងៃថា តាមរណសិរ្សអំពាវនាវឲ្យចូលព្រៃម៉ាគី។ ខ្ញុំសូមសួរលោកថា សូមលោកពន្យល់អំពីព្រៃម៉ាគីហ្នឹងជូនតុលាការបាន ឲ្យបានច្បាស់លាស់ជាងប្រើពាក្យមួយម៉ាត់អីចឹងបានទេ តើអ្វីទៅហៅព្រៃម៉ាគី?

[០៩:២៣:៥៦]

**ឆ៖** សូមឆ្លើយ ការបកស្រាយនូវអត្ថន័យព្រៃម៉ាគី ខ្ញុំប្រហែលជាបកស្រាយមិនបានចំទាំងអស់ទេ។ តែបើខ្ញុំចាំនូវគោលគំនិតជារួម គឺថារួបរួមគ្នាទាំងអស់វើចក្រពត្តិ ក្នុងនុ៎ងមានរដ្ឋអំណាច លន់ នល់នៅជាមួយ ដែលធ្វើរដ្ឋប្រហាររំលំព្រះមហាក្សត្រ។ ដូច្នេះ ការយល់ន័យជម្រៅម៉ាគីរបស់ខ្ញុំបានប៉ុណ្ណឹងបាទ។

**ស៖** លោកបាននិយាយថា រណសិរ្សអំពាវនាវឲ្យចូលព្រៃម៉ាគី។ ចុះរណសិរ្សហ្នឹងជានរណា? ជាក្រុមណា? ឬក៏ជាអង្គការអ្វី?

**ឆ៖** រណសិរ្សនេះ ដែលខ្ញុំទទួលការណែនាំបន្តនោះគឺថា អង្កាល់ណោះគេឲ្យឈ្មោះថា “ប្រមុខរដ្ឋ” ហើយក្នុងនុ៎ង តាមខ្ញុំចាំគឺ សម្តេចហៅថា “សម្តេចឪ” មានប៉ុណ្ណឹង។ ឯលម្អិតម៉េចទៀត ខ្ញុំមិនដឹងដែរ ព្រោះទទួលការបន្តមក។

**ស៖** បើដូច្នេះរណសិរ្សអំពាវនាវហ្នឹងឲ្យប្រជាជនទូទៅចូលព្រៃម៉ាគី ដើម្បីរំដោះប្រទេសជាតិ

ពីចក្រពត្តិ បើតាមខ្ញុំចាំលោកមានប្រសាសន៍ពីម្សិល។ ពីឆ្នាំ១៩៧០ ដល់ ១៩៧៥ លោកបានចូលធ្វើការពេញលក្ខណៈនៅក្នុងរណសិរ្ស។ រណសិរ្សនេះបង្កើតដោយបក្សកុម្មុយនីស្តកម្ពុជា ឬក៏បង្កើតដោយសម្តេចឪ?

[០៩:២៧:០៧]

**ឆ៖** សូមឆ្លើយ ខ្ញុំយល់មិនដល់ទេ ពីព្រោះជាការងារក្របខ័ណ្ឌខាងលើហើយបាទ។

**ស៖** ចាប់ពីឆ្នាំ១៩៧០ ដល់ ៧៥ ដដែល លោកបានចូលជាសមាជិកពេញសិទ្ធិនៅក្នុងអ្នកតស៊ូពេលហ្នឹងលោកយល់ថា អ្នកតស៊ូទាំងអស់ដែលហៅរណសិរ្សហ្នឹង គឺជារបស់សម្តេចឪទាំងអស់ ឬក៏មានក្រុមពីរ ក្រុមបី?

**ឆ៖** ខ្ញុំយល់មិនបានល្អិតទេ តែខ្ញុំឃើញនៅក្នុងរណសិរ្សដែលអំពាវនាវហ្នឹងគឺគ្រប់កម្លាំងទាំងអស់ ឬថាគ្រប់ចលនាទាំងអស់រួមគ្នា។ តែឲ្យថាខ្ញុំដៅថា ឈ្មោះអីៗ ខ្ញុំមិនដឹងទេ។ ហើយបញ្ហានេះលោកក៏អាចយល់ថា បញ្ហាលម្អិតក្របខ័ណ្ឌខាងលើអ៊ីចឹង គឺថ្នាក់ក្រោមមិនអាចយល់ទេបាទ។

**ស៖** សូមអរគុណ។ នៅក្នុងឯកសារសួរចម្លើយរបស់ចៅក្រមស៊ើបអង្កេតលេខ D369/16 ត្រង់ចំណុច ឆ.៣៖ សួរលោកថា តើ តាស៊ី ត្រូវបានចាប់ខ្លួននៅពេលណា តាមលោកដឹង? លោកអាចឆ្លើយបានទេ ពេលហ្នឹង?

**ឆ៖** ខ្ញុំសូមឆ្លើយ ខ្ញុំសូមបញ្ជាក់ថា ខ្ញុំនៅតែយកខ្លឹមសារដែលខ្ញុំបានសម្ភាសជាមួយផ្នែកស៊ើបអង្កេតដដែល គឺថាខ្ញុំមកផុតហើយ បានឮដំណឹងថាបានចាប់ខ្លួន ដូច្នេះខ្ញុំមិនបានអីចងចាំថា ថ្ងៃខែណាអីទេបាទ។

[០៩:៣០:០៦]

**ស៖** អរគុណ។ ខ្ញុំសួរបន្ត នៅក្នុងឯកសារដដែលនុ៎ង លោកបានឆ្លើយថានៅក្នុង-- លោកបានឆ្លើយនៅក្នុងឯកសារដដែលនៅបន្ទាត់ទី២។ ក្នុងរយៈពេលប្រហែលបី ឬបួនខែក្រោយ ពីលោកបានចេញពីភូមិភាគបស្ចិមមកធ្វើការនៅក្រសួងការបរទេស ក៏កើតមានរឿងជាច្រើន កើតមានឡើងទាក់ទងនឹងការចាប់មនុស្សនៅភូមិភាគបស្ចិម តែខ្ញុំមិនបានដឹងទេ។ ត្រង់ពាក្យឃ្លាចុងក្រោយបំផុត លោកថាលោកឆ្លើយថា "ក្រសួងការបរទេសក៏កើតមានរឿងជាច្រើន កើតមានឡើងទាក់ទងនឹងការចាប់មនុស្សនៅភូមិភាគបស្ចិម តែខ្ញុំមិនបានដឹងទេ"។ អាហ្នឹងលោកចង់មានន័យថាម៉េច សូមបំភ្លឺឃ្លាហ្នឹង គ្រាន់បំភ្លឺឃ្លាហ្នឹងឲ្យច្បាស់បន្តិចមើល៍?

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែម។ ឃ្លាដែលខ្ញុំថា ក្រោយខ្ញុំចេញផុត មានដំណឹងមកថា មានការដក-- បាត់ខ្លួន ឬក៏ចាប់ខ្លួននៅភូមិភាគបស្ចិម។ ខ្ញុំបានដឹងតាមដំណឹងខាងក្រៅ។ តែឲ្យដឹងថាអ្នកអស់នោះ ទៅណាមកណា ខ្ញុំមិនដឹងទេ។ ឯថាក្នុងក្រសួងការបរទេស ខ្ញុំមិនបាននិយាយទេ។ តាមចាំ ដូចមិនបាននិយាយរឿងថា នៅក្នុងក្រសួងការបរទេសទេ។ តែបើអាចនិយាយ ថាខ្ញុំមក វាអ្នកណាបាត់ទៅណាមកណា ខ្ញុំមិនដឹង ខ្ញុំក៏មិនស្គាល់ផង។ ហើយមកដល់ ខ្ញុំបានទទួលនាទី តែត្រឹម អ្វី!ខាងផ្នែកមន្ទីរចាត់តាំងឲ្យធ្វើពិធីការជូនភ្ញៀវ ហើយនិងសម្អាតផ្ទះ។ ដូចខ្ញុំបានជម្រាបហើយ កុំឲ្យវែង សម្អាតផ្ទះ ជូតលាង ដុសលាងអីហ្នឹង ហើយនិងទទួលភ្ញៀវតាមថ្នាក់ដែលខ្ញុំទទួលបានបាទ។ សូមអស់បាទ។

[០៩:៣២:៤៧]

**ស៖** សំណួរមួយទៀតសួរថា លោកបានឆ្លើយប្រាប់ទៅចៅក្រមស៊ើបអង្កេតថា លោកមានមកធ្វើការនៅក្រសួងការបរទេសហើយ។ យ៉ាងម៉េចបានជាលោកដឹងថា នៅភូមិភាគបស្ចិមកើតរឿងជាច្រើន ទាក់ទងនឹងការចាប់មនុស្សនៅភូមិភាគនោះ តើលោកដឹងដោយសារអ្វី?

**ឆ៖** សូមជម្រាបជូន ដឹងដោយសារតែការនិយាយតៗគ្នាទេ មិនមានអីជាផ្លូវការទេបាទ។

**ស៖** សូមអរគុណ។ នៅក្នុងឯកសារដដែល គឺឯកសារលេខ D369/16 ត្រង់សំណួរលេខ៩ សួរថា តាមទស្សន៍-- តាមទស្សនាវដ្ដីទង់បដិវត្តលេខ៨ ខែសីហា ឆ្នាំ១៩៧៧ តើលោកបានដឹងដែរ បានដឹងរឿងទង់បដិវត្តនៅខែសីហា ឆ្នាំ១៩៧៧ ទេ? ដែលបានឃើញទេ? ហើយបានដឹងទេ?

**ឆ៖** ខ្ញុំបានឆ្លើយ ហើយអាចបញ្ជាក់សាឡើងវិញ ចំទាំងអស់ ឬមិនចំ តែខ្ញុំចាំជាមូលដ្ឋាន គឺទីមួយ ខ្ញុំមិនបានឃើញទេ។ ទីពីរ សូម្បីតែខ្លឹមសារដែលយកមកផ្សព្វផ្សាយ ក៏ជាខ្លឹមសារដកស្រង់ពី ព្រោះពាក្យថា "ទង់បដិវត្ត" នេះជាឯកសាររបស់ផ្ទៃក្នុង។ ហេតុនេះ ខ្ញុំបានបញ្ជាក់ប៉ុណ្ណឹង ថ្ងៃហ្នឹងក៏សូមបញ្ជាក់ជូនប៉ុណ្ណឹងដែរបាទ។

**ស៖** សំណួររបស់ខ្ញុំ គ្រាន់ចង់សួរលោកថា លោកបានឃើញទង់បដិវត្ត សៀវភៅទង់បដិវត្តហ្នឹងទេ? បានអានទេ? ឬក៏គ្រាន់តែឃើញការដកស្រង់ន័យខ្លះៗពីទង់បដិវត្តហ្នឹងយកមកអាន?

**ឆ៖** ឆ្លើយបាទ ពេលនោះ ឯកសារទង់បដិវត្តនោះមិនទាន់ផ្សព្វផ្សាយអីទូទៅទេ។ ដូច្នេះ ខ្ញុំមិនបានឃើញទេ។ បើបានៗតែទទួលខ្លឹមសារដកស្រង់ បាទ។

**ស៖** អរគុណ។ លោកនៅចាំខ្លះទេ អំពីរឿងទង់បដិវត្តដែលថាឃើញអត្ថន័យដកស្រង់ខ្លះៗ។ លោកបានមានបានចាំខ្លះទេ លោកអាចជម្រាបមកអង្គសវនាការបានខ្លះទេ?

**ឆ៖** សូមជម្រាបជូន ខ្លឹមសារជាមូលដ្ឋានដែលខ្ញុំចាំ គឺខ្លឹមសាររើសម្រុកបង្កបង្កើនផល ឧបត្ថម្ភខ្លួន។ នេះជាខ្លឹមសារចម្បង ឬហៅថាមូលដ្ឋានដែលខ្ញុំចាំ ហើយយកទៅប្រតិបត្តិ។ ខ្លឹមសារទីពីរ គឺក្រៅពីជំរុញការរើសម្រុកបង្កបង្កើនផល គឺមានតែជំរុញការដោះស្រាយជីវភាពនៅតាមមូលដ្ឋាន។ នេះដែលខ្លឹមសារសំខាន់ទីពីរ ដែលខ្ញុំចងចាំ។ ហើយក្រៅពីនុំងមានខ្លឹមសាររួមផ្សំ គឺមានការ-- ខ្លឹមសាររួមផ្សំគឺមានការជំរុញការថែទាំសុខភាពប្រជាជន ជំរុញការចងក្រងសាមគ្គីរវាងប្រជាជនចាស់ថ្មី។ នេះដែលចងចាំបានប៉ុណ្ណឹងទេ បាទ។

[០៩:៣៧:៥៤]

**ស៖** សូមអរគុណណាស់ចំពោះចម្លើយរបស់លោកយ៉ាងក្បោះក្បាយនេះ។ តាមចម្លើយរបស់លោកទៅព្រះរាជអាជ្ញាថ្ងៃទី២៨ ឧសភា ឆ្នាំ២០១២ ថារបាយការណ៍របស់លោកទៅភូមិភាគត្រូវធ្វើតាមតំបន់ ហើយបើមានលិខិតស្នាមអ្វីពីភូមិភាគមកលោក គឺតាមតំបន់ដែរ។ រឿងហ្នឹងរចនាសម្ព័ន្ធហ្នឹងរបៀបធ្វើការហ្នឹង បែបបទរដ្ឋបាលហ្នឹងអ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** បាទ សូមជម្រាបជូនថា រចនាសម្ព័ន្ធ របៀបរបបធ្វើការគឺបែបហ្នឹង។ គឺខាងក្រោមឡើងទៅលើត្រូវឡើងតាមថ្នាក់ លំដាប់ថ្នាក់ ហើយពីលើចុះមកក្រោមក៏តាមលំដាប់ថ្នាក់ បាទ។

**ស៖** សូមអរគុណ។ នេះជារចនាសម្ព័ន្ធ និងឋានានុក្រមរបស់បែបបទរដ្ឋបាលនៅពេលនុំងលោកយល់ថា ហើយលោកដឹងទេថា នៅៗតាមតំបន់ក្តី នៅតាមអង្គភាពណាផ្សេងក្តី ធ្វើការរបៀបអ៊ីចឹងទាំងអស់គ្នា ឬក៏ថាធ្វើតាមឯករាជ្យភាពរបស់គេ?

**ឆ៖** បាទ កិច្ចដំណើរការពេលនុំង គឺខ្ញុំឃើញជាមូលដ្ឋានតាមហ្នឹងបាទ។

**ស៖** សូមអរគុណ។ លោកដឹងទេថារយៈពេលពីឆ្នាំ ដែលលោកបានចូលរណសិរ្សគឺឆ្នាំ១៩៧០មកនោះ ទោះបីលោកបានទទួលមុខងារជាអ្នកឃោសនាអប់រំរហូតដល់ឆ្នាំ១៩៧៥ក្តី។ រយៈពេលនោះតើលោកមានបានឃើញមានទ័ពបរទេស និយាយឲ្យចំថាទ័ពវៀតណាម ដែលហៅថា ពីដើមគេហៅថា "វៀតកុង" ចូលមកជួយវាយរបប លន់ នល់ និងអាមេរិកនោះដែរឬទេ?

**ឆ៖** សូមឆ្លើយ ក្របខ័ណ្ឌនិងតួនាទីរបស់ខ្ញុំជាអ្នកឃោសនិក ក៏បានដើរហើរក្របខ័ណ្ឌមូលដ្ឋានដែលទទួលខុសត្រូវ។ ដូច្នោះ ខ្ញុំមិនបានឃើញអីមកចូលរួមជាក់ស្តែងថាជាកងទ័ពវៀតណាម ឬហៅវៀតកុងអី នោះ ខ្ញុំមិនបានឃើញទេបាទ។

**ស៖** សូមអរគុណ។ ចុះដល់ឆ្នាំ១៩៧៥ ពេលរំដោះភ្នំពេញ តើលោកបានឃើញចលនាទ័ព

វៀតណាមយ៉ាងណា? មានបានឃើញទ័ពវៀតណាមធ្វើមកធ្វើចលនា មកធ្វើសកម្មភាពជាមួយនឹងទ័ពខ្មែរក្រហមទេ? ទ័ពរណសិរ្ស និយាយឲ្យចំ។

[០៩:៤២:៥៦]

**ឆ៖** សូមលោកបញ្ជាក់ម្តងទៀតបាទ សំណួរ។

**ស៖** សូមអរគុណណាស់។ ចាប់ពីឆ្នាំ១៩៧៥មក ពេលវ៉ៃចូលនៅថ្ងៃ១៧-- នៅថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ពេលហ្នឹងវ៉ៃរំដោះខាងបក្សកុម្មុយនីស្តកម្ពុជាហ្នឹង វ៉ៃរំដោះយកភ្នំពេញ។ តើពេលវ៉ៃចូលភ្នំពេញហ្នឹងក្តី វ៉ៃចូលទី-- ឥឡូវ លោកនៅភ្នំពេញ លោកនៅឧដុង្គមិនវ៉ៃចូលភ្នំពេញ។ លោកបានចូលមកភ្នំពេញដែរ ពេលនុ៎ង បើតាមលោកនិយាយជម្រាបអង្គសវនាការពីម្សិល ម្សិលមិញ ម្សិលម៉្ងៃ។ លោកមានបានឃើញមានទ័ពបរទេស និយាយឲ្យចំ គឺថាទ័ពយៀកណាម បានវ៉ៃជាមួយគ្នាចូលមកភ្នំពេញទេ? ឬក៏មានតែទ័ពកម្ពុជាប្រជាធិបតេយ្យសុទ្ធសាធ?

**ឆ៖** សូមឆ្លើយ ខ្ញុំនៅមុខសញ្ញាហ្នឹង ហើយខ្ញុំបានចូលផ្ទាល់ទៅដល់ទីក្រុង។ ខ្ញុំមិនឃើញមានកងទ័ពបរទេសទេ។ ឃើញតែកងទ័ព ហៅថាកម្លាំងរណសិរ្សរួបរួមគ្នានេះ វ៉ៃចូលបាទ។

[០៩:៤៤:៤០]

**ស៖** ពេលដែលលោកវ៉ៃចូលក្រុង-- កងទ័ពផ្នែកខាងបស្ចិមហ្នឹង វ៉ៃចូលភ្នំពេញ។ លោកមិនមែនជាកងទ័ពជួរមុខទេ លោកកងទ័ពជួរក្រោយ អ៊ីចឹងណេះ បើខ្ញុំនិយាយមិនខុស។ ហើយលោកវ៉ៃមុខព្រួញតែមួយទេ ចូលភ្នំពេញ។ ចុះមុខព្រួញផ្សេងទៀត លោកមានដែលឮថា មានកងទ័ពបរទេសជួយកម្ពុជាប្រជាធិបតេយ្យទេ?

**ឆ៖** សូមបញ្ជាក់ជូនបន្ថែម គឺថាខ្ញុំដឹងច្បាស់មុខព្រួញមួយ។ តែជាទូទៅ ខ្ញុំយល់តាម ៗដែលខ្ញុំយល់ ហើយខ្ញុំដឹងជារួម ខ្ញុំថាដូចគ្មានកម្លាំងណាទេ មានតែកម្លាំងរណសិរ្សបង្រួបបង្រួមគ្នានេះវ៉ៃសម្រុកចូលបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមដូរសំណួរផ្សេង។ លោកបាន-- លោកតាំងពីលោកចូលរណសិរ្សពេញសិទ្ធិមក លោកបានធ្វើការពេញទំហឹងជាមួយនឹងរណសិរ្ស ហើយលោកមានមុខងារពី៧០ មកដល់៧៥ រហូតដល់ទៅ៧៩ លោកមានមុខងារធំល្មម។ លោកដែលស្គាល់លោក នួន ជា ទេ?

[០៩:៤៦:៥៧]

**ឆ៖** សូមជម្រាប គឺក្នុងឋានៈដឹកនាំខាងលើ យើង--

**អ្នកបកប្រែ៖**

សូមទោសលោកប្រធាន អ្នកបកប្រែស្តាប់អត់ទាន់ សូមលោកប្រធានអនុញ្ញាត សូមអនុញ្ញាតឲ្យលោកមេធាវីមេត្តាសួរឡើងវិញ។ សូមអត់ទោស។

**ប្រធានអង្គជំនុំ៖**

កុំៗអាលទាន់ឆ្លើយ! សូមលោកមេធាវីតាំងសំណួរចុងក្រោយអម្បាញ់មិញនេះសាជាថ្មីម្តងទៀត ព្រោះអ្នកបកប្រែស្តាប់មិនទាន់ មិនអាចបកប្រែបាន។

**លោក សុន អរុណ៖**

អរគុណលោកប្រធាន។

[០៩:៤៧:៣២]

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមតាំងសំណួរសាឡើងវិញ។ លោកបានចូលទៅជាសមាជិកពេញសិទ្ធិតាំងពីឆ្នាំ១៩៧០ រហូតដល់៧៥ រហូតដល់ឆ្នាំ១៩៧៩ ពេលដែលទ័ពវៀតណាមចូល វ៉ៃចូលក្រុងភ្នំពេញ។ លោកបានធ្វើការមុខងាររបស់លោក ខ្មែរយើងហៅថាអាចថា "ដុំកំភួន" ឬក៏អាចល្មមនឹងដឹង នឹងស្គាល់អស់លោកធំៗខ្លះៗ។ តើលោកស្គាល់លោក នួន ជា ទេ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ក្នុងឋានៈលោក នួន ជា ជាថ្នាក់ដឹកនាំខាងលើ ខ្ញុំអ្នកខាងក្រោមស្គាល់។ សូមជម្រាបជូនបាទ។

[០៩:៤៩:០៤]

**ស៖** បើលោកបានស្គាល់លោក នួន ជា លោកស្គាល់បានជិតដិតទេ? ឬគ្រាន់តែដឹងថាលោកហ្នឹង នួន ជា លោកមានមុខងារលោកធំ ហើយលោក នួន ជា ពេលដែលលោកបានឃើញ បានដឹង បានស្គាល់នុ៎ង តើលោកមានមុខងារជាអ្វីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា?

**ឆ៖** ខ្ញុំសូមឲ្យលោកលើកសំណួរនេះម្តងទៀត ពីព្រោះខ្ញុំស្តាប់ទៅវាមិនទាន់យល់អស់បាទ។

**ស៖** សូម-- លោកប្រធានសូមអត់ទោស។ សូមសួរសាជាថ្មី តាំងពីលោកចូលជាសមាជិកពេញសិទ្ធិនៅក្នុងរណសិរ្សពីឆ្នាំ១៩៧០ រហូតមកដល់៧៥ រហូតមកដល់ឆ្នាំ១៩៧៩ ពេលដែលទ័ពវៀតណាមវ៉ៃចូលភ្នំពេញហើយ លោកមានមុខងារធំល្មមអាចស្គាល់អ្នកធំ អ្នកតូចច្រើន តើលោកស្គាល់

លោក នួន ជា ច្បាស់លាស់ទេ?

**ឆ៖** ខ្ញុំបាន--

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយទេ! សំណួរនេះ សំណួរច្រំដែល សំណួរនេះសួររួចហើយ។ សំណួរចុងក្រោយលោកដែលមិនទាន់បានមានបញ្ហានោះ គឺសំណួរចុងក្រោយទេ សំណួរនេះគាត់បានឆ្លើយរួចហើយ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធានបានរំឭក។

[០៩:៥១:១៨]

**សួរដោយលោក សុន អរុណ៖**

**ស៖** លោកៗមានប្រសាសន៍ថា លោកបានស្គាល់លោក នួន ជា ក្នុងឋានៈជាមេកោយ តើលោកដឹងថា លោក នួន ជា ហ្នឹងមានមុខងារធ្វើអ្វីនៅក្នុងបក្សកុម្មុយនីស្តកម្ពុជាទេ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ។ ចម្លើយនេះដដែល គឺការងារខាងលើ ឬរចនាសម្ព័ន្ធខាងលើ ខ្ញុំមិនដឹងទេបាទ។

**ស៖** បើតាមខ្ញុំដឹងថា លោក នួន ជា គាត់មានមុខងារជាប្រធានរដ្ឋសភា នៃកម្ពុជាប្រជាធិបតេយ្យទទួលបន្ទុកអប់រំ និងឃោសនា។ ពាក្យថា អប់រំ និងឃោសនា មានន័យថា នៅខ្សែបណ្តោយរបស់ខាងលោកហ្នឹងណា លោកមិនអប់រំ និងឃោសនាដូចលោក នួន ជា។ ខ្ញុំសូមសួរថា ពេលដែលលោក នួន ជា គាត់ទៅឃោសនានៅតាមតំបន់ នៅតាមភូមិភាគក្តី ឧបមាថា លោកទៅឃោសនានៅភូមិភាគបស្ចិម លោកដែលបានចូលរួមក្នុងការឃោសនា និងអប់រំរបស់លោក នួន ជា ទេ?

[០៩:៥៣:១៦]

**ឆ៖** សូមឆ្លើយតាមការចងចាំ និងតាមការឃើញ។ ទីមួយ រចនាសម្ព័ន្ធ ដែលលោកបានសួរខ្ញុំអម្បាញ់មិញនេះ វាជារូបភាពវាមាន តែជាខ្លឹមសារនៃការប្រតិបត្តិ វាមិនបានដំណើរការទេ ពីព្រោះខ្ញុំសូមឆ្លើយតាមយល់ សភាពការណ៍ពេលនោះវាខ្លីណាស់ រៀបចំភ្លាមៗទីមួយ ទីពីរសង្គ្រាមចប់ភ្លាមសង្គ្រាមមួយបន្តមកទៀត។ ការធ្វើការ ការប្រាស្រ័យទាក់ទងវាគ្មានយកអីជាមូលដ្ឋានបានទេលោក។ ហ្នឹងទីមួយ សូមឆ្លើយអ៊ីចឹង។ ទីពីរ ការដែលខ្ញុំបានបញ្ជាក់បន្តបន្ទាប់ពីម្សិលម៉្ងៃ ថ្ងៃម្សិលមិញ នៅពេល

នេះជាន់គ្នាដដែល គឺខ្ញុំបានចូលរួមស្តាប់ការអប់រំ ឬហៅថា ការឧទ្ទេសនាម ក្នុងអង្គប្រជុំបើកទូលាយ ហើយក៏មិនបានច្រើនដងទេ ពីព្រោះកិច្ចការខាងលើមិនងាយបានចុះទៅមូលដ្ឋានបាទ។ សូមឆ្លើយប៉ុណ្ណឹងបាទ។

[០៩:៥៥:០៥]

**ស៖** សូមអរគុណសាជាថ្មី។ ចម្លើយរបស់លោកឆ្លើយថា លោកបានទៅចូលរួមនៅអង្គសវនាការ ឬក៏ប្រជុំរួមជាម្តងម្កាល លោកបានឃើញលោក នួន ជា ទោះបីស្គាល់ជិតដិត ឬមិនជិតដិតក៏ដោយ លោកអាចមាននិយាយបានថា តើលោក នួន ជា ហ្នឹងគាត់ជាមនុស្សដែលមានលក្ខណៈជាអ្នកដឹកនាំ ដែលជាគំរូល្អសម្រាប់ប្រជាពលរដ្ឋ ឬក៏គាត់គឺជាមនុស្សដែលមានសន្តានចិត្តឃោរឃៅ អាចថាចោទថាគាត់ហ្នឹងយកមនុស្សទៅដាក់ទោសទណ្ឌទៅសួរចម្លើយស្អី បញ្ជូនមនុស្សទៅដាក់ទោសទណ្ឌសួរចម្លើយ? ឬក៏គាត់គឺជាមនុស្សដែលមានចរិតៗជារបៀបអ្នកដឹកនាំល្អសម្រាប់ប្រជាពលរដ្ឋ?

**ឆ៖** សូមឆ្លើយទៅតាមសំណួរដែលសួរ ហើយផ្សារភ្ជាប់នឹងចម្លើយដែលខ្ញុំយល់។ ទីមួយ ខ្ញុំពិនិត្យឃើញថា ជារូបភាព ជាមនុស្សធម្មតា។ តែទីពីរកិច្ចសម្រេចអីផ្សេងៗ លម្អិតអីផ្សេងៗវាជាតួនាទីភារកិច្ចរបស់ខាងលើ។ ដូច្នេះខ្ញុំមិនអាចវិនិច្ឆ័យយ៉ាងម៉េចបានទេបាទ។ សូមអស់។

**ស៖** សូមអរគុណ។ តាំងពីឆ្នាំ១៩៧៥ មក ពេលដែលលោកបានផ្លាស់ប្តូរពីទីកន្លែងមួយទៅកន្លែងមួយច្រើនដង តើពេលផ្លាស់ប្តូរនោះមានធ្វើជាលិខិតស្នាមពីថ្នាក់លើ ដើម្បីឱ្យលោកផ្លាស់ប្តូរ ឬគ្រាន់តែនិយាយតាមមាត់ទទេថា អ្នកលោក នី កន ទៅនេះទៅនោះអ៊ីចឹងទៅ បែបបទនៃកិច្ចការរដ្ឋបាលហ្នឹង តើលោកអាចបញ្ជាក់ជម្រាបតុលាការបានទេ?

**ឆ៖** ខ្ញុំជម្រាបជូនបាន គឺរបៀបរបបដឹកនាំពេលនោះ ថ្នាក់ក្រោមគោរពថ្នាក់លើបន្តបន្ទាប់។ ដូច្នេះមានតែការបញ្ជាក់ថា លោកត្រូវទៅជួយការងារខាងក្រសួងវិញ។ ខ្លឹមសារ ឬហេតុផលនៃការដែលថា លោកត្រូវទៅ ដដែល គឺលោកមានសមត្ថភាពខាងអក្សរ ខាងលេខ សមរម្យទៅធ្វើការងារខាងក្រសួង ឯនៅមូលដ្ឋានមិនបាច់ទេ មិនស្របទេ។ តែប៉ុណ្ណឹងបាទ។

[០៩:៥៩:៣៥]

**ស៖** សំណួររបស់ខ្ញុំ ភ្ជាប់នឹងសំណួរអម្បាញ់មិញនេះ ចង់សួរថា ក្នុងរចនាសម្ព័ន្ធរបស់កម្ពុជាប្រជាធិបតេយ្យដែលលោកបានដឹង បានធ្លាប់អនុវត្តផ្ទាល់។ ឧទាហរណ៍ថា លោកជាប្រធាននាយកដ្ឋានអីមួយចុះ ឬក៏រដ្ឋមន្ត្រីមួយ ក្រោមហ្នឹង ថ្នាក់ក្រោមហ្នឹងមានៗអនុ ពាក្យខ្មែរថា “អនុ” ដើម្បីធ្វើការជំនួស

ថ្នាក់លើទេ? លោកយល់សំណួរខ្ញុំទេ?

**ឆ៖** សូមអភ័យទោស សូមបញ្ជាក់ម្តងទៀត។

**ស៖** ខ្ញុំចង់សួរថា ថ្នាក់ដឹកនាំម្នាក់ ថ្នាក់ដឹកនាំណាក៏ដោយ ឧទាហរណ៍ថា រដ្ឋមន្ត្រី ឬក៏ភូមិភាគ បន្ទាប់ពីភូមិភាគ ឬពីរដ្ឋមន្ត្រីហ្នឹងមកមាន អនុម្នាក់ ឬពីរនាក់ ដូចរចនាសម្ព័ន្ធរដ្ឋបាលទូទៅក្នុងពិភពលោកទេ ឬក៏ថាអត់ទេ មាននរណាប្រធានហើយ រួចពីហ្នឹងចង់ប្រើអ្នកណាធ្វើអីក៏បាន។ អីចឹងដែរ ឬក៏ៗមាន-- ត្រូវមានអនុអីដូចគ្នាអីចឹង?

[១០:០១:២២]

**ឆ៖** សូមជម្រាប ជារួមមាន ជាមូលដ្ឋានដូចគ្នា តែដោយឡែកខ្ញុំ ៗដកមកហើយ ដាក់ជាអ្នកទទួលភារកិច្ចខាងនាំភ្ញៀវ ហើយក៏មិនទាន់បានកំណត់ខ្ញុំជាយ៉ាងម៉េចច្បាស់ ពេលនោះ មន្ទីរប្រគល់ឲ្យខ្ញុំយុវជន ហើយនិងយុវនារីប្រហែលជាបីនាក់ សម្រាប់ជួយការងារខ្ញុំ។ ដូច្នេះខាងក្រោមខ្ញុំមិនទាន់មានអនុអីទេបាទ។

**ស៖** សូមអរគុណ។ លោក សុន សេន ជាបងរបស់លោក ពេលដែលលោក សុន សេន ទៅបំពេញបេសកកម្មនៅបូព៌ាទិស នៅពេលដែលខាងបូព៌ាទិសមានវិវាទគ្នា គឺនៅថ្ងៃ១៥ សីហា ឆ្នាំ១៩៧៧ ពេលនោះ លោកដឹងថាលោក សុន សេន ហ្នឹងតាមបែបបទរដ្ឋបាលធ្វើការលោកមានចាត់អ្នកណាឲ្យនៅជំនួសគាត់នៅក្នុងក្រសួងការពារជាតិ និងសន្តិសុខជាតិ និងអន្តរជាតិទេ?

**ឆ៖** សូមជម្រាបជូនបាទ។ ដូចបានជម្រាបបន្តបន្ទាប់ ការងារដាច់ដោយឡែកពីគ្នា តួនាទីក៏ខុសគ្នា ដូច្នេះការដែលសួរថា ខ្ញុំដឹងអំពីរចនាសម្ព័ន្ធរបស់បងប្រុសខ្ញុំ ខ្ញុំសូមបញ្ជាក់ជូនថាមិនដឹងទេ។

[១០:០៤:០៩]

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរមួយសំណួរថែមទៀត ពេលដែលលោកធ្វើការឃោសនាអប់រំអស់រយៈពេលយ៉ាងយូរ។ ខ្ញុំសូមសួរថា មុនពេលធ្វើការបោះ-- មុនពេលធ្វើការនោះ តើលោកមានបានទៅសិក្សា រៀនសូត្រអំពីយុទ្ធសាស្ត្រ និងបច្ចេកទេសឃោសនាអប់រំដែរឬទេ?

**ឆ៖** សូមឆ្លើយ កាលៈទេសៈពេលនោះ ដូចតាមខ្ញុំចាំមិនខុសទេ-- បើមិនខុសទេ គឺគ្មានការបណ្តុះបណ្តាលជាសាលាស្អី ដើម្បីបណ្តុះបណ្តាលគ្រូបង្រៀននយោបាយអី ដូចគ្មានទេ គ្មានទេបាទ។ មានតែការទទួលបន្ត ហើយមើលចំណាំកត់ត្រាតាមបន្ត ថាតើបើគេអប់រំ គេឃោសនា គេនិយាយអីមុន ហើយក្រោយមកខ្លឹមសារ គេនិយាយរឿងអី? ប៉ុណ្ណឹង ហើយចេះតែធ្វើតាមបន្តៗមកបាទ។

**ស៖** លោកអាចបញ្ជាក់យ៉ាងខ្លីជម្រាបតុលាការថា ការអប់រំដែលលោកបានឮបន្តៗមកនេះ ហើយយកទៅអនុវត្ត ច្រើនតែគេអប់រំពីរឿងអី?

[១០:០៧:០២]

**ឆ៖** ការអប់រំ និងខ្លឹមសារអប់រំ តាមខ្ញុំចាំ គេយោងទៅតាមពេលវេលា យោងទៅតាមមជ្ឈដ្ឋាន ឬមជ្ឈដ្ឋានៗបាទ ឬមូលដ្ឋាន។ ឧបមាថា បើទៅកន្លែងមូលដ្ឋាន គេលើកពីបញ្ហាវ៉ៃសម្រុកបង្កបង្កើនផលឧបត្ថម្ភខ្លួន ដើម្បីអនុវត្តនយោបាយឯករាជ្យ ខ្លួនទីពឹងខ្លួន ហើយហ្នឹងជាទីមួយ។ ទីពីរ បើមានបញ្ហារួមផ្សំជាសុខភាព រួមផ្សំជាសាមគ្គី ក៏យកខ្លឹមសារនេះ គួបផ្សំអប់រំទៅ ធ្វើម៉េចចងក្រងសាមគ្គីគ្នា ឈរលើមូលដ្ឋានអី? ឈរលើមូលដ្ឋានជាតិតែមួយ ហ្នឹងអ៊ីចឹង។ រួចហើយបើសិនជាសុខភាពត្រូវហូបទឹកក្តៅ ហូបទឹកក្តៅ ត្រូវ អ្ហ៊ឺ!ធ្វើម៉េចត្រូវមានការចាត់តាំងដាំ ហើយគ្មានថ្នាំយកអី? សូមបន្ថែមមួយម៉ាត់ទៀត គឺយកវល្លិ៍ជុយ។ បាទនេះសូមជម្រាបជូនលោកប៉ុណ្ណឹង។ បើសម័យដែលចាំបាច់កម្លាំងទៅមុខ គេឃោសនាអប់រំ គេយកខ្លឹមសារថា ចូលរួមការតស៊ូ ដើម្បីរំដោះជាតិ។ ទីពីរចូលរួមឲ្យអស់សមត្ថភាពលទ្ធភាពជួយដឹកជញ្ជូន។ ហើយថែមខ្លះទៀត គឺចូលរួមឧបត្ថម្ភសមរភូមិមុខ មានអីឧបត្ថម្ភហ្នឹងទៅ។ បាទខ្ញុំជម្រាបជូនតាមការចងចាំ និងតាមការដែលខ្ញុំធ្លាប់ប្រតិបត្តិជូនប៉ុណ្ណឹងបាទ។

[១០:០៩:៣៣]

**លោក សុន អរុណ៖**

អរគុណ។ ខ្ញុំមានឃើញឯកសារមួយ ឯកសារហ្នឹងលេខ D91/22 ERN 02044134។ ខ្ញុំសូមឲ្យបញ្ចាំងនៅលើអេក្រង់ ហើយនិងជូនទៅសាក្សីបានអានក្នុងឯកសារនេះ ដើម្បីខ្ញុំមានសំណួរ។

**ប្រធានអង្គជំនុំ៖**

មានចំណងជើងឯកសារថាម៉េចទៅ?

**លោក សុន អរុណ៖**

ចំណងជើងឯកសារនេះមានសរសេរធំៗខាងក្រោមដាក់៖ *"មីនីស្រ្ទី អូហ្វហ្វ័ររិន អាហ្វែរ អាលីយ៉ាស ប៊ីវ័ន"* (Ministry of Foreign Affairs Alias B-1)។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំអនុញ្ញាត។ មន្ត្រីតុលាការទទួលឯកសារជាក្រដាសពីមេធាវីយកទៅជូនសាក្សីពិនិត្យ ហើយនិងអនុញ្ញាតបុគ្គលិកជំនួយការបង្ហាញឯកសារនោះនៅលើកញ្ចក់អេក្រង់កុំព្យូទ័រ។

**សួរដោយលោក សុន អរុណ៖**

**ស៖** នៅក្នុងឯកសាររចនាសម្ព័ន្ធនេះលោកមានដែលបានឃើញទេ?

មានឈ្មោះលោកនៅខាងលើជួរលើបំផុត។ ចាប់ពី អៀង សារី មកនៅខាងស្តាំប្រអប់លេខ អៀង សារី-- ១,២,៣,៤ ប្រអប់ទីបួនមានឈ្មោះ នី កន។

**លោក នី កន៖**

**ឆ៖** សុំជម្រាបជូន បាទឃើញបាទ។

**ស៖** លោកធ្លាប់ឃើញរចនាសម្ព័ន្ធរបស់ក្រសួងការបរទេសនេះ។ លោកបានឃើញហើយ-- ឥឡូវខ្ញុំនិយាយតែប្រអប់របស់លោកផ្ទាល់មួយ។ ខាងលើដាក់ឈ្មោះ៖ ទី ស្រ៊ិន *អាលីយ៉ាស* មុត (Ti Srin alias Mut), ហើយ នី កន *ប្រូតូកូល ឌីផាតម៉ិន* (Protocol Department) លោកអានបានទេ ទាំងអស់ហ្នឹង ក្រៅពីខ្ញុំអានទៅ លោកអានបានទេអក្សរអស់ហ្នឹងដូចជា ទី ស្រ៊ិន ហើយទីស្ទី ខ្ញុំអានមិនច្បាស់ទេ ហើយនិង *អាលីយ៉ាស* មុត, មុត ហ្នឹងមានសក់អីណាវង់ព្រះខែនៅខាងលើអីចឹងៗ ហើយឃើញ ខ្ញុំឃើញមិនមែនតែលើឈ្មោះប្រអប់លោកហ្នឹងមួយទេ គឺប្រអប់ទាំងអស់ សឹងតែទាំងអស់មានធ្វើអីចឹង។ តើអក្សរហ្នឹងលោកមានស្គាល់ទេ អក្សរមានសក់មានអីអីចឹង? ពីដើមមកអីចឹង ឬម៉េច?

[១០:១៣:៣៩]

**ឆ៖** សុំឆ្លើយបញ្ជាក់ជូន គឺបើតាមខ្ញុំ ភាសាខ្ញុំនិយាយ គឺថាតារាងនេះ ខ្ញុំទើបតែឃើញពេលក្រុមចៅក្រមស៊ើបអង្កេតយកទៅឲ្យខ្ញុំទេ នេះទីមួយ។ ទីពីរ ឈ្មោះ ទី ស្រ៊ិន អីនេះ ខ្ញុំមិនស្គាល់ទេ។ ទីបីឈ្មោះក្នុងពេលសង្គ្រាម ឬក្រោយសង្គ្រាម ឬហៅថាចន្លោះ ៧៥-៧៩ នេះមានតែ “កន” ទេ អត់មាន “នី” ផងបាទ ព្រោះត្រកូលនេះក៏មិនដែលដាក់។ ជំនាន់នោះគឺថា យកអាណាខ្លីៗ ចំណេញពេលចំណេញវេលា ហើយវាស្វាត់។ ដូច្នេះ ខ្ញុំឆ្លើយជូនលោកបានប៉ុណ្ណឹង។ គឺសរុបទៅខ្ញុំទើបតែឃើញពេលចៅក្រមយកទៅសម្ភាសខ្ញុំទេបាទ។

[១០:១៥:០៥]

**ស៖** លោកបានបញ្ជាក់ថា លោកបានឃើញនៅពេលដែលចៅក្រមស៊ើបអង្កេតបង្ហាញជូន។ ប៉ុន្តែមកដល់ថ្ងៃនេះ ខ្ញុំសូមបង្ហាញលោកម្តងទៀត តើលោកទទួលស្គាល់រចនាសម្ព័ន្ធហ្នឹងទេ?

**ឆ៖** សូមបញ្ជាក់សាជាថ្មី រចនាសម្ព័ន្ធនេះ ខ្ញុំបានបញ្ជាក់បន្តបន្ទាប់ដដែល គឺថាខ្ញុំត្រូវដកយកមកដាក់នៅកន្លែងពិធីការអីចឹងមែន។ តែតួនាទី ខ្ញុំជាអ្នកអនុវត្ត មិនទាន់ជាផ្លូវការថា ខ្ញុំជាចាងហ្វាង

ជាអីអត់ទេ។ ហើយអនុវត្តក្នុងរយៈពេលខ្លី។ នេះជាការបញ្ជាក់ ខ ទីមួយ។ ហើយជាការបញ្ជាក់ ខ ទីពីរ ពេលនោះគ្មានរឿង ឬក៏អ្នកណាគុបតែងក្រោយម៉េច ឬក៏ផ្នែកបច្ចេកទេសអ្នកជំនាញនៅក្រសួងគេគុបតែងយ៉ាងម៉េចខ្ញុំមិនដឹង។ តែគ្មានសរសេរអីលាយលក្ខណ៍អក្សរថា អ្នកនេះនៅស្មើអ្នកនេះ អ្នកនេះនៅប្រអប់នេះប្រអប់នោះអីអត់ទេបាទ។ សូមបញ្ជាក់ជូនប៉ុណ្ណឹង។

**ស៖** បើដូច្នេះ កាលពីលោកចូលទៅធ្វើការនៅក្រសួងការបរទេស ក្នុងការិយាល័យពិធីការ លោកអត់បានឃើញរចនាសម្ព័ន្ធនេះទេ អ៊ីចឹងទេណា? ហើយដល់ពេលនេះ ដល់ពេលចៅក្រមស៊ើបអង្កេតបង្ហាញលោក លោកបានឃើញ។ អ៊ីចឹងហើយបានខ្ញុំសួរបញ្ជាក់អំមិញ។ ឥឡូវខ្ញុំសួរបញ្ជាក់ម្តងទៀតថា តើលោកទទួលស្គាល់រចនាសម្ព័ន្ធហ្នឹង ឬមិន-- ឬក៏មិនទទួលស្គាល់ទេ?

[១០:១៧:២៥]

**ប្រធានអង្គជំនុំ៖**

សំណួរច្រំដែលមិនបាច់ឆ្លើយទេ! សាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ! សំណួរច្រំដែល។ លោកមេធាវីសួរទៅមុខទៀត។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរបន្តទៅទៀត។ អក្សរទាំងឡាយនៅលើរចនាសម្ព័ន្ធនេះ ដែលមានសក់ ៗមានសញ្ញាដូចព្រះខែអីអ៊ីចឹងនៅពីលើសក់ទាំងអស់ហ្នឹង ដែលលោកធ្លាប់បានរៀនសូត្រមក តើអក្សរបារាំង ឬអក្សរឡាតាំង ឬពេលសម័យលោកប្រហែលជាមិនសូវរៀនអង់គ្លេសទេ លោកទទួលស្គាល់ថា អក្សរហ្នឹងវាប្រាកដជាខ្មែរយើងធ្វើទេ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ សូមបញ្ជាក់ជូនថាខ្ញុំយល់មិនដល់ទេ ពីព្រោះខ្ញុំទើបនឹងឃើញ រួចឲ្យខ្ញុំសន្និដ្ឋានថា ខាងណាធ្វើ ខាងណាមិនធ្វើអីក៏មិនបានដឹងបាទ។

[១០:១៩:០៧]

**ស៖** សូមអរគុណ។ ខ្ញុំសួរសំណួរទៅមួយផ្សេងទៀត ហើយជាសំណួរបញ្ចប់របស់ខ្ញុំ។ ឯកសារលេខ D366/7.1.214 ដែលសហព្រះរាជអាជ្ញាបានសួរលោករួចមកមួយចំនួនធំហើយ តែពេលនេះខ្ញុំសូមសួរបន្ថែមនូវសំណួរដូចតទៅ។ សំណើរបស់អ្នកកាសែតអាមេរិក និងសាស្ត្រាចារ្យអង់គ្លេសបីនាក់បានធ្វើសំណូមពរដោយឡែកពីគ្នា។ សួរថា តើសំណូមពរទាំងអស់ ដូចរបាយការណ៍របស់លោក

ដែលផ្ញើទៅថ្នាក់លើនោះ តើលោក-- តើថ្នាក់លើបានអនុញ្ញាតឲ្យតាមសំណូមពររបស់ជនបរទេសទាំងបីនាក់នោះ ឬទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំបានបញ្ជាក់ម្ដងហើយ គឺថាពេលវេលាយូរ រួចហើយខ្លឹមសារ គ្រាន់តែដាក់ឈ្មោះខ្ញុំ ខ្ញុំចាំមិនអស់ទេ។ តែទីពីរ សន្និដ្ឋាន តាមការចងចាំខ្លះ ដូចជាមិនបានតាមសំណូមពរទេបាទ។

**ស៖** ចុះសំណូមពររបស់ស្រី បេកយ័រ ជនជាតិអាមេរិកាំង ស្នើសុំធ្វើសម្ភាសជាមួយបងរដ្ឋមន្ត្រីទីមួយ តើថ្នាក់លើអនុញ្ញាតឲ្យជួបទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំមិនចាំទេបាទ។

**លោក សុន អរុណ៖**

ខ្ញុំអស់សំណួរហើយលោកប្រធាន សូមអរគុណ។ សហការីខ្ញុំនឹងសួរបន្ត។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអញ្ជើញ!

[១០:២២:០៩]

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** លោកសាក្សី ខ្ញុំជាមេធាវីអន្តរជាតិ ការពារក្ដីឲ្យលោក នួន ជា ហើយខ្ញុំមានសំណួរមួយចំនួនត្រូវសួរទៅលោក។ ខ្ញុំមានប្រធានបទប្រហែលជាបីបួន ហើយមុននឹងសម្រាកនេះ ខ្ញុំអាចនឹងនិយាយប្រហែលជាប្រធានបទមួយ មុននឹងសម្រាកបាទ។ លោកសាក្សី ជាបឋមខ្ញុំចង់សួរសំណួរមួយចំនួន ដែលលោកធ្វើសច្ចាប្រណិធាន ដែលលោកស្បថ មុនពេលដែលលោកមកតុលាការនេះ។ តើត្រូវដែរឬទេ លោកបានប្រាប់តុលាការថា នៅពេលដែលចាប់ផ្ដើមផ្ដល់សក្ខីកម្មហ្នឹង លោកបានធ្វើសម្បថរួចហើយ? ដែលលោកបានធ្វើហើយ តើមែនឬទេ មុនពេលមកតុលាការ តើត្រូវអ៊ីចឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ! បញ្ហានេះ អង្គជំនុំជម្រះបានជម្រាបជូនរួចហើយ មានទាំងកំណត់ហេតុ និងរបាយការណ៍របស់ក្រឡាបញ្ជី ហើយអង្គជំនុំជម្រះបានជម្រាបជូនសាធារណជន និងភាគីរួចហើយ កាលពីម្សិល-- កាលពីថ្ងៃដំបូង នៃការចាប់ផ្ដើមសវនាការ។

[១០:២៣:៣៦]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** តើលោកបានធ្វើសម្បថនៅទីណា លោកសាក្សី?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយទេ! ឲ្យគាត់-- មេធាវីមើលប្រតិចារឹកទៅ មានកំណត់ក្នុងកំណត់ហេតុហ្នឹង គឺមានហើយ។ នៅទីនេះ គឺសាក្សីមុននឹងឆ្លើយ គឺត្រូវធ្វើសម្បថនៅអ្នកតាដំបងដែក គឺនៅមុខ-- នៅខាងកើតនៃអគារសវនាការនេះ។

**លោក ម៉ៃខល ផេសមិន៖**

បាទ ខ្ញុំយល់ហើយលោកប្រធាន។ គឺថាជានីតិវិធីធម្មតា ក៏ប៉ុន្តែខ្ញុំចង់ឲ្យប្រាកដថា តើបានគោរពតាមនីតិវិធីត្រឹមត្រូវដែរឬទេ ចំពោះរូបសាក្សីម្នាក់នេះ?

**ប្រធានអង្គជំនុំ៖**

លោកអាចសំណួរផ្សេងទៀត ដែលមិនពាក់ព័ន្ធនឹងបញ្ហានេះ។ សំណួរអម្បាញ់មិញនេះ យើងមិនឲ្យសាក្សីឆ្លើយទេ។

[១០:២៤:៥២]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមានសំណួរមួយចំនួនទាក់ទងទៅនឹងសំណួរសម្បថ ហើយនិងខ្ញុំនឹងសួរ។ លោកសាក្សី ខ្ញុំយល់លោកបានផ្តល់ធ្វើការសម្បថនៅខាងក្រៅ មុនពេលដែល-- គឺបានចំពោះមុខអ្នកដំបងដែក។ តាមធម្មតា គឺសម្បថត្រូវបានធ្វើឡើងនៅក្នុងតុលាការ។

**ប្រធានអង្គជំនុំ៖**

យើងសម្រេចមិនឲ្យលោកសួរពាក់ព័ន្ធនឹងបញ្ហាសម្បថនេះទេ យើងបានប្រកាសជាសាធារណៈរួចហើយ។ ប្រសិនបើមានកំហុសនីតិវិធី នៃការមិនធ្វើសម្បថ លោកអាចធ្វើនីតិវិធីនៃការមោឃភាពទៅលើការផ្តល់សក្ខីកម្មរបស់សាក្សីនេះបាន នៅចុងទីបញ្ចប់នៃសេចក្តីសន្និដ្ឋានបញ្ចប់កិច្ចពិភាក្សាដេញដោល។

**លោក ម៉ៃខល ផេសមិន៖**

សូមលោកប្រធាន-- ខ្ញុំជម្រាបថា ខ្ញុំមិនចង់ជំទាស់ដេញដោលនឹងសាក្សីនេះទេ ប៉ុន្តែខ្ញុំចង់ថាតើ

សាក្សីបានគោរពទៅតាមនីតិវិធី ដែលតុលាការតម្រូវដែរឬទេ។ ហើយខ្ញុំសូមបញ្ជាក់ថា តាមធម្មតាការសម្បថគឺត្រូវធ្វើឡើងនៅ-- គឺនៅក្នុងសាលសវនាការ ដោយមានវត្តមានរបស់ភាគីទាំងអស់នោះផងដែរ។ ហើយ--

**ប្រធានអង្គជំនុំ៖**

នេះមិនមែនជានីតិវិធី ដែលត្រូវអនុវត្តនៅទីនេះទាំងស្រុងទេ។ លើកលែងតែអ្នកនោះ មិនកាន់ពុទ្ធសាសនា គឺអ្នកដែលកាន់សាសនាផ្សេងទៀត មានយេស៊ូ-- សាសនាគ្រីស្ត សាសនាជាដើម ទើបយើងធ្វើនីតិវិធីនេះ ចំណែកឯភាគីផ្សេងទៀតដែលកាន់ព្រះពុទ្ធសាសនា ត្រូវធ្វើសម្បថនៅអ្នកតាដំបងដែកតាមនីតិវិធី របស់អង្គជំនុំជម្រះដែលបានកំណត់យកតាមខ្លឹមសារ នៃនីតិវិធីនៃការធ្វើសម្បថដែលមានចែងនៅក្នុងព្រហ្មទណ្ឌ-- នីតិវិធីព្រហ្មទណ្ឌខ្មែរ ដែលបានរៀបចំហើយ។ សាក្សីជាច្រើនហើយដែលបានមកផ្តល់សក្ខីកម្មនៅទីនេះ ដោយធ្វើសម្បថនៅចំពោះមុខអ្នកតាដំបងដែក តាមវប្បធម៌ តាមច្បាប់កម្ពុជា ចំពោះដែលកាន់ព្រះពុទ្ធសាសនា។ លើកលែងតែ អ្នកដែលកាន់សាសនាផ្សេងទៀតមានគ្រីស្តសាសនា ទើបយើងតម្រូវឲ្យធ្វើនៅទីនេះ ទោះបីជាប្រជាជនខ្មែរ ឬក៏ពលរដ្ឋខ្មែរក៏ដោយ។

[១០:២៧:២៨]

**លោក ម៉ែខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំយល់ពីបញ្ហានេះ។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** បាទ នេះជាទម្លាប់អនុវត្តច្បាប់នៅកម្ពុជា ប៉ុន្តែឥឡូវនេះ ខ្ញុំនឹងចូលដល់សំណួរជាក់លាក់។ តាមឯកសារដែលដាក់នៅក្នុងសំណុំរឿងនោះ លោកបានធ្វើសម្បថរួចហើយ លោកបាននិយាយថា ដូចខាងក្រោមនេះ ខ្ញុំសូមដកស្រង់ "បើខ្ញុំឆ្លើយមិនពិតតាមបញ្ហាមួយណាទេ សូមឲ្យទេវតា អ្នកតា ហើយនិងបារមី ដែលមានឥទ្ធិពលបំផ្លាញខ្ញុំ ហើយនិងទ្រព្យសម្បត្តិរបស់ខ្ញុំត្រូវខ្ទេចខ្ទី ហើយខ្ញុំត្រូវស្លាប់ដោយវេទនាបំផុត។" តើលោកនៅចាំពាក្យដែលលោកបានធ្វើសម្បថបែបនេះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ!

ឲ្យតែសំណួរណាពាក់ព័ន្ធនឹងការធ្វើសម្បថ នីតិវិធីហ្នឹងមិនបាច់ឆ្លើយទេ។ ចាំឆ្លើយនៅសំណួរសារធាតុទៅបានហើយ។

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន។ ខ្ញុំប្រហែលជាលោកមិនយល់ថា មូលហេតុអ្វីដែលខ្ញុំត្រូវសួរសំណួរនេះ។ ថាតើសាក្សីរូបនេះបានធ្វើសាក្សី ហើយឬអត់ គាត់បានប្រើពាក្យហ្នឹងដែរឬអត់? ហើយជាបឋម ខ្ញុំចង់ដឹងថាតើសាក្សីនេះគាត់ជឿជាក់នៅលើសម្បថ ដែលគាត់បានស្បថចំពោះអ្នកតាដំបងដែកឬទេ? ហើយខ្ញុំចង់ដឹងថាតើគាត់ឆ្លើយនៅក្នុងពាក្យសម្ដី ដែលគាត់បានស្បថដែរឬទេ? ថាតើគាត់យល់ទេថា គាត់ឲ្យស្បថថា បើគាត់ឆ្លើយមិនពិតឲ្យគាត់ស្លាប់ដោយវេទនា ដោយហិនហោចទ្រព្យសម្បត្តិនោះ។ ខ្ញុំគ្រាន់តែចង់បញ្ជាក់គាត់តែប៉ុណ្ណឹងទេបាទ។

[១០:២៩:៣១]

**ប្រធានអង្គជំនុំ៖**

តើលោកមានទំនងមានសំណួរអីសារធាតុផ្សេងទៀតទេ? បើមិនមានសំណួរផ្សេងទៀតទេ គឺអង្គជំនុំជម្រះនឹងបញ្ចប់លោកត្រឹមនេះ ហើយនិងប្រគល់វេទិកាជូនទៅភាគី ក្រុមមេធាវីការពារក្ដីដទៃទៀត។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំកំណត់ថា ខ្ញុំសូមសួរសំណួរនេះ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកគិតថា អ្នកតាដំបងដែក-- ខ្ញុំសូមអនុញ្ញាតសួរឡើងវិញបាទ។ តើវត្ថុមានតុលាការនេះ--

**ប្រធានអង្គជំនុំ៖**

សម្រេចហើយមិនឲ្យសួរទេ នូវសំណួរនីតិវិធីនៃការធ្វើសម្បថនេះ។ អង្គជំនុំជម្រះប្រកាន់ជំហរគឺការសម្រេចដូច្នេះ ហើយបានសម្រេចរួចហើយ ឲ្យលោកចូលទៅសំណួរផ្សេងទៀត ដែលជាសំណួរសារធាតុ។ ចំពោះសំណួរនីតិវិធីនៃការធ្វើសម្បថនេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកសួរទេ។

[១០:៣០:៥៣]

**លោក ម៉ៃខល ផេសមិន៖**

តាមពិតខ្ញុំមានសំណួរសារធាតុ ប៉ុន្តែមុនខ្ញុំចង់ដឹងថា តើសាក្សីនេះគាត់បានយល់អំពីការស្បថដូចដែលលោកប្រធានយល់ដែរឬទេ អំពីគោលបំណងដែលគាត់ស្បថ ហើយមកឆ្លើយនេះ។ ឥឡូវនេះគឺជា

ដល់ពេលសមល្មមនឹងត្រូវផ្អាកទៅចំណុចនេះ ហើយខ្ញុំនឹងបន្តទៅប្រធានបទមួយផ្សេងទៀតបាទ។

បាទ សមពេលល្មមនឹងសម្រាកសិន ហើយខ្ញុំសូមអនុញ្ញាតបន្ត។

**ប្រធានអង្គជំនុំ៖**

របៀបរបបក្នុងការសម្រាក ឬមិនសម្រាក នេះជាសិទ្ធិរបស់ប្រធានសវនាការជាអ្នកសម្រេច។ ភាគីពាក់ព័ន្ធមិនមានសិទ្ធិអីមកសម្រេចពីរឿងនីតិវិធី នៃការសម្រាក ឬមិនសម្រាកទេ។ យើងស្ដាប់បញ្ហានេះដូចញ៊ីកញាប់ហើយ។ បញ្ហាយើងបានរំឮកញ៊ីកញាប់ហើយ ទាំងតំណាងសហព្រះរាជអាជ្ញាផង រឿងបញ្ហាគ្រប់គ្រងកិច្ចដំណើរការសវនាការ គឺយើងជាអ្នកទទួលខុសត្រូវនៅក្នុងច្បាប់ស្ដីពីនីតិវិធីព្រហ្មទណ្ឌ ក៏ដូចជាវិធានផ្ទៃក្នុងដែរ រួមនឹងអង្គជំនុំជម្រះ ដែលត្រូវទទួលខុសត្រូវក្នុងការគ្រប់គ្រងសម្របសម្រួលកិច្ចដំណើរការសវនាការឲ្យប្រព្រឹត្តទៅឆាប់រហ័ស និងមានប្រសិទ្ធភាពនោះ។

**លោក ម៉ៃខល ផេសមិន៖**

ហើយកូនក្ដីរបស់ខ្ញុំក៏ចង់បានចេតនានេះដែរ។ ហើយខ្ញុំនឹងបន្តទៅទៀត។

[១០:៣២:៣៧]

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី សូមលោកពន្យល់ខ្ញុំនិងតុលាការដោយសង្ខេបថា ហេតុអ្វីបានគេផ្ទេរលោកពីតំបន់៣២ ទៅក្រសួងការបរទេសកាលពីសម័យនោះបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ!

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងឈលៈ**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំមិនចង់កាត់ផ្ដាច់ទេ។ សំណួរនេះគឺថាត្រូវបានចោទសួរកាលពីម្សិលមិញហើយ ហើយអម្បាញ់មិញនេះក៏គេចោទសួរសំណួរនេះដែរ។ ខ្ញុំគិតថា ប្រហែលជាសំណួរដដែលៗហើយ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សេចក្ដីជំទាស់របស់តំណាងសហព្រះរាជអាជ្ញាមានប្រសិទ្ធភាព។ សាក្សីមិនចាំបាច់ឆ្លើយតបនឹងសំណួរអម្បាញ់មិញនេះទេ ពីព្រោះជាសំណួរច្រំដែល នាំឲ្យខាតពេលឥតប្រយោជន៍។

[១០:៣៣:៥០]

**លោក ម៉ៃខល ផេសមិន៖**

ហើយមុននឹងធ្វើសេចក្តីសម្រេច ក៏ប៉ុន្តែការកត់សម្គាល់ជាទូទៅមួយ ខ្ញុំចង់ជម្រាបតុលាការថា នេះគឺជាផ្នែកមួយនៃការសួរដេញដោល ដើម្បីសួរសាក្សី ដើម្បីសួរសំណួរដដែល ដើម្បីបញ្ជាក់ថា តើគាត់ឆ្លើយដូចម្តេច។ ខ្ញុំសូមជម្រាបថា វាកើតឡើងជាញឹកញាប់នៅក្នុងតុលាការយើងនេះ ប៉ុន្តែគឺថា ភាគីសួរសំណួរដដែល។ បាទ ហើយខ្ញុំសូមបញ្ជាក់ថា ទោះបីជាយើងសួរដដែលហើយ ពេលខ្លះចម្លើយក៏មិនបានប្រាកដនោះដែរ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី--

**ប្រធានអង្គជំនុំ៖**

លោកអាចបន្តសំណួរផ្សេងណា! លោកមេធាវីតទៅសំណួរផ្សេងទៀត។ ព្រោះសំណួរអម្បាញ់មិញនេះយើងបានសម្រេចរួចហើយ។

[១០:៣៤:៤២]

**លោក ម៉ៃខល ផេសមិន៖**

បាទ លោកប្រធាន ខ្ញុំបានទទួលការណែនាំនោះហើយ។ ឥឡូវនេះខ្ញុំនឹងសួរ។

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកមានបញ្ហាអ្វីទេ ដែលជាបញ្ហាលំបាកនៅក្នុងតំបន់៣២នោះ កាលលោកធ្វើការនៅពេលនោះ?

**ឆ៖** សូមឆ្លើយ ខ្ញុំជាបុគ្គលមួយ ហើយមានតួនាទីទទួលខុសត្រូវមួយផ្នែកដូចបានជម្រាប។ ហើយពេលនោះ កិច្ចការអីទាំងអស់ឲ្យតែខាងលើប្រគល់ជូន រីករាយនឹងធ្វើដោយអស់ពីចិត្តពីថ្លើម គ្មានតថ្លៃ។ ហើយក្នុងសភាពដែលចលនារួមវាអ៊ីចឹង ខ្ញុំក៏មិនឃើញថាមានការលំបាកអីទេបាទ។

**អ្នកបកប្រែ៖**

ពីអ្នកបកប្រែ សូមកែតម្រូវ គាត់សួរថាតើលោកមានបញ្ហារឿងស្រីញីដែរឬទេ នៅតំបន់៣២បាទ?

**ស៖** បាទ តើនៅពេលដែលគេបញ្ជូនបញ្ហាលោកទៅប-១ ដោយសារតែលោកមានបញ្ហារឿង

ស្រីញ៉ូ ថាតើពិតដែរ ឬទេ? គឺថា គេបញ្ជូនលោកទៅប-១ដោយសារលោកមានបញ្ហារឿងស្រីញ៉ូតើអ៊ីចឹង មែនឬទេ?

[១០:៣៦:៣៥]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរហ្នឹងទេ! សំណួរហ្នឹងមិនពាក់ព័ន្ធជាមួយនឹងអង្គហេតុដែលត្រូវចោទប្រកាន់ចំពោះជនជាប់ចោទទេ។ មិនមានបង្ហាញ លាតត្រដាងនៅក្នុងបណ្តាកថាខណ្ឌនានា ដែលបានចោទប្រកាន់ នៅក្នុងដីកាដំណោះស្រាយចោទប្រកាន់ជនជាប់ចោទទេ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំសូមជម្រាបថា សំណួរនេះគឺមានការពាក់ព័ន្ធទៅនឹងអ្វីដែលមានបញ្ជាក់ គឺថាមិនមានចំណុចណាមិនពាក់ព័ន្ធទេ។ យើងទទួលបានព័ត៌មានថា បញ្ហាស្រីញ៉ូ ឬក៏សីលធម៌ គឺជាមូលហេតុសំខាន់ដែលគេប្តូរកម្មាភិបាលមួយទៅកន្លែងមួយផ្សេងទៀតដូចទៅក្រសួងការបរទេស។ ពីម្សិលមិញគឺថា យើងដឹងតាមរយៈសហព្រះរាជអាជ្ញាសួរសំណួរថា គឺ--

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះបានសម្រេចរួចហើយ។ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកធ្វើអត្ថាធិប្បាយអីផ្សេងទៀតទេ។ លោកតាំងសំណួរថ្មីទៀត ប្រសិនបើមាន។ ប្រសិនបើលោកអស់សំណួរហើយ ត្រូវប្រាប់យើង ថាលោកអស់សំណួរហើយ។ យើងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីផ្សេងទៀត។

[១០:៣៧:៥៤]

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមានសំណួរ ហើយខ្ញុំមានប្រធានបទផ្សេងទៀត ខ្ញុំចង់សួរបន្តទៀត ចំពោះសាក្សីរូបនេះ។ ហើយខ្ញុំព្យាយាមឲ្យសាក្សីឆ្លើយ ហើយខ្ញុំពន្យល់ថាឲ្យថាបញ្ហានេះសំខាន់ ហើយចម្លើយរបស់គាត់ក៏សំខាន់ ពីព្រោះថាម្សិលមិញ គឺថាមុននឹងមានការបោសសម្អាតនេះ គឺថាមានមូលហេតុ គឺថាការបញ្ជូនសាក្សីរូបនេះទៅក្រសួងការបរទេសបាទ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសូមជម្រាបមេធាវីថា អង្គជំនុំជម្រះមិនបណ្តែតបណ្តោយឲ្យភាគី ដែលពាក់ព័ន្ធនឹងរឿងក្តីនេះឡើងធ្វើអត្ថាធិប្បាយដោយចំណាយពេលដែលអង្គជំនុំជម្រះផ្តល់ឲ្យ ដើម្បីតាំងសំណួរ

ដេញដោលដល់សាក្សី ដែលធ្វើអត្ថាធិប្បាយឯណាវែងអន្លាយនោះទៀតឡើយ។

អង្គជំនុំជម្រះប្រកាសផ្អាក! សម្រាកត្រឹមនេះ!

ហើយអង្គជំនុំជម្រះនឹងចាប់ផ្ដើមបន្តធ្វើនៅវេលាម៉ោងដប់មួយ។ មន្ត្រីរដ្ឋបាលតុលាការសម្រប សម្រួលផ្ដល់កន្លែងសម្រាកសមរម្យសម្រាប់សាក្សីរូបនេះ ហើយនិងឲ្យអញ្ជើញគាត់ឲ្យមកកន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះនៅវេលាម៉ោងដប់មួយ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១០:៣៩ នាទី ដល់ម៉ោង ១១:០២ នាទី)*

[១១:០២:៣៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។

មុននឹងផ្ដល់វេទិកាទៅឲ្យក្រុមមេធាវីការពារក្ដីលោក នួន ជា ដើម្បីមានឱកាសតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ អង្គជំនុំជម្រះសូមធ្វើការកត់សម្គាល់ចំពោះក្រុមមេធាវីការពារក្ដី នួន ជា។ ជាពិសេសមេធាវី-- ដោយឡែក គឺមេធាវីការពារក្ដី ផេសមិន ក្នុងអំឡុងពេលព្រឹកមិញនេះ គឺគាត់រឹងរូសមិនស្ដាប់នូវសេចក្ដីបង្គាប់របស់ប្រធានអង្គជំនុំជម្រះម្ដងហើយម្ដងទៀត។ ហើយបញ្ហានេះអង្គជំនុំជម្រះធ្វើការកត់សម្គាល់ ហើយសូមជម្រាបលោកក្រុមមេធាវីការពារក្ដី នួន ជា ថាសូមលោកតាំងសំណួរដេញដោលឲ្យចំនូវបញ្ហា ហើយជៀសវាងនូវការប្រព្រឹត្តដូចព្រឹកមិញនេះ។ ប្រសិនបើលោកអស់សំណួរ គឺលោកប្រាប់យើង គឺលោកប្រាប់យើង ថាយើងអស់សំណួរសារធាតុក្នុងការតាំងសំណួរចំពោះសាក្សីរូបនេះហើយ ដើម្បីសន្សំសំចៃពេលវេលា ផ្ដល់ពេលវេលានោះជូនទៅក្រុមមេធាវីការពារក្ដីដទៃទៀត ដើម្បីអនុវត្តសិទ្ធិក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីឲ្យមាន ឲ្យបានឆាប់រហ័សនិងមានប្រសិទ្ធភាព។ ទីពីរ យើងបានសូមរំឭកឡើងវិញថា យើងនឹងខិតខំគ្រប់គ្រងកិច្ចដំណើរការសវនាការនេះ ឲ្យប្រព្រឹត្តទៅដោយឆាប់រហ័សនិងមានប្រសិទ្ធភាព។ មិនអនុញ្ញាតឲ្យភាគីដែលពាក់ព័ន្ធ គឺឡើងធ្វើសេចក្ដី

សន្និដ្ឋាន ឬក៏ធ្វើសេចក្ដីថ្លែងការណ៍នូវបញ្ហាផ្សេងៗអូសវែងអន្លាយនៅក្នុងរឿងក្ដីនេះទេ។

[១១:០៤:២៩]

ដំណាក់កាលនេះ គឺដំណាក់កាលនៃកិច្ចដំណើរការតាំងសំណួរដេញដោលចំពោះសាក្សី ចំពោះអង្គហេតុទាំងឡាយដែលកើតមានឡើងនៅ-- និងពាក់ព័ន្ធទៅនឹងបណ្ដាលកថាខណ្ឌនៃសំណុំរឿង002/01 ហើយករណី លើកលែងតែករណីខ្លះដែលអាចពាក់ព័ន្ធទៅនឹងសំណុំរឿង០០២ទាំងមូល ដែលអង្គជំនុំជម្រះនឹងជម្រាបជូនភាគីពាក់ព័ន្ធជាក្រោយ ទៅតាមករណីសមស្រប ឬករណីជាក់ស្ដែងនៃអ្នកដែលផ្ដល់សក្ខីកម្ម ពាក់ព័ន្ធនឹងវិសាលភាពទូលំទូលាយនៃសំណុំរឿង០០២ តែប៉ុណ្ណោះ។

បាទ សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិនៈ**

សូមអរគុណច្រើនលោកប្រធានចំពោះកំណត់សម្គាល់របស់លោកប្រធាន ប៉ុន្តែដើម្បីប្រតិចារឹក ខ្ញុំសូមលើកឡើងនៅមុនសម្រាក គឺថា លោកបាន-- លោកប្រធានបានហាមឃាត់ខ្ញុំមិនឱ្យសួរសំណួរដើម្បីស្វែងរកឃើញនូវភាពគួរឱ្យជឿទុកចិត្តបានទៅលើសាក្សីរូបនេះ។ ហើយនេះជាសិទ្ធិរបស់កូនក្ដីរបស់យើងខ្ញុំក្នុងការសួរ ស្វែងរកឱ្យឃើញនូវភាពគួរឱ្យជឿទុកចិត្តបាន។ ទាក់ទងទៅនឹងអ្វីដែលលោកប្រធានបានលើកឡើងថា ខ្ញុំមានភាពរឹងរូស ខ្ញុំគិតថា អាកប្បកិរិយានេះមិនមែនជា អាកប្បកិរិយាមួយអាក្រក់សម្រាប់មេធាវីការពារក្ដីនោះទេ។--

[១១:០៦:១០]

**ប្រធានអង្គជំនុំៈ**

យើងមិនអនុញ្ញាតឱ្យលោកធ្វើសេចក្ដីថ្លែងការណ៍អ៊ីចឹងទេ យើងបានប្រាប់ហើយអម្បាញ់មិញ។ ពេលវេលា គឺឱ្យលោកសួរទៅសាក្សីអំពីសារធាតុ សំណួរសារធាតុដែលពាក់ព័ន្ធនឹងអង្គហេតុ។ យើងបានប្រាប់ហើយអំមិញ។ ប្រសិនបើលោកនៅតែបន្តនូវស្ថានភាពដែលមិនពាក់ព័ន្ធចូលទៅក្នុងថា សំណួរសារធាតុពាក់ព័ន្ធនឹងអង្គហេតុទៀតទេនោះ អង្គជំនុំជម្រះនឹងចាត់ទុកថា លោកអស់សំណួរសារធាតុក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះទៀតហើយ។ អង្គជំនុំជម្រះនឹងបញ្ឈប់លោកក្នុងការតាំងសំណួរសាក្សី ចំពោះសាក្សីរូបនេះ ហើយនិងអង្គជំនុំជម្រះនឹងផ្ដល់ពេលវេលាទៅក្រុមមេធាវីការពារក្ដីដទៃទៀត ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

[១១:០៧:០០]

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ខ្ញុំមានសំណួរផ្សេង និងប្រធានបទផ្សេងទៀតដែលត្រូវបន្ត ហើយខ្ញុំនឹងរួតរះ។ ខ្ញុំចង់បង្ហាញឯកសារមួយទៅសាក្សី វាគឺនិយាយអំពីអង្គការលេខ ដែលគេបានដឹងជាទូទៅទៅហើយ គឺឯកសារ D91/22 និយាយអំពីរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស។ ខ្ញុំសូមការអនុញ្ញាតពីអង្គជំនុំជម្រះដើម្បីបង្ហាញឯកសារនេះនៅលើអេក្រង់ និងខ្ញុំក៏មានឯកសារថតចម្លងសម្រាប់ជូនសាក្សីផងដែរ។

[១១:០៧:៥៤]

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត!

**សួរដោយលោក ម៉ៃខល ផេសមិន៖**

**ស៖** ដំបូងបំផុត គឺលោកសាក្សី គឺយើងមានប្រអប់ក្រហម ប្រអប់ពណ៌ក្រហមដែលព័ទ្ធជុំវិញឈ្មោះ គាត ឈន់ ហៅ មុត។ តើឈ្មោះនេះជាឈ្មោះរបស់បុគ្គលដែលលោកសាក្សីបានលើកឡើងពីម្សិលមិញមែនឬទេ? នៅពេលដែលលោកនិយាយអំពីដំណើរទស្សនកិច្ចរបស់សាស្ត្រាចារ្យ ខាត់វែលនេះមកកាន់ទីក្រុងភ្នំពេញ លោកចាំទេ លោកបានលើកឡើងអំពីឈ្មោះរបស់គាត់ម្សិលមិញនេះ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ឈ្មោះដែលខ្ញុំបានលើកឡើងមូលហេតុវាទាក់ទងដល់ ឃើញក្នុងខ្លឹមសារដែលថារាយការណ៍ជូនតាមថ្នាក់លើ ហើយមានឈ្មោះខ្ញុំ និងមានឈ្មោះ មុត។ ដល់អ៊ីចឹងទៅ ឈ្មោះក្នុងក្រសួងពេលនោះ ដែលទាក់ទិននឹងជូនភ្ញៀវតាមក្រុមក៏មានឈ្មោះ មុត ហ្នឹងដែរ។ ហើយក៏ឃើញចុះហត្ថលេខាដោយវែអក្សរពុម្ពថាមាន កន ហើយមាន មុត។ អ៊ីចឹងខ្ញុំឃើញថា មុត ហ្នឹងមានតែឈ្មោះឯកឧត្តម គាត ឈន់ ហ្នឹងហើយបាទ។ ហើយភ្ជាប់ហ្នឹងដែរ ក៏ជាឱកាសដែលដើម្បីកុំឲ្យភ័ន្តច្រឡំ ខ្ញុំក៏មានបញ្ជាក់មួយម៉ាត់ទៀតថា ខ្ញុំដឹងថាមានក្រុមជូនភ្ញៀវមួយទៀត ដោយឈ្មោះបងប្រាសិទ្ធ។ បាទ ខ្ញុំខ្លាចច្រឡំ ព្រោះបងប្រាសិទ្ធ នេះ បើឃើញជាឈ្មោះនេះនោះ ក៏មានឈ្មោះថា ជួន ប្រាសិទ្ធ។ អ៊ីចឹងក្រែងច្រឡំទៅខាងក្រៅ អ្នកផ្សព្វផ្សាយអីទៅ ខ្ញុំទៅជាអ្នកដែលមានមតិខុស។ អ៊ីចឹង ចង់បញ្ជាក់ប៉ុណ្ណឹងបាទ។ អស់។

**ស៖** សូមអរគុណលោកសាក្សី។ តើលោក គាត ឈន់ មានមុខងារជាអ្វីដែរ នៅក្រសួងការ

បរទេសនេះ?

**ឆ៖** បាទ សូមឆ្លើយ មុខងារច្បាស់លាស់ជាមូលដ្ឋាន ខ្ញុំមិនដឹងដែរទេ តែដែលខ្ញុំឃើញម្តងម្កាលហ្នឹង គាត់ជាអ្នកបកប្រែៗ ភាសា ហើយជាអ្នកចូលរួមទទួលភ្ញៀវ។ ឯរចនាសម្ព័ន្ធច្បាស់ថា ជាស្អីខ្ញុំមិនដឹងទេបាទ។

[១១:១២:០២]

**ស៖** សូមអរគុណ។ តួនាទីទីមួយរបស់គាត់ គឺធ្វើការកត់ត្រាក្នុងកិច្ចប្រជុំសំខាន់ៗ។

**ឆ៖** លោកចង់សួរថាម៉េច? ខ្ញុំមិនយល់បាទ។

**ស៖** លោកសាក្សីថាតើលោកដឹងថា លោក គាត ឈន់ ក៏មានតួនាទីកត់ត្រានៅក្នុងកិច្ចប្រជុំសំខាន់ៗផងដែរឬទេ?

**ឆ៖** សូមឆ្លើយ ខ្ញុំឃើញជាទូទៅ គឺអ្នកដែលមានសមត្ថភាពខាងភាសា សមត្ថភាពខាងកត់ត្រាឃើញច្រើនគ្នា មិនមានឃើញតែលោក គាត ឈន់ មួយទេ ហ្នឹងទីមួយ។ ហើយទីពីរ បើកត់ត្រាអីសំខាន់ៗ ខ្ញុំក៏មិនដឹងដែរ ពីព្រោះមានក្របខ័ណ្ឌចង្អៀត។ នេះសូមឆ្លើយជូនប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមលើកឈ្មោះរបស់បុគ្គលម្នាក់ទៀត នៅក្នុងអង្គការលេខនេះ គឺលោកឃើញទេ នៅមុខលោកនេះ។ គឺមនុស្សម្នាក់ទៀត ដែលមានឈ្មោះថា ហោ ណាំហុង ហើយតាមដែលខ្ញុំយល់នោះ គឺថាដំបូង គាត់ជាឯកអគ្គរដ្ឋទូតប្រចាំប្រទេសគុយបា ហើយក្រោយមក យោងទៅតាមអង្គការលេខនេះ គឺថាគាត់បានផ្ទេរមកកាន់មន្ទីរប-៣២។ មន្ទីរប-៣២ នេះ គឺជាផ្នែកមួយនៃបឹងត្របែក។ លោកសាក្សី ថាតើលោកដឹងថា ហោ ណាំហុង ជាប្រធាននៅជំរំបឹងត្របែកនោះដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីកុំអាលទាន់ឆ្លើយ! ចាំរង់ចាំស្តាប់អង្គជំនុំជម្រះសម្រេច ឥឡូវនេះមានការជំទាស់ពីមេធាវីអ៊ំ! ពីតំណាងសហព្រះអាជ្ញាអន្តរជាតិក្នុងការតាំងសំណួរនេះ។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទ អរគុណលោកប្រធាន។ នេះគឺជាសំណួរនាំមុខ ហើយគឺថាមានព័ត៌មានបីនៅក្នុងហ្នឹង នៅក្នុងសំណួរហ្នឹង។ មួយ គឺអតីតកាលរបស់លោក ហោ ណាំហុង ហើយចំណុចទីពីរ គឺថាគាត់ធ្វើការនៅប-៣២ ដែលមាននៅក្នុងតារាងនេះ ហើយបន្ទាប់មកទៀត ព័ត៌មានមួយទៀត គឺថាគាត់ជាប្រធានប-

៣២។ ខ្ញុំគិតថា នេះជាសំណួរនាំមុខ អ៊ីចឹងត្រូវសួរជាដំណាក់ៗ ហើយធ្វើសួរ ថាតើគាត់ស្គាល់ ហោ ណាំហុង ឬអត់? ហើយនៅប-៣២ ឬហើយក្រោយមកធ្វើជាប្រធានប-៣២ អីអ៊ីចឹង។ សូមអរគុណ។

[១១:១៥:៥៨]

**លោក ម៉ែខល ផេសមិន៖**

ខ្ញុំនឹងរៀបសំណួរខ្ញុំឡើងវិញ។

**សួរដោយលោក ម៉ែខល ផេសមិន៖**

**ស៖** លោកសាក្សី តើលោកបានដឹងអំពីតួនាទីរបស់លោក ហោ ណាំហុង ដែរឬទេ នៅមន្ទីរបឹងត្របែកនោះ?

**លោក នី កន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ គឺទីមួយ ខ្ញុំមិនស្គាល់លោក ហោ ណាំហុង ទេ។ ទីពីរ តាមរយៈមិនស្គាល់ក៏មិនជាតួនាទីយ៉ាងម៉េចដែរ។ សរុបទៅគឺ មិនដឹង មិនស្គាល់។

**ស៖** លោកសាក្សី រហូតមកដល់ចុងបញ្ចប់នៃរយៈពេលរបស់កម្ពុជាប្រជាធិបតេយ្យបក្សកុម្មុយនីស្តកម្ពុជា គឺឆ្នាំ១៩៧៨ គឺលោក ហោ ណាំហុង រស់នៅក្នុងវីឡាមួយជិតវិមានឯករាជ្យ តើលោកដឹងទេ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយនឹងសំណួរនេះទេ ព្រោះសាក្សីអត់ស្គាល់ ហើយអត់ដឹង អត់ស្គាល់លោក ហោ ណាំហុង ផង ហើយអត់បានដឹងអំពីមុខងារ អំពីបញ្ហាពាក់ព័ន្ធនឹង ហោ ណាំហុង ទេ។

លោកមេធាវីអាចតាំងសំណួរផ្សេង សំណួរពាក់ព័ន្ធនឹងបុគ្គលនេះ ចំពោះសាក្សីរូបនេះមិនអាចបន្តការសួរដេញដោលបានទេ ព្រោះសាក្សីមិនស្គាល់ឈ្មោះ ហោ ណាំហុង នេះទេ។

[១១:១៨:០០]

**លោក ម៉ែខល ផេសមិន៖**

លោកប្រធាន មុនខ្ញុំបន្តទៅទៀត ខ្ញុំសូមបញ្ជាក់ថា ការដែលសាក្សីឆ្លើយថា មិនស្គាល់បុគ្គលរូបនេះគឺ មិនប្រាកដថា មិនដឹងថា បុគ្គលរូបនេះរស់នៅទីណានោះទេ។

ខ្ញុំសូមចូលប្រធានបទមួយផ្សេងទៀត។ ខ្ញុំចង់បង្ហាញជូនសាក្សី នូវឯកសារមួយ ឯកសារលេខ D366/7.1.473 ហើយខ្ញុំក៏មានឯកសារថតចម្លង សម្រាប់ជូនសាក្សីផងដែរ។ ហើយមន្ត្រីគ្រប់គ្រង

សំណុំរឿងរបស់យើងខ្ញុំ ក៏បានបង្ហាញនៅលើអេក្រង់នេះ។

**ប្រធានអង្គជំនុំ៖**

លោកមេធាវី តើលោកបង្ហាញអត្តសញ្ញាណឯកសារ និងបង្ហាញអំពីនីតិវិធីនៃការដាក់ឯកសារនេះចំពោះមុខអង្គជំនុំជម្រះ ស្នើសុំដាក់ជូនអង្គជំនុំជម្រះ ថាតើបានធ្វើនីតិវិធីនៃការស្នើសុំដាក់ចំពោះមុខអង្គជំនុំជម្រះហើយឬនៅ? ហើយអង្គជំនុំជម្រះបានទទួល យល់ព្រមអនុញ្ញាតឲ្យយកឯកសារនេះដេញដោលហើយឬនៅ? សូមលោកធ្វើការបញ្ជាក់អំពីបញ្ហានេះជាមុនសិន។

**លោក ម៉ៃខល ផេសមិន៖**

សូមអរគុណលោកប្រធាន។ ចម្លើយរបស់ខ្ញុំមិនដឹងថាតើឯកសារនេះមាននៅក្នុងបញ្ជីរបស់ភាគីដទៃទៀតដែលបានដាក់ជូនអង្គជំនុំជម្រះហើយឬនៅទេ? ប៉ុន្តែអ្វីដែលខ្ញុំដឹងនេះគឺ យើងខ្ញុំបានដាក់នៅលើ *អ៊ីនធើហ្វេស* នូវឯកសារជាក់លាក់នេះហើយ ដែលជាឧបសម្ព័ន្ធទៅនឹងសំណើដែលយើងខ្ញុំបានដាក់ជូននៅរសៀលថ្ងៃចន្ទនោះ។

*(ចៅក្រមពិភាក្សាគ្នា)*

[១១:២១:០៤]

**ប្រធានអង្គជំនុំ៖**

បាទ ឲ្យបុគ្គលិកជំនួយការដកឯកសារនេះចេញវិញសិន។ ហើយអង្គជំនុំជម្រះ-- អង្គជំនុំជម្រះសូមជម្រាបជូនទៅមេធាវីការពារក្តីលោក នួន ជា ថាការដែលលោកយកឯកសារណាមួយ យកមកដាក់ត្រឹមតែ*អ៊ីនធើហ្វេស*នោះ វាមិនគ្រប់គ្រាន់តាមកិច្ចដំណើរការនីតិវិធី ដែលអនុវត្តនៅទីនេះទេ។ អង្គជំនុំជម្រះបានណែនាំអំពីការអនុវត្តក្នុងការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះហ្នឹងច្រើនលើក ច្រើនសាហើយ គឺរួមទាំងការសម្រេចដោយផ្ទាល់មាត់ចំពោះឯកសារកន្លងមក ហើយរួមទាំងខ្លឹមសារនៃលិខិតជម្រាបជូនទៅភាគី ដែលពាក់ព័ន្ធនឹងបញ្ហានេះ អំពី-- ចុះថ្ងៃទី២៤ ខែឧសភា ឆ្នាំ២០១២ ផង។

ចំពោះឯកសារដែលមិនបានស្នើសុំដាក់ដេញដោលដោយភាគី ដែលមានបញ្ជីនៅក្នុងបញ្ជីឯកសារហើយអង្គជំនុំជម្រះបានសម្រេចទទួលយកកន្លងមកទីនោះ គឺភាគីដែលពាក់ព័ន្ធដែលមានបំណងចង់ដាក់ឯកសារប្រភេទនេះ ត្រូវអនុវត្តទៅតាមនីតិវិធី គឺវិធាន៨៧(៤) នៃវិធានផ្ទៃក្នុង ដើម្បីអង្គជំនុំជម្រះមានពេលវេលា និងមានពេលការពិចារណាសម្រេចពីបញ្ហានេះជាមុន។ ហើយអម្បាញ់មិញនេះ លោកបានបង្ហាញច្បាស់លាស់ហើយ លោកគ្មានមូលដ្ឋានអ្វីក្នុងការស្នើសុំដាក់ឯកសារនេះដេញដោលចំពោះមុខ

អង្គជំនុំជម្រះ ដោយអនុវត្តតាមនីតិវិធីនៃវិធាន ៨៧(៤) ដូចសេចក្ដីណែនាំកន្លងមកទេ ដូចវិធានផ្ទៃក្នុងដែលបានកំណត់ទេ។ ដូច្នេះ អង្គជំនុំជម្រះមិនអនុញ្ញាតឲ្យលោកយកឯកសារនេះមកតាំងសំណួរ-- ជាមូលដ្ឋានក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីនេះទេ។

[១១:២៣:០៦]

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន យើងខ្ញុំបានដាក់សំណើសុំកាលពីថ្ងៃចន្ទហើយ ដែលក្នុងនោះរួមមានទាំងពីសំណើសុំឲ្យយើងខ្ញុំបានប្រើប្រាស់នូវឯកសារជាក់លាក់នេះ ដែលយើងខ្ញុំបានដាក់នៅលើ*អ៊ីនធើហ្វេស*រួចហើយនោះ។ ប៉ុន្តែខ្ញុំបានដឹងថា យើងខ្ញុំបានទទួលអ៊ីម៉ែលមួយ ហើយលោកប្រធានតើត្រូវឲ្យខ្ញុំបន្តទៅទៀតឬក៏យ៉ាងណា?

**ប្រធានអង្គជំនុំ៖**

ម្ដងហើយម្ដងទៀត គឺគាត់នៅតែប្រកាន់-- នៅតែប្រព្រឹត្តអាកប្បកិរិយាដូច្នេះ អង្គជំនុំជម្រះបានសម្រេចរួចហើយលើបញ្ហានេះ។ បញ្ហាអ្វីទៀត ដែលអង្គជំនុំជម្រះបានសម្រេចរួចហើយ ក្នុងករណីលោកមិនសុខចិត្ត លោកអាចប្ដឹងសាទុក្ខទៅតុលាការកំពូលបាន តាមនីតិវិធីចំពោះឯកសារ ឬសេចក្ដីសម្រេចរបស់សាលាដំបូងឯណាដែលលោកមានសិទ្ធិនៅក្នុងការប្ដឹងសាទុក្ខទៅតុលាការកំពូល។

[១១:២៤:០៣]

ឥឡូវនេះ តើលោកមានទំនងមានសំណួរសារធាតុផ្សេងទៀតទេលើក្នុងការតាំងសំណួរសាក្សីនេះ? យើងបានប្រាប់ហើយអំមិញ ប្រសិនបើលោកនៅតែបង្កបញ្ហានៃការធ្វើឲ្យប៉ះពាល់នូវកិច្ចដំណើរការនីតិវិធីក្នុងការបង្កើនល្បឿន ក្នុងការដេញដោលនេះ យើងចាត់ទុកថាលោកអស់សំណួរសារធាតុ យើងនឹងបញ្ឈប់លោកក្នុងការសួរដេញដោលសាក្សីរូបនេះ។ យើងនឹងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្ដីផ្សេងទៀត។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមិនទាន់អស់សំណួរនៅឡើយទេ។ ប៉ុន្តែខ្ញុំនៅតែយល់ថា ខ្ញុំបានដាក់សំណើសុំ ដើម្បីឲ្យយើងខ្ញុំបានប្រើប្រាស់ឯកសារនេះនៅថ្ងៃចន្ទនោះ។ តែតាមដែលខ្ញុំដឹងគឺថា មន្ត្រីច្បាប់ជាន់ខ្ពស់ គឺថាគាត់បានឆ្លើយតបទៅនឹងសំណើនេះរួចវិញហើយ។

**ប្រធានអង្គជំនុំ៖**

យើងបានសម្រេចរួចហើយបញ្ហាហ្នឹងណា! ឥឡូវនេះយើងបានសម្រេចរួចហើយ។ អម្បាញ់មិញនេះ ថែមទៀត។ លោកត្រូវប្រឹងប្រែងធ្វើការងារឲ្យបានពេញលេញតាមដែលអាចធ្វើទៅបាន គឺលៃលកពេលតាមសេចក្តីណែនាំ គឺលៃពេលវេលាសមស្របសម្រាប់អង្គជំនុំជម្រះក្នុងការពិនិត្យពិចារណាសម្រេចផងដែរ។ ហើយការដាក់ឯកសារត្រូវដាក់ជាក់ច្បាស់ជូនមកអង្គជំនុំជម្រះតាមនីតិវិធីដែលធ្លាប់អនុវត្តពីមុន ចំពោះឯកសារដែលដាក់ក្នុង*អ៊ីនធើហ្វេស* ជាប្រភេទឯកសារដែលគ្រោងក្នុងការសួរដេញដោលនៅពេលខាងមុខ។ ចំណែកឯពាក្យសំណើសុំដាក់ឯកសារដែលថ្មី ដែលខ្លួនមិនបានស្នើសុំពីមុន គឺត្រូវធ្វើតាមនីតិវិធីដែលបានអនុវត្តកន្លងមក។

លោកបន្តទៅសំណួរផ្សេងទៀត ដែលមិនពាក់ព័ន្ធទៅនឹងឯកសារ ដែលអង្គជំនុំជម្រះបានសម្រេចមិនអនុញ្ញាតឲ្យលោកលើកយកឯកសារនោះមកធ្វើមធ្យោបាយ ធ្វើជាមូលដ្ឋានក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក ម៉ៃខល ផេសមិន៖**

ខ្ញុំមានភាពច្របូកច្របល់បន្តិចគឺថា យើងខ្ញុំបានដាក់សំណើគឺថា ឯកសារនេះមិនមានតែ--មិនត្រឹមតែមាននៅក្នុង*អ៊ីនធើហ្វេស* ទេ ក៏ជាឧបសម្ព័ន្ធនៃសំណើនោះផងដែរ។

[១១:២៦:២៧]

**ប្រធានអង្គជំនុំ៖**

អស់ពេលហើយ លែងឲ្យលោកសួរទៀតហើយ។ អង្គជំនុំជម្រះប្រគល់វេទិកាជូនទៅមេធាវីការពារក្តីលោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

សូមអញ្ជើញលោកមេធាវី!

**លោក ម៉ៃខល ផេសមិន៖**

លោកប្រធាន ខ្ញុំមិនទាន់អស់សំណួរនៅឡើយទេ។

**ប្រធានអង្គជំនុំ៖**

អស់ហើយ បញ្ឈប់លែងឲ្យលោកតាំងសំណួរដេញដោលចំពោះសាក្សីនេះទៀតហើយ។ យើងសម្រេចប្រគល់វេទិកានេះឲ្យទៅក្រុមមេធាវីការពារក្តីអៀង សារី ដើម្បីបន្តការតាំងសំណួរដេញដោល។

សូមលោកអង្គុយចុះ!

[១១:២៧:២៣]

យើងប្រាប់ហើយថាអំមិញយើងមិនឲ្យ អនុញ្ញាតឲ្យអ្នកឯងយកវេទិកាពេលវេលាដែលកំណត់ឲ្យសួរដេញដោលនូវសំណួរសារធាតុចំពោះសាក្សីនេះទៅធ្វើសេចក្ដីថ្លែងការណ៍អ្វីផ្សេងទៀតទេ។ បើលោកមានបំណងនៅក្នុងការធ្វើអ្វីផ្សេងទៀត ដែលមានលក្ខណៈវែងអន្លាយ លោកអាចធ្វើសំណើសុំជាលាយលក្ខណ៍អក្សរមកអង្គជំនុំជម្រះតាមនីតិវិធី ដែលបានអនុវត្តកន្លងមក។

សូមអញ្ជើញលោកមេធាវីការពារក្ដីលោក អៀង សារី!

[១១:២៨:២០]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន សូមគោរពលោក លោកស្រីចៅក្រម។ សួស្ដីសហភាតា! សួស្ដីលោកអ្នកទាំងឡាយដែលចូលរួមសវនាការនេះ ទោះនៅក្នុងបន្ទប់ ឬក្រៅបន្ទប់ក្ដី។

សួស្ដីលោក នី កន! ខ្ញុំ អាង ឧត្តម ជាសហមេធាវីរបស់លោក អៀង សារី។ នៅពេលនេះស្នើសុំសួរសំណួរលោកមួយចំនួន។

សំណួររបស់ខ្ញុំជាបឋម គឺពាក់ព័ន្ធទៅនឹងរចនាសម្ព័ន្ធ ឬអង្គការលេខដែលលោកមាននៅនឹងដៃស្រាប់។ ហើយសំណួររបស់ខ្ញុំមិនច្រំដែល ហើយជាសំណួរថ្មី។ អាស្រ័យហេតុនេះ ខ្ញុំស្នើសុំលោកប្រធានមេត្តាអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើកញ្ចក់ទូរទស្សន៍ ដើម្បីឲ្យខ្ញុំបាទបានពិភាក្សាជាមួយលោកសាក្សី។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាត! សូមបញ្ជាក់អត្តសញ្ញាណឯកសារផង ដើម្បីជាប្រតិចារឹក។

**លោក អាង ឧត្តម៖**

លេខ D91/22។

[១១:២៩:៥៣]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** លោក នី កន បើផ្អែកតាមប្រតិចារឹករបស់លោក ដែលមាននៅក្នុងចម្លើយរបស់លោកប៉ុន្មានថ្ងៃចុងក្រោយនេះ លោកបាន-- ហើយទាក់ទងនឹងរឿង អ្ហឹ! ក្របខ័ណ្ឌការងារនៅក្រសួងការបរទេស លោកបានអះអាងថា លោកត្រូវបានគេដាក់ចូលនៅក្នុងប្រអប់មួយ ហៅថាប្រអប់ពិធីការ

ហើយមេរបស់លោក គឺលោក ជាម។ បានន័យថា លោកជាកូនចៅលោក ជាម។ តើលោកនៅរក្សាចម្លើយនេះដដែលឬទេ?

**ឆ៖** សូមបញ្ជាក់ជូនទីមួយ ខ្ញុំជាបុគ្គលមួយដែលទទួលតួនាទីខាង ទទួលមួយផ្នែកតូច ខាងជូនភ្ញៀវ ទីមួយ។ ហើយទីពីរ លោក ជាម ជាប្រធានមន្ទីរ។ ដូច្នេះ ខ្ញុំទទួលការណែនាំអ្វីៗដែលទាក់ទងដល់ការងារហ្នឹងតាមរយៈលោក ជាម បាទ។

**ស៖** សូមអរគុណ។ បើផ្អែកទៅតាមប្រតិចារឹក នៅក្នុងការផ្តល់សក្ខីកម្មរបស់លោក ចុះថ្ងៃទី២៩។ ហើយនៅក្នុងទំព័រជាភាសាខ្មែរ បន្ទាត់ទី១៤ និង១៥ អត់មានជាភាសាអង់គ្លេសបារាំងទេ។ ខ្ញុំសូមអានជូនលោកនូវសំណួរ និងចម្លើយ។ ពេលនោះគេសួរលោកថា "តើអ្នកណាជាប្រធានផ្ទាល់របស់លោកនៅក្រសួងការបរទេស?" ហើយលោកបានឆ្លើយថា៖ "ប្រធានហ្នឹង គឺប្រធានមន្ទីរហ្នឹងហើយ។ ហើយប្រធានមន្ទីរហ្នឹង តាមខ្ញុំចាំ ដែលមកប្រគល់ការងារឲ្យខ្ញុំហ្នឹង គឺពេលនោះ ហៅឈ្មោះ ជាម បាទ"។ អ៊ីចឹងលោកនៅរក្សាចម្លើយនេះថា លោក ជាម ដែលជាប្រធានមន្ទីរហ្នឹង គឺជាប្រធានផ្ទាល់របស់លោក? តើលោកនៅរក្សាចម្លើយអ៊ីចឹងទេ?

[១១:៣៣:២៥]

**ឆ៖** បាទ សូមបញ្ជាក់ គឺដូចខ្ញុំបញ្ជាក់អំមិញដដែល ដូចខ្ញុំថាខ្ញុំទទួលការណែនាំផ្ទាល់ពីលោក ជាម ដដែលបាទ។

**ស៖** បាទ សូមអរគុណ។ ហើយលោកក៏បានមានប្រសាសន៍ទៀតថា លោកទទួលការណែនាំបញ្ជាពីលោក ជាម។ ម្យ៉ាងវិញ លោកបានបញ្ជាក់នៅក្នុងសវនាការហើយថា ពេលរាយការណ៍ក៏លោករាយការណ៍ទៅលោក ជាម ផ្ទាល់ដែរ។ តើលោកនៅរក្សាចម្លើយនេះទេ?

**ឆ៖** សូមបញ្ជាក់ជូន គឺកិច្ចដំណើរការកន្លងទៅ គឺតាមលំដាប់លំដោយអ៊ីចឹង គឺថាពេលខ្ញុំជូនភ្ញៀវត្រឡប់មកវិញ ដល់ក្រសួងហ្នឹង គឺខ្ញុំប្រគល់ជូនលោក ជាម ហើយក្នុងលទ្ធផលនៃការជូនភ្ញៀវក៏រាយការណ៍ជូនលោក ជាម។ ឯលោក ជាម ត្រូវបន្តទៅទៀត។ អាហ្នឹងជាភារកិច្ចរបស់គាត់បាទ។

**ស៖** សូមអរគុណ។ អ៊ីចឹងបើយើងពិនិត្យមើលទៅអង្គការលេខ ឬរចនាសម្ព័ន្ធដែលមាននៅក្នុងដៃ និងនៅមុខលោកស្រាប់។ វាអាចប្រាប់ទូទៅថា លោក ជាម ហើយនិងខ្លួនលោកផ្ទាល់ គឺលោក នី កន វានៅនឹងជួរស្មើគ្នា វាអាចប្រាប់ថាតួនាទី ភារកិច្ច ការទទួលខុសត្រូវរបស់លោក ឬក៏រវាងលោក និងលោក ជាម វាស្មើគ្នា ឬក៏វាដូចគ្នា។ តើលោកយល់ថារចនាសម្ព័ន្ធនេះវាឆ្លើយតប វាត្រឹមត្រូវ វាទៀត

ទាត់ទៅលើការពិតរបស់លោកដែរឬទេ?

**ឆ៖** សូមឆ្លើយជូន ខ្ញុំបញ្ជាក់សាចុះសាឡើង វាដដែល ដែលនាំឲ្យលោកតាមមិនទាន់។ គឺខ្ញុំជម្រាបថា ពេលនោះតួនាទីខ្ញុំជាតួនាទីមួយផ្នែកនៃពិធីការ ហើយខ្ញុំត្រូវដកហូតមកដាក់កន្លែងនេះ ហេតុផលយ៉ាងម៉េចមិនដឹង គ្រាន់ថាចេះអក្សរ ចេះលេខ។ រួចហើយមកក៏ទទួលការណែនាំពីលោក ជាម។ ដូច្នេះមិនបានឃើញការប្រកាសថាខ្ញុំស្មើលោក ជាម ឬយ៉ាងណានោះ គ្មានទេ។ ហើយការពិតវិញ គឺខ្ញុំមិនអាចដល់ថ្នាក់លោក ជាម ទេ។ ទើបតែឃើញរចនាសម្ព័ន្ធដែលខាងណា ខាងណីមកធ្វើនៅនេះ ដាក់លេខដាក់អីទៅ វាស្មើនឹងលោក ជាម។ តែការប្រត្តិបត្តិជាក់ស្តែងអ្វីដែលមិនមែន ខ្ញុំមិនទទួលបានទេ។ បើវាមិនមែន វាមិនជាក់ស្តែង។ កម្រិតខ្ញុំទាបណាស់ ខ្ញុំមិនអាចទៅស្តាប់ការប្រជុំអីសំខាន់ៗជាមួយលោក ជាម បាទ។ បើនិយាយឲ្យចំ ខ្ញុំក្រៅបន្ទប់ទេ។ ទទួលការងារហ្នឹងហើយ លោក ជាម មកណែនាំ។ ដូច្នេះសរុបទៅ គឺឋាន:ខ្ញុំមិនស្មើលោក ជាម ទេ បាទ។

[១១:៣៧:៥០]

**ស៖** សូមអរគុណ។ អ៊ីចឹងលោកអាចសរុប សន្និដ្ឋានសរុបសេចក្តីបានថា ទេថារចនាសម្ព័ន្ធ ឬអង្គការលេខហ្នឹងវាត្រូវ ឬវាខុសសម្រាប់លោក?

**ឆ៖** ដូចខ្ញុំបញ្ជាក់ហើយ គឺថាខ្ញុំទើបតែឃើញចៅក្រមស៊ើបអង្កេតយករចនាសម្ព័ន្ធនេះមកឲ្យខ្ញុំមើល។ រួចអក្សរអីហ្នឹងក៏ខ្ញុំមិនចេះ ហើយបញ្ជាក់អម្បាញ់មិញទៀត ថាបើលោកសួរខ្ញុំថាតើតួនាទីខ្ញុំ ឬក៏ភារកិច្ចខ្ញុំអីស្មើលោក ជាម ខ្ញុំបានឆ្លើយហើយគឺថា មិនស្មើទេ។ ដូច្នេះសរុបទៅ គឺថាមិនត្រឹមត្រូវទេ។ អត់ត្រឹមត្រូវទេ។

**ស៖** សូមអរគុណ។ ខ្ញុំសូមបន្តចូលប្រធានបទមួយថ្មីទៀត។ ខ្ញុំសូមពិភាក្សាជាមួយលោកដោយផ្អែកទៅលើកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សីរបស់លោកដែលមានឯកសារលេខ D91/22។ ខ្ញុំសូមអញ្ញាតលោកប្រធានមេត្តាបញ្ជូន ប្រគល់ឯកសារនេះដល់សាក្សី ហើយសូមអនុញ្ញាតបញ្ចាំងឯកសារនេះនៅលើកញ្ចក់ទូរទស្សន៍ផង។

[១១:៣៩:៥៦]

**ប្រធានអង្គជំនុំ៖**

ឯកសារដដែល ឯកសារនៅដដែលតើ! ឯកសារប៉ុន្មានទៅ? អត្តសញ្ញាណថ្មី? 91! D91/22 ដដែលតើឯកសារ នៅមានស្រាប់ហើយ។

**លោក អាង ឧត្តម៖**

បាទ សូមអរគុណ។ អ៊ីចឹងខ្ញុំសូមអនុញ្ញាត សូមបញ្ចាំងនៅលើកញ្ចក់ទូរទស្សន៍ផង។

**ប្រធានអង្គជំនុំ៖**

បុគ្គលិកជំនួយការដាក់បញ្ចាំងឯកសារ D91/22 នៅលើអេក្រង់ទូរទស្សន៍! ម៉េចខុសគ្នា អាចច្រឡំទេ? ឯកសារនេះអត្តសញ្ញាណយ៉ាងម៉េចទៅ?

**លោក អាង ឧត្តម៖**

សូមទោស! D91/22 ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ គឺជាកំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី។ សូមអរគុណ។

[១១:៤១:២៦]

**សួរដោយ លោក អាង ឧត្តម៖**

លោក នី កន ឆ្លើយតបទៅនឹងសំណួររបស់អ្នកស៊ើបអង្កេតពីការិយាល័យសហចៅក្រមស៊ើបអង្កេតនៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០០៧ ដែលលោកមានឯកសារនៅនឹងដៃដែរ ហើយនិងមាននៅលើកញ្ចក់ទូរទស្សន៍ដែរ។ ជួនពេលនោះ អ្នកស៊ើបអង្កេតសួរលោកថា នេះបើយោងលើឯកសារនេះ នៅលេខខ្មែរ ERN00204132, អង់គ្លេស 007 សូមទោស! ខ្មែរម្តងទៀត។ ខ្ញុំអានម្តងទៀត 00204132, អង់គ្លេស 00702361 ដល់ 62, ភាសាបារាំង 00529342 ដល់ 43។ កាលនោះ អ្នកស៊ើបអង្កេតបានសួរលោកថា នៅសំណួរ ឬចម្លើយទីពីរហ្នឹង។

ខ្ញុំសូមអានសំណួរ៖ “សូមលោកបញ្ជាក់អំពីមន្ត្រីការទូតខ្មែរមួយចំនួននៅពេលនោះ ត្រូវបានដកពីស្ថានទូតបរទេសមកស្រុកខ្មែរវិញ ដែលមានឈ្មោះដូចជា មាឃ ទូច ហៅ កែម ជាទូតប្រចាំនៅប្រទេសឡាវ។ លោក ហួត សម្បត្តិ និងលោក អ៊ុន លន ហៅ ណាត ជាដើម។ ក្រោយមកអ្នកទាំងនោះត្រូវបានឃុំខ្លួននៅស-២១ តើថ្នាក់ដឹកនាំក្រសួងការបរទេស បានដឹងដែរឬទេ? តើថ្នាក់លើនោះជាអ្នកណាខ្លះ?” តបទៅនឹងសំណួរនេះ លោកបានឆ្លើយថា៖ “ពេលវេលាដែលខ្ញុំធ្វើការនៅក្រសួងការបរទេសមានរយៈពេលខ្លី”។ ម្យ៉ាងទៀត លោកបានបង្ហាញអំពីរចនាសម្ព័ន្ធរបស់ក្រសួងការបរទេស។ “ខ្ញុំក៏មិនស្គាល់ឈ្មោះអ្នកទាំងនោះដែរ”។ “ដូច្នេះ ឈ្មោះមន្ត្រីការទូតប៉ុន្មានខាងលើនេះ ខ្ញុំមិនស្គាល់ទេ”។

[១១:៤៥:១៤]

“ចំពោះការចាប់ខ្លួន ការផ្លាស់ប្តូរមន្ត្រីទូត គឺថ្នាក់លើជាអ្នកសម្រេច។ ថ្នាក់លើ គឺអស់

លោកអ្នកដឹកនាំធំៗ គឺអ៊ំៗ គឺ ប៉ុល ពត ហៅ តាប៉ុល, នួន ជា ហៅ តានួន, អៀង សារី ហៅ តាវ៉ាន់ និងៗ ខៀវ សំផន។ ខ្ញុំមិនដែលបានជួបផ្ទាល់ជាមួយអស់លោកទាំងនោះទេ ពីមុនមក”។

**សៈ** សំណួររបស់ខ្ញុំទាក់ទងលើបញ្ហានេះ គឺថានៅពេលដែលកម្មាភិបាលថ្នាក់លើ ដែលលោកអះអាងនេះថា ចូលរួមប្រជុំដើម្បីសម្រេច។ តើលោកបានចូលរួមប្រជុំជាមួយអស់លោកទាំងអស់នោះទេ?

**ឆៈ** សូមឆ្លើយ គឺសំណួរលោកសួរខ្ញុំ ថាតើខ្ញុំបានទៅប្រជុំជាមួយអស់លោកហ្នឹងទេ? គឺវាទាក់ទងនឹងចម្លើយខ្ញុំប៉ុន្មានថ្ងៃនេះ បន្តបន្ទាប់។ គឺខ្ញុំជាថ្នាក់ក្រោម រួចហើយថ្នាក់ផ្នែកទៀត ក្នុងរយៈកាលនោះ។ ដូច្នេះ ខ្ញុំគ្មានសមត្ថភាព-- គ្មានសិទ្ធិ គ្មានលទ្ធភាពទៅប្រជុំទេ ព្រោះថ្នាក់លើកំពូលហើយបាទ។ សូមមានមតិប៉ុណ្ណឹង។

[១១:៤៧:៣៨]

**សៈ** សូមអរគុណ។ អ៊ីចឹង លោកអាចឆ្លើយយ៉ាងខ្លី សង្ខេបថាលោកមិនធ្លាប់បានចូលរួមប្រជុំជាមួយអស់លោកនោះទេ។ សូមលោកឆ្លើយខ្លីថា ធ្លាប់ដែរ ឬមិនធ្លាប់? សូមខ្លីមួយម៉ាត់ ហើយខ្ញុំបន្តសំណួរទៀត។

**ប្រធានអង្គជំនុំៈ**

មិនបាច់ឆ្លើយទេ សំណួរនេះសាក្សីឆ្លើយរួចហើយ។ មេធាវីបន្តសំណួរថ្មីទៀត។

**លោក អាង ឧត្តមៈ**

សូមអរគុណ។

**សួរដោយលោក អាង ឧត្តមៈ**

**សៈ** ដោយសារតែលោកបានអះអាងថា មិនដែលបានចូលរួមប្រជុំជាមួយកម្មាភិបាលថ្នាក់លើទាំងអស់ហ្នឹងទេ។ ចុះចំណែក កំណត់ហេតុប្រជុំ សេចក្ដីសង្ខេបនៃកិច្ចប្រជុំ ឬរបាយការណ៍ប្រជុំ ទាំងឡាយណានោះ តើលោកដែលបានទទួលយកមកអានដោយផ្ទាល់ទេ?

**លោក នី កនៈ**

**ឆៈ** សូមឆ្លើយ សំណួរលោកសួរនេះ គឺហួសលទ្ធភាពខ្ញុំហើយ។ ការប្រជុំពិសេស ឬថ្នាក់កំពូល ឬផ្នែកក្នុងអ៊ីចឹង មិនអាចដល់ថ្នាក់ខ្ញុំបានអានអីទេបាទ។

[១១:៤៩:២០]

**លោក អាង ឧត្តម៖**

*(មិនបើកក្បាលមីក្រូហ្វូន)*

**ប្រធានអង្គជំនុំ៖**

ចុចក្បាលមេក្រូសិន សឹមនិយាយ!

**លោក អាង ឧត្តម៖**

សូមទោសបាទ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** អ៊ីចឹងដោយសារលោកអត់ដែលបានអានឯកសារដែលខ្ញុំរៀបរាប់អម្បាញ់មិញអ៊ីចឹង អំមិញហ្នឹងទេ។ ចុះលោកដែលឮអ្នកណាដទៃ ឧទាហរណ៍ ដូចជាបងប្រុសរបស់លោក លោក សុន សេន ជាដើមអ៊ីចឹង ដែលនិយាយប្រាប់លោកពីកិច្ចប្រជុំទាំងឡាយណានោះ នៅពេលខ្លះទេ?

[១១:៥០:០២]

**ឆ៖** ជាឱកាសល្អដែរដែលលោកសួរសំណួរនេះ ពីព្រោះលាក់ការណ៍សម្ងាត់នោះ ខ្ញុំបានបញ្ជាក់បន្តបន្ទាប់វាខ្ពស់ណាស់។ សូម្បីតែគ្រួសារ ក៏មិនដែលយកកិច្ចការ ការងាររបស់ផ្ទាល់ខ្លួន ឬរបស់អង្គប្រជុំមកប្រាប់ដែរ។ ដូច្នេះ ក្នុងឋានៈខ្ញុំជាប្អូន ហើយនៅឆ្ងាយ ការងារដាច់ពីគ្នា ការងារខុសគ្នា គឺគ្មានទេ បាទ។

[១១:៥០:៥៥]

**ស៖** សូមអរគុណ។ អ៊ីចឹង ដោយសារតែលោក អត់បានចូលរួមប្រជុំជាមួយនឹងកម្មាភិបាលថ្នាក់លើទាំងអស់ហ្នឹងទេ។ ឯកសារនៃកំណត់ហេតុប្រជុំ របាយការណ៍ប្រជុំ ឬសេចក្តីសង្ខេបនៃអង្គប្រជុំក៏លោកមិនដែលបានអាន ហើយក៏គ្មានអ្នកណាដែលប្រាប់លោកពីលទ្ធផលនៃកិច្ចប្រជុំរបស់កម្មាភិបាលថ្នាក់លើទាំងអស់ហ្នឹងទេ។ តើជាការត្រឹមត្រូវទេដែលយើងអាចថា វាជាការស្មានទេរបស់លោកទេ ជាការស្មានទេ ដែលលោកថា ការចាប់ខ្លួន ការផ្លាស់ប្តូរទូត គឺជាការសម្រេចរបស់ថ្នាក់លើ។ តើត្រឹមត្រូវទេដែលថា នេះជាការស្មានរបស់លោក?

**ប្រធានអង្គជំនុំ៖**

មិនបាច់ឆ្លើយនឹងសំណួរនេះទេ ពីព្រោះសំណួរនាំមុខ។ មេធាវីរៀបចំនូវសំណួរនេះឲ្យបានត្រឹមត្រូវឡើយវិញ ដើម្បីក្នុងការតាំងសំណួរនេះ ដើម្បីឲ្យសាក្សីហ្នឹងឆ្លើយតបតាមត្រឹមត្រូវ តាមនីតិវិធី។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** អ៊ីចឹងផ្អែកតាមសក្ខីកម្មរបស់លោកទាំងអស់នេះ ដែលលោកអះអាងបែបនោះ គឺលោកស្មានទេ ផ្អែកលើការស្មានរបស់លោកទេ? អ៊ីចឹងមែនទេបាទ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ឆ្លើយទេ។ សំណួរបែបនេះគឺជាសំណួរនាំមុខដដែលទេ។ សំណួរដូចគ្នានឹងសំណួរដែលបានសួររួចហើយ អង្គជំនុំជម្រះឲ្យមេធាវីកែសម្រួលក្នុងការតាំងសំណួរនេះ ឲ្យត្រឹមត្រូវជៀសវាងសំណួរបែបនាំមុខ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** សូមអរគុណ។ អ៊ីចឹង សំណួរខ្ញុំបន្តថា ទាក់ទងនឹងការអះអាងនេះ តើលោកបានទទួលព័ត៌មានដោយផ្ទាល់ពីប្រភពណាផ្សេងទៀតទេ?

[១១:៥៤:១១]

**លោក នី កន៖**

**ឆ៖** ខ្ញុំសូមឆ្លើយ។ ខ្ញុំមិនបានទទួលទេបាទ។

**ស៖** សូមអរគុណ។ អ៊ីចឹង ចំពោះចម្លើយរបស់លោក ដែលឆ្លើយចំពោះអ្នកស៊ើបអង្កេតរបស់ការិយាល័យសហចៅក្រមស៊ើបអង្កេតពេលនោះ ចម្លើយរបស់លោកដែលឆ្លើយថា "ការចាប់ខ្លួន ការផ្លាស់ប្តូរមន្ត្រីការទូត ជាការ-- ជាថ្នាក់លើជាអ្នកសម្រេច"។ លោកឆ្លើយបែបនេះ តើផ្អែកទៅលើអី?

[១១:៥៥:១៤]

**ឆ៖** សូមឆ្លើយ ការឆ្លើយបែបនេះ គឺទៅតាមការជាក់ស្តែងដែលកិច្ចការផ្ទៃក្នុង គឺខាងលើអ្នកទទួលខុសត្រូវទាំងអស់ កិច្ចការផ្ទៃក្នុង ហេតុនេះខាងក្រោមកម្រិតខ្ញុំអីជាដើម ឬអ្នកដទៃដែលថ្នាក់កម្រិតពួកខ្ញុំក៏មិនអាចសម្រេចអីបានដែរបាទ។ ជាមួយនឹងក៏មិនអាចដឹងផងបាទ។

**ស៖** សូមអរគុណ។ លោកបានឆ្លើយអំមិញថា ផ្អែកទៅលើកិច្ចការជាក់ស្តែង។ សូមលោកអធិប្បាយចំណុចនេះឲ្យបានលម្អិតផង ខ្ញុំមិនយល់។

**ប្រធានអង្គជំនុំ៖**

លោកតាំងសំណួរចុងក្រោយឲ្យបានស្រួលបួលទៅ សាក្សីទំនងជាមិនយល់ដែរទេ។ ហើយមិនដឹងថាលោកចង់មានបំណងនៃការសំណួរ-- ការតាំងសំណួរនេះថាតើឲ្យសាក្សីហ្នឹងឆ្លើយថាម៉េច?

ចំពោះបញ្ហាស្អីដែលលោកសួរនេះ?

[១១:៥៧:០២]

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ខ្ញុំសូមប្តូរសំណួរ។ លោកបានឆ្លើយអំមិញថា ចម្លើយរបស់លោកផ្អែកលើកិច្ចការជាក់ស្តែង។ អឺចឹងសួរ-- ខ្ញុំសូមសួរបន្តទៀតថា តើកម្មាភិបាលដឹកនាំជាន់ខ្ពស់ កម្មាភិបាលថ្នាក់លើទាំងអស់ហ្នឹង នៅពេលដែលគេធ្វើសេចក្តីសម្រេចអ្វីមួយ ជាពិសេសទាក់ទងរឿងបញ្ហាយើងនេះ គឺការចាប់ខ្លួនផ្តោះប្តូរទូតនេះ។ តើកម្មាភិបាលថ្នាក់លើជាន់ខ្ពស់ហ្នឹងគេធ្វើសេចក្តីសម្រេចរបៀបម៉េច? តាមវិធីណា? មធ្យោបាយណា? សូមលោកពន្យល់ផង។ សូមអរគុណ។

**លោក នី កន៖**

**ឆ៖** សូមបញ្ជាក់តាមសមត្ថភាពខ្ញុំ ហើយនិងតាមលទ្ធភាពខ្ញុំយល់ដឹង ហើយនិងឃើញការប្រតិបត្តិជាក់ស្តែង គឺគេញែកការងាររដ្ឋបាលផ្សេង ការងារផ្ទៃក្នុងផ្សេង។ ដូច្នេះការងាររដ្ឋបាលនេះ គឺពួកខ្ញុំ ឬខ្ញុំក្នុងន័យអនុវត្ត គឺអនុវត្ត ហើយដល់ការងារផ្ទៃក្នុង ពួកខ្ញុំមិនអាចចូលរួមអីបានទេ។ ហើយការងារផ្ទៃក្នុងនេះមិនមែនត្រឹមការងារផ្ទៃក្នុងធម្មតាឯណា ជាការផ្ទៃ-- ការងារផ្ទៃក្នុងកម្រិតចាប់ខ្លួនមនុស្ស។ បាទ សូមអធិប្បាយជូនបានប៉ុណ្ណឹងបាទ។

[១១:៥៨:១៧]

**ស៖** សូមអរគុណ។ នៅពេលដែលខ្ញុំសួរថា ឲ្យលោកបញ្ជាក់ពីកិច្ចការជាក់ស្តែងលោកបានពន្យល់ថា តាមការយល់ ការដឹង ការឃើញរបស់លោក ប៉ុន្តែបើផ្អែកចម្លើយលោកឆ្លើយអំមិញថា លោកមិនដែលបានឃើញ អត់ដែលបានចូលរួមប្រជុំ អត់ដែលបានអានឯកសារនៃកិច្ចប្រជុំអីទេ។ តើលោកអាចពន្យល់បានថា តើលោកយល់ដឹង និងឃើញពីដំណើរការនៃកិច្ចការប្រជុំសម្រេចផ្សេងៗរបស់ថ្នាក់លើទាំងអស់នោះយ៉ាងដូចម្តេច?

**ឆ៖** សូមជម្រាបលោកប្រធាន គឺសំណួរនេះខ្ញុំដូចមិនសូវយល់ទេ ហើយដូចជាជាន់ចុះជាន់ឡើង ហើយខ្ញុំបញ្ជាក់ហ្នឹងបញ្ជាក់តាមភាសាដែលខ្ញុំនិយាយហ្នឹងគឺថា វាជាការងារដែលខ្ញុំឃើញក្នុងកិច្ចដំណើរការ មិនមែនខ្ញុំបានឃើញឯកសារលទ្ធផលអីទេ។ កិច្ចដំណើរការ គឺការងារស្រាលៗ គឺខាងផ្នែករដ្ឋបាល ដល់ការងារផ្ទៃក្នុងនេះ គឺការងារខាងលើបាទ។ ដូច្នេះ ខ្ញុំបញ្ជាក់ជូនបានប៉ុណ្ណឹង។ ឲ្យខ្ញុំបញ្ជាក់លើសពីនេះទៀត ខ្ញុំអត់មានទេបាទ។

[១២:០១:២២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកសាក្សី។ អរគុណមេធាវី។ ឥឡូវនេះដល់ពេលសមល្មមសម្រាក ដើម្បីពិសាថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសាថ្ងៃត្រង់ចាប់ពីពេលនេះតទៅរហូតដល់ម៉ោងមួយសាមសិបនាទីរសៀលនេះសូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួល និងផ្តល់កន្លែងសម្រាកសមរម្យដល់សាក្សីរូបនេះជាមួយនឹងមេធាវីប្រឹក្សារបស់គាត់នៅបន្ទប់រង់ចាំសម្រាប់សាក្សីដែលបានរៀបចំរួចហើយ ហើយនិងឲ្យអញ្ជើញគាត់មកកន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅរសៀលនេះ នៅវេលាម៉ោងមួយសាមសិបនាទី។

សូមអញ្ជើញលោកមេធាវី!

**លោក សុន អរុណ៖**

ដូចសព្វរាល់ដងលោក នួន ជា ដោយមានសុខភាពមិនល្អ សូមទៅសម្រាកនៅពេលថ្ងៃត្រង់នៅខាងបន្ទប់ខាងក្រោម។ ហើយបន្តការ-- សុំសិទ្ធិបន្តការតាមដាននៅបន្ទប់ខាងក្រោម ហើយសុំសិទ្ធិលះបង់ពីកន្លែងអង្គសវនាការនេះ។ សូមលោកប្រធានអនុញ្ញាត។

[១២:០២:៣០]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ សូមអង្គុយចុះ!

បានស្តាប់សំណើសុំរបស់លោក នួន ជា ដែលធ្វើឡើងតាមរយៈមេធាវីការពារក្តីរបស់គាត់ ស្នើសុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយសម្រាប់រយៈពេលថ្ងៃរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការ ដោយមូលហេតុបញ្ហាសុខភាព។ អង្គជំនុំជម្រះសម្រេចយល់ព្រមតាមសំណើសុំរបស់ជនជាប់ចោទ នួន ជា ដែលបានស្នើសុំតាមរយៈមេធាវីការពារក្តីរបស់គាត់ សុំទៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់ឃុំខ្លួនមួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាមរយៈឧបករណ៍សោតទស្សន៍សម្រាប់រយៈពេលពេញមួយរសៀលនេះ ដោយគាត់លះបង់សិទ្ធិចូលរួមនៅក្នុងកិច្ចដំណើរការសវនាការដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ។

[១២:០៣:២៣]

អង្គជំនុំជម្រះតម្រូវឲ្យក្រុមមេធាវីការពារក្តី នួន ជា ប្រគល់មកឲ្យអង្គជំនុំជម្រះភ្លាមនូវលិខិតលះបង់សិទ្ធិចូលរួមសវនាការដោយផ្ទាល់នៅក្នុងបន្ទប់សវនាការ ដោយមានចុះហត្ថលេខា ឬផ្តិតស្នាមម្រាមដៃយ៉ាងជាក់ច្បាស់ពីជនជាប់ចោទ នួន ជា។ បង្គាប់ឲ្យផ្នែកខាងសោតទស្សន៍ភ្ជាប់ប្រព័ន្ធសោតទស្សន៍សម្រាប់ជនជាប់រូបនេះអាចតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ក្នុងរយៈពេលនៃកិច្ចដំណើរការសវនាការសម្រាប់រសៀលថ្ងៃនេះ។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទ នួន ជា ហើយនិង ខៀវ សំផន ទៅកាន់បន្ទប់ឃុំខ្លួនខាងក្រោម ដោយនៅរសៀលនេះទុកឲ្យ នួន ជា នៅក្នុងបន្ទប់ដែលរៀបចំទុកជាស្រេចនូវឧបករណ៍សោតទស្សន៍សម្រាប់គាត់អាចចូលរួមតាមដានកិច្ចដំណើរការពីចម្ងាយ និងដោយឡែកលោក ខៀវ សំផន បង្គាប់ឲ្យនាំខ្លួនគាត់មកកាន់បន្ទប់សវនាការនេះវិញនៅរសៀលនេះមុនម៉ោងមួយសាមសិបនាទី។ សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមអញ្ជើញក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១២:០៤ នាទី ដល់ម៉ោង ១៣:៣១ នាទី)*

[១៣:៣១:៤៦]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ហើយនិងប្រគល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក អៀង សារី ដើម្បីបន្តការតាំងសំណួរចំពោះសាក្សីរូបនេះ។

សូមអញ្ជើញ!

**លោក ម៉ៃខល ផេសមិន៖**

សូមអនុញ្ញាតពេលពីរមីនុត ដើម្បីជម្រាបតុលាការ លោកប្រធាន!

**ប្រធានអង្គជំនុំ៖**

មិនអនុញ្ញាតទេ។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក អៀង សារី!

លោកមេធាវីការពារក្តីលោក នួន ជា ក្នុងករណីលោកមានបញ្ហាអី លោកអាចសរសេរពាក្យជាលាយលក្ខណ៍អក្សរបញ្ជូនមកយើង ដើម្បីយើងពិនិត្យ សម្រេច។

យើងមិនអនុញ្ញាតឲ្យលោកនិយាយទេ លោកអស់ពេលហើយ។ ពេលវេលាដែលយើងបានផ្តល់ឲ្យ អស់ហើយនៅសម្រាប់ការតាំងសំណួរសាក្សីរូបនេះ។ ប្រសិនបើលោកមានបញ្ហាអ្វី លោកដាក់ពាក្យសុំ ឬក៏ពាក្យបណ្តឹងរបស់លោកជាលាយលក្ខណ៍អក្សរ មកអង្គជំនុំជម្រះ។

[១៣:៣៣:៣៨]

**លោក អាង ឧត្តម៖**

សូមគោរពលោកប្រធាន លោកស្រីចៅក្រមសាថ្មី ហើយសួស្តី និងគោរពអង្គសវនាការផង។ អរុណសួស្តីលោក នី កន សាជាថ្មី។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ឥឡូវយើងបន្តកិច្ចពិភាក្សារបស់យើងទៀត។ ពីព្រឹកមិញលោកបានមានប្រសាសន៍ថានិយាយតាមពិតជាក់ស្តែង គឺថាថ្នាក់លើ នៅក្នុងសេចក្តីថ្លែងខ្លះហ្នឹងជាមេដឹកនាំ នៅក្នុងសេចក្តីថ្លែងខ្លះហ្នឹង ហើយបានធ្វើសេចក្តីសម្រេចទាក់ទងពីរឿងការចាប់ ការផ្លាស់ប្តូរអ្នកការទូត។ សំណួរខ្ញុំបន្តទៀតគឺថា ដោយហេតុនេះ តើលោកមានព័ត៌មានអីពិតជាក់ស្តែងទាក់ទងថា នៅពេលណាដែលពួកអស់លោកជាថ្នាក់លើហ្នឹងចូលរួមប្រជុំ? តើលោកដឹងព័ត៌មានជាក់ស្តែងទាំងអស់ហ្នឹងទេ?

[១៣:៣៥:១៨]

**ឆ៖** សូមជម្រាបជូនបាទ ព័ត៌មានជាក់ស្តែង ខ្ញុំអត់មានទេបាទ។

**ស៖** សូមអរគុណ។ បន្តទៀត តើលោកមានព័ត៌មានជាក់ស្តែងអី ទាក់ទងថាតើក្នុងចំណោមថ្នាក់លើទាំងអស់ហ្នឹង តើមានអ្នកណាខ្លះដែលបានចូលរួមប្រជុំហ្នឹង?

**ឆ៖** សូមជម្រាបជូន ចម្លើយរបស់ខ្ញុំហាក់ដូចដដែល គឺខ្ញុំអត់បានដឹងទេក្នុងក្របខ័ណ្ឌថ្នាក់លើនោះ។ តើនរណាប្រជុំ នរណាមិនប្រជុំ ខ្ញុំមិនដឹងទេបាទ។

**ស៖** ផ្អែកលើសម្តីលោកដដែល ថាចម្លើយនេះទាក់ទងផ្អែកលើការអនុវត្តជាក់ស្តែង។ អ៊ីចឹងសំណួរខ្ញុំបន្តទៀតថា តើលោកមានព័ត៌មានជាក់ស្តែងណាមួយស្តីពី ថាតើកិច្ចប្រជុំនេះគេមានរបៀបវារៈប្រធានបទអីខ្លះទេ?

[១៣:៣៧:០៣]

**ប្រធានអង្គជំនុំ៖**

សាក្សីមិនបាច់ចាំឆ្លើយទេ! ព្រោះលោកសាក្សីអត់ដឹងថាមានកិច្ចប្រជុំផង ហើយទម្រាំតែរបៀបវារៈទៀត វាកាន់តែអត់ដឹងទៀតហើយ ព្រោះកិច្ចប្រជុំមិនដឹងផង។

**លោក អាង ឧត្តម៖**

សូមៗលោកប្រធាន។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** អ៊ីចឹងបានន័យថា តើលោកមានព័ត៌មានអី ឬក៏ការដឹងឮផ្ទាល់ដោយចំពោះទាក់ទងរឿងការប្រជុំ និងការសម្រេចរបស់ថ្នាក់លើនេះទេ?

[១៣:៣៨:១៣]

**លោក នី កន៖**

**ឆ៖** សូមជម្រាប ការសម្រេច ការប្រជុំ ហើយនីតិវិធីទាំងអស់នេះវានៅក្នុងចម្លើយរបស់ខ្ញុំខាងដើមហើយ គឺខ្ញុំមិនបានដឹងទេ ជាផ្ទៃក្នុងក្របខ័ណ្ឌថ្នាក់លើ បាទ។

**លោក អាង ឧត្តម៖**

ខ្ញុំអស់សំណួរហើយ។ សូមអរគុណលោក នី កន ដែលបានឡើងមកឆ្លើយក្នុងសវនាការ ដើម្បីផ្តល់សក្ខីកម្មទាក់ទងរឿងការពិត និងយុត្តិធម៌។ សូមជូនពរលោកធ្វើដំណើរវិញមានសុវត្ថិភាព។

សូមអរគុណលោកប្រធាន។

[១៣:៣៩:០៣]

**ប្រធានអង្គជំនុំ៖**

អរគុណ។ បាទជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តីលោក ខៀវ សំផន។

[១៣:៤០:០២]

**អ្នកបកប្រែ៖**

ជម្រាបលោកប្រធាន ខាងបកប្រែស្តាប់ខាងលោកមេធាវីនិយាយអត់បាន បាទ។

**ប្រធានអង្គជំនុំ៖**

សូមលោកមេធាវីចាប់ផ្ដើមសាជាថ្មី ទំនងជាអាចឮហើយ។ លោកនិយាយអម្បាញ់មិញពីដំបូងហ្នឹងមិនមានការបកប្រែទេ ព្រោះអត់ឮសំឡេង។

**លោក គង់ សំអុន៖**

បាទសូមអរគុណលោកប្រធាន។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមគោរពសាជាថ្មី ហើយសូមជម្រាបសួរលោក នី កន ខ្ញុំមេធាវី គង់ សំអុន ហើយសូមសួរលោកបីបួនចំណុចទាក់ទៅនឹងការផ្ដល់សក្ខីកម្មនាពេលនេះ។ ជាបឋម ខ្ញុំសូមសួរថា តើលោកមានប្រើឈ្មោះអ្វីផ្សេងក្រៅពីឈ្មោះ កន និងឈ្មោះ នី កន នេះទេ?

[១៣:៤០:៥៦]

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ។ ឈ្មោះខ្ញុំមានបី កន, កិន, សាត។

**ស៖** សូមអរគុណ។ លោកអាចប្រកបជាភាសាខ្មែរបានទេ ឈ្មោះ កិន ហើយនិង សាត?

**ឆ៖** បាទ បានបាទ។ កន ហ្នឹង គឺអក្សរ “ក” ហើយនិង “ន”។ ហើយ កិន ហ្នឹង អក្សរ “ក” និង “ិ”, “ន”។ ហើយ សាត ហ្នឹង “ស”, “ា” និង “ត” បាទ។

**ស៖** បាទ សូមអរគុណ។ តើលោកប្រើឈ្មោះក្រៅដែលលោកបានជម្រាបជូនក្រុមប្រឹក្សាជំនុំជម្រះអម្បាញ់មិញនេះញឹកញាប់ទេ ឬក៏ប្រើជាផ្លូវការដែរទេ?

**ឆ៖** ឈ្មោះប្រើញឹកញាប់គឺឈ្មោះ កន និង កិន បាទ។

**ស៖** ចុះឈ្មោះ សាត ហ្នឹងមានគេស្គាល់លោកថាលោកឈ្មោះ សាត អ៊ីចឹងដែរទេ ឈ្មោះហៅក្រៅរបស់លោកហ្នឹង?

[១៣:៤២:៤១]

**ឆ៖** បាទ ស្គាល់ តែស្គាល់ចំនួនតិច។

**ស៖** ហើយលោកមានដែលចុះហត្ថលេខានៅលើឯកសារណាមួយជាផ្លូវការ ដោយប្រើឈ្មោះ សាត ឬក៏ឈ្មោះ កិន ក្រៅពីឈ្មោះ កន នេះដែរទេ?

**ឆ៖** បាទ មិនសូវប្រើទេ ក្រៅពីឈ្មោះ កន បាទ។

**ស៖** បាទ សូមអរគុណ។ លោកបានបញ្ជាក់ជាច្រើនដងនៅក្នុងរយៈពេលសវនាការនេះអំពីគោលការណ៍នៃការរក្សាការសម្ងាត់នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តើលោកអាចបញ្ជាក់បានទេថា តើលោកទទួលការអប់រំបែបណាក្នុងការអនុវត្តចំពោះការរក្សាការសម្ងាត់នេះ?

**ផ៖** សូមលោកបញ្ជាក់សំណួរម្ដងទៀត ដើម្បីខ្ញុំយល់បាទ។

**ស៖** បាទ ទាក់ទងទៅនឹងការរក្សាការសម្ងាត់នេះ សូមលោកបញ្ជាក់ថាតើលោកបានទទួលការអប់រំ ឬក៏ការបណ្ដុះបណ្ដាលដើម្បីរក្សាការសម្ងាត់នេះដែរឬទេ? ហើយបើមាននោះដោយរបៀបណាដែរ?

[១៣:៤៤:៣០]

**ផ៖** សូមឆ្លើយ ក្នុងការទទួលការណែនាំ ឬការអប់រំអំពីការសម្ងាត់នេះ គេប្រើពាក្យថា "លាក់ការណ៍សម្ងាត់"។ លាក់ការណ៍សម្ងាត់នេះ គឺមានន័យថា កិច្ចការអ្វីជាផ្ទៃក្នុង ជាក្របខ័ណ្ឌដឹកនាំ ជាក្របខ័ណ្ឌការងារដែលថ្នាក់នីមួយៗត្រូវដឹង។ ថ្នាក់ប្រជាជនត្រូវដឹងប៉ុនណា? ថ្នាក់កម្មាភិបាលធម្មតាត្រូវដឹងប៉ុនណា? ថ្នាក់ដឹកនាំត្រូវដឹងប៉ុនណា? ហើយពាក្យស្លោកមានច្រើន តែខ្ញុំចាំមិនអស់ទេ។ ខ្ញុំចាំតែ ស្លូត្រត់មាត់ គឺការងារគេ គេដឹង ការងារយើង យើងដឹង។ យើងមិនត្រូវមានះ ឬក៏ទទូចចង់ដឹងពីរឿងគេទេ។ នេះប៉ុណ្ណឹងដែលជាពាក្យស្លោក។ សូមជម្រាបជូនអ៊ីចឹង អំពីការណែនាំ។ បានការណែនាំអ៊ីចឹង ខ្ញុំក៏ទៅណែនាំអ៊ីចឹងដែរ។ តាមហ្នឹង ហើយចេះតែណែនាំបន្តៗតាមថ្នាក់ហ្នឹងទៅ បាទ។ តាមថ្នាក់ តាមជាន់អ៊ីចឹងទៅ បាទ។

**ស៖** បាទ សូមអរគុណ។ ចុះក្នុងករណីដែលមានការបំពាន ឬក៏រំលោភចំពោះការរក្សាការសម្ងាត់នេះ ជាលទ្ធផលនោះវាទៅជាយ៉ាងណាដែរ?

[១៣:៤៧:០២]

**ផ៖** គេមាននីតិវិធីគេមួយ គឺគេហៅស្វ័យទិតៀន គឺខ្លួនឯងពិនិត្យខ្លួនឯង តើបានរក្សាការសម្ងាត់បានល្អជាគុណសម្បត្តិបែបណា? ខ្វះខាតយ៉ាងណា? ប៉ុណ្ណឹងបាទ ហើយលើកទិសថ្ងៃក្រោយទៀត កុំធ្វើអ៊ីចឹងទៀតយ៉ាងណា? បាទ ប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ចុះចំពោះរូបលោកផ្ទាល់វិញក្នុងសម័យកម្ពុជាប្រជាធិបតេយ្យនោះ តើលោកគោរពគោលការណ៍នៃការរក្សាការសម្ងាត់នេះដោយរបៀបណាដែរ?

**ផ៖** ខ្ញុំសូមបញ្ជាក់ គឺខ្ញុំគោរពតាមការណែនាំ ហើយភ្ជាក់រឭកខ្លួនឯងដោយការយល់ថា អ្វី

ចំណោញ អ្វីខាត។ ដូច្នេះ ខ្ញុំប្រតិបត្តិតាមហ្នឹងបាទ។

**ស៖** បាទសូមអរគុណ។ ក្នុងការអនុវត្តជាក់ស្តែង តើលោកធ្លាប់មានបានបំពាននូវគោលការណ៍លាក់ការណ៍សម្ងាត់ ឬក៏រក្សាការសម្ងាត់នេះដែរទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

[១៣:៤៩:១១]

**ឆ៖** តាមការចងចាំរបស់ខ្ញុំ ខ្ញុំមិនដែលបំពានទេ បាទ។

**ស៖** បាទ សូមអរគុណ។ ឥឡូវខ្ញុំសូមសួរលោកទាក់ទងទៅនឹងឯកសារដែលបានបង្ហាញជូនលោករួចហើយក្នុងរយៈពេលកន្លងមកនេះ គឺឯកសារដែលមានលេខ D91/21 ត្រង់ទំព័រទីបី។

**លោក គង់ សំអុន៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាតឲ្យសហការីបង្ហាញនូវលើអេក្រង់ទូរទស្សន៍។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះអនុញ្ញាតសូមអញ្ជើញ!

**លោក គង់ សំអុន៖**

លេខ ERN នៅក្នុងភាសាខ្មែរ គឺមានលេខ 00204129 ជាភាសាបារាំងមានលេខ 00529340 ជាភាសាអង់គ្លេស 00223626។

**សួរដោយលោក គង់ សំអុន៖**

**ស៖** សូមទោសលោកសាក្សី តើលោកបានឃើញឯកសារហ្នឹងទេ? លោកអាចអានភាសាខ្មែរបានទេ? ខ្ញុំសូម-- បើសិនជាលោកអាចអាននៅក្នុងអេក្រង់ទូរទស្សន៍បាន ខ្ញុំឲ្យលោកអាននៅក្នុងនោះ បើសិនជាលោកមិនអាចអាននៅក្នុងអេក្រង់ទេ។ ខ្ញុំសូមជូនឯកសារដល់លោក។

[១៣:៥២:៥១]

**លោក នី កន៖**

**ឆ៖** សូមឆ្លើយបាទ ខ្ញុំអានបានបាទ ឯកសារ។

**លោក គង់ សំអុន៖**

សូមទោស។ ត្រង់--

សូមអធ្យាស្រ័យលោកប្រធាន ដោយសារកុំព្យូទ័រខ្ញុំបាទអត់មានភ្ជាប់នូវប្រព័ន្ធនេះ។ អ៊ីចឹងខ្ញុំបាទមើលអត់ឃើញនូវទីតាំង។ ខ្ញុំសូមជម្រាបជូនសាក្សី នៅត្រង់ខាងចុងទំព័រ ក្នុងកន្លែង “ន.ក” រាប់ពី

បន្ទាត់ខាងក្រោម កន្លែងចាប់ពីផារ៉ាក្រាសទីពីរ រាប់ពីក្រោមទៅចន្លោះហ្នឹង។ មួយ ពីរ បី បួន បន្ទាត់ទីបួន មានដាក់ថា "ន.ក៖ ខ្ញុំស្គាល់ច្បាស់--" ខ្ញុំសូមអានជូន "ខ្ញុំស្គាល់ច្បាស់"។ ខ្ញុំសូមទាក់ទងនឹងសំណួរនេះ ដោយលោកឆ្លើយថា "ខ្ញុំស្គាល់ច្បាស់លោក អៀង សារី ចំណែកលោក ខៀវ សំផន និង អៀង ធីរិទ្ធ-- អ៎! សូមទោស លោក ខៀវ សំផន, អៀង ធីរិទ្ធ និង នួន ជា គឺស្គាល់ដែរត្រង់ថា ជាថ្នាក់លើ"។ សូមឲ្យលោកជួយពន្យល់ ពាក្យថា ថ្នាក់លើដែលលោកចង់និយាយនៅទីនេះ មានន័យដូចម្ដេចដែរ?

**ឆ៖** សូមបកស្រាយជូនបាទ។ ថ្នាក់លើនេះ ជាភាសានិយាយ រួចហើយនិយាយជួនកាលវាមិនច្រំដែលក៏ប្រើថាថ្នាក់ម្ដង ខាងលើម្ដង។ ដូច្នេះ ន័យវាតែមួយទេ គឺថាអ្នកដឹកនាំខាងលើបាទ។ តែប៉ុណ្ណឹងបាទ។

[១៣:៥៦:២២]

**ស៖** បាទសូមអរគុណ។ តើពាក្យថ្នាក់លើនេះមានទំនាក់ទំនងជាអ្នកគ្រប់គ្រងផ្ទាល់របស់លោក ឬមួយក៏ពុំមានទេ?

**ឆ៖** ថ្នាក់លើដែលខ្ញុំឆ្លើយនឹងការសម្ភាស គឺជាថ្នាក់លើក្របខ័ណ្ឌទូទៅហើយ ក្របខ័ណ្ឌដឹកនាំរួមហើយ ហើយថ្នាក់លើក្រៅពីហ្នឹងគឺ បុគ្គលនីមួយៗគេនិយាយថា ថ្នាក់លើបន្តបន្ទាប់តាមថ្នាក់គេបាន។ តែថ្នាក់លើហ្នឹង ជាថ្នាក់លើកម្រិតណា វាអាស្រ័យនឹងការសន្ទនារបស់គេ។ ដូច្នេះថ្នាក់លើដែលខ្ញុំបញ្ជាក់នេះ គឺថ្នាក់លើកំពូលហើយបាទ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹង ខ្ញុំសូមបញ្ជាក់ឡើងវិញ ថ្នាក់លើដែលលោកមានប្រសាសន៍នេះ គឺមិនមែនជាថ្នាក់លើ ដែលស្ថិតនៅក្រោមការគ្រប់គ្រងផ្ទាល់ចំពោះលោកទេ?

**ឆ៖** សូមបញ្ជាក់ទៀត ក្រែងលោការបកប្រែពីខ្ញុំទៅភ័ន្តច្រឡំ។ ថ្នាក់លើដែលខ្ញុំសម្ភាសក្នុងពេលនេះ គឺឈ្មោះទាំងប៉ុន្មានដែលខ្ញុំលើកឡើងនេះឯងបាទ។

**ស៖** សូមអរគុណ។ ខ្ញុំសូមសួរលោកបន្តថា តើលោកស្គាល់លោក ខៀវ សំផន ជាលក្ខណៈបុគ្គលដែរឬទេ ក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ក៏ដូចជាសម័យមុនកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** សូមបញ្ជាក់។ ស្គាល់ជាបុគ្គលមិនស្គាល់ទេ តែស្គាល់ជាដឹកនាំរួម ដែលបានឃើញពេលពិធីទទួលភ្ញៀវ ឬក៏ពិធីអីមួយដែលម្ដងម្កាលខ្ញុំឃើញ។ តែជាបុគ្គល មិនបានជិតស្និទ្ធ ស្គាល់ជិតស្និទ្ធអីទេបាទ។

[១៣:៥៩:១៥]

**ស៖** បាទ សូមអរគុណ។ តើលោកធ្លាប់មានបានធ្វើការអ្វី ឬដូចជាការទទួលបញ្ជាអ្វីពីលោក ខៀវ សំផន ដែរទេក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ?

**ឆ៖** សូមបញ្ជាក់ជូនបាទ។ ខ្ញុំមិនដែលបានទទួលផ្ទាល់ទេ ពីព្រោះការងារវាញែកពីគ្នាដាច់។ ខ្ញុំនៅខាងក្របខណ្ឌក្រសួង គឺទទួលតែពីក្រសួងបាទ។

[១៣:៥៩:៥៨]

**ស៖** បាទសូមអរគុណ។ ខ្ញុំសូមលោកបញ្ជាក់មួយទៀត ទាក់ទងទៅនឹងកំណត់ហេតុស្តាប់ចម្លើយរបស់លោក ជាមួយអ្នកស៊ើបអង្កេតរបស់ចៅក្រម សហចៅក្រមស៊ើបអង្កេត ដែលមានលេខឯកសារ D91/22 ត្រង់ទំព័រទីពីរ ដែលមានលេខជាភាសាខ្មែរ ERN ជាភាសាខ្មែរ 00204132។

**លោក គង់ សំអុន៖**

ខ្ញុំសូមលោកប្រធានអនុញ្ញាតបញ្ចាំងត្រង់ទំព័រនេះ តាមទូរទស្សន៍។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ អង្គជំនុំជម្រះអនុញ្ញាត។ បុគ្គលិកជំនួយការបង្ហាញឯកសារនៅលើអេក្រង់កុំព្យូទ័រ!

**សួរដោយលោក គង់ សំអុន៖**

**ស៖** លោក នី កន លោកបានឃើញនៅក្នុងទូរទស្សន៍ទេ ត្រង់ចំណុចគូសបន្ទាត់ពណ៌ក្រហមពីក្រោម ហើយលោកអាចផ្ទៀងជាមួយនឹងឯកសារដែលមាននៅក្នុងដៃរបស់លោក។

**លោក នី កន៖**

**ឆ៖** បាទ។

[១៤:០២:១០]

**ស៖** ចំណុចត្រង់នេះ លោកមេធាវីរបស់លោក អៀង សារី បានសួរលោកមុននេះរួចហើយ ហើយខ្ញុំសូមបញ្ជាក់សារឡើងវិញ ដើម្បីបង្ហាញពីចំណុចដែលខាងយើងខ្ញុំចង់បាន តើលោកអាចអានជូនក្រុមប្រឹក្សាជំនុំជម្រះត្រង់ចំណុចដែលមានបន្ទាប់ក្រហមនេះបានទេ?

**ឆ៖** ខ្ញុំសូមអាន ហើយបើសិនជាការអានរបស់ខ្ញុំវាមិនចំសំណួររបស់លោក ក៏សូមបញ្ជាក់។ “ការផ្លាស់ប្តូរមន្ត្រីទូត គឺថ្នាក់លើជាអ្នកសម្រេច។ ថ្នាក់លើគឺអស់លោកថ្នាក់ដឹកនាំធំៗ គឺអ៊ំៗ គឺប៉ុល ពត ហៅតាប៉ុល, នួន ជា ហៅតានួន, អៀង សារី ហៅតាវ៉ាន់ និងលោក-- និង ខៀវ សំផន។ ខ្ញុំមិន

ដែលបានជួបផ្ទាល់ជាមួយអស់លោកទាំងនោះទេពីមុនមក" បាទ។

**ស៖** បាទ សូមអរគុណ។ ពីមុននេះខ្ញុំសូមឲ្យលោកអានភ្ជាប់ជាមួយនឹងពាក្យថា ចំពោះការចាប់ខ្លួនផងដែរ មុននេះ។ លោកមិនចាំបាច់អានទៀតទេបាទ។ សូមអរគុណ។ ខ្ញុំបាននិយាយរួចហើយ។ ត្រង់ចំណុចនេះ ទាក់ទងទៅនឹងការសម្រេចរបស់ថ្នាក់លើ តាមការឆ្លើយបញ្ជាក់របស់លោកកន្លងមក លោកថាលោកមិនបានដឹងទេ លោកមិនបានចូលរួមទេ។ ហើយលោកក៏មិនបានទទួលរបាយការណ៍ ឬក៏ការណែនាំណាផ្សេងៗ អំពីការប្រជុំរបស់ថ្នាក់ដឹកនាំទាំងនោះដែរ តាមដែលលោកឆ្លើយជាមួយនឹងលោកមេធាវីរបស់លោក អៀង សារី អម្បាញ់មិញនេះ។ ខ្ញុំសូមសួរលោកបន្ថែមថា តើលោកមានមូលដ្ឋាន ឬក៏សំអាងអ្វីដែលអាចបញ្ជាក់ថា ការសម្រេចទាំងអស់នេះជារបស់ថ្នាក់លើ តាមដែលលោកបានមានប្រសាសន៍នេះដែរទេ?

[១៤:០៥:១២]

**ឆ៖** មូលដ្ឋានដែលលោកចង់បាន ដែលចង់បានឲ្យខ្ញុំបញ្ជាក់ ខ្ញុំបញ្ជាក់ជូនបានត្រឹមដែលខ្ញុំយល់ ហើយនិងឃើញការប្រតិបត្តិ។ ទីមួយ ទាក់ទងនឹងការចាប់ខ្លួនមន្ត្រីទូតនៅក្នុងក្រសួងការបរទេស។ ខ្ញុំសូមសង្ខេបសភាពការណ៍បន្តិច ដើម្បីលោកយល់។ ទីមួយ ខ្ញុំមកដល់ហ្នឹង អង្គភាព មន្ទីររបស់ក្រសួងការបរទេសនេះ គេមានជាអង្គភាពគេពេញលេញ ពេញលក្ខណៈអស់ហើយ។ ខ្ញុំជាបុគ្គលមួយដែលត្រូវដកហូតយកមកបន្ថែមនៅត្រង់ហ្នឹង ឬហៅថា "បញ្ឈរជើងក៏ថាបាន"។ ដូច្នេះ រចនាសម្ព័ន្ធនៅក្នុងអង្គភាពនេះមានរៀបរយអស់ហើយ។ ទីពីរ ខ្ញុំមកដល់មន្ត្រីទូតដែលលោកចៅក្រមស៊ើបអង្កេតយកមកសួរខ្ញុំក៏មិនៗមានជាមនុស្ស មិនស្គាល់ជាឈ្មោះបាទ។ អ៊ីចឹងហើយបានជាខ្ញុំបញ្ជាក់ថា ខ្ញុំមិនដឹង ខ្ញុំមិនអាចឆ្លើយថាដឹងបានទេ។

[១៤:០៧:០៦]

ទីពីរ បានបញ្ជាក់ពីព្រឹកមិញថ្មីៗនេះថា រចនាសម្ព័ន្ធវាមានខាងក្រៅ វាមានផ្ទៃក្នុង។ ផ្ទៃក្នុងថ្នាក់ដឹកនាំ ខ្ញុំសូមបញ្ជាក់សាជាថ្មីថា ខ្ញុំមិនដឹងជាប្រជុំថ្ងៃណា? ហើយបើសួរដល់របៀបវារៈទៀត វារឹតតែជ្រៅទៀតហើយ។ ហេតុនេះខ្ញុំមិនអាចឆ្លើយថា ឈរលើមូលដ្ឋានអីជូនលោកបានទេ ឈរតែលើមូលដ្ឋានមួយគឺ កិច្ចការ ការងារផ្ទៃក្នុងរបស់ខាងលើ ឬថ្នាក់លើ។ សូមជម្រាបជូនប៉ុណ្ណឹងបាទ។

**ស៖** អ៊ីចឹង ខ្ញុំសូមបញ្ជាក់លោកសាឡើងវិញថា មូលដ្ឋានដែលលោកសំអាងថា ថ្នាក់លើជាអ្នកសម្រេចនេះ ដោយយោងថា អ្នកខាងលើនៅខាងលើជាអ្នកសម្រេច ដែលថ្នាក់ដឹកនាំជាអ្នកសម្រេច

ដោយការយល់ជាលក្ខណៈទូទៅរបស់លោក អ៊ីចឹងមែនទេ?

**ឆ៖** បាទ ខ្ញុំយល់បានប៉ុណ្ណឹងបាទ។

**ស៖** បាទ សូមអរគុណ។ ចំពោះថ្នាក់លើដែលលោកបានបង្ហាញជូនក្រុមប្រឹក្សាជំនុំជម្រះនៅពេលនេះ មានឈ្មោះច្រើន តើលោកដឹងថាថ្នាក់លើទាំងអស់នោះធ្វើការជាមួយគ្នា ឬលោកមិនបានដឹងថាការងាររបស់គាត់ធ្វើការដោយរបៀបណាទេ?

[១៤:០៩:២២]

**ឆ៖** សូមឆ្លើយ ខ្ញុំមិនដឹងទេ។

**ស៖** បាទ សូមអរគុណ។ អ៊ីចឹងបានន័យថា ការសន្និ-- ការជម្រាបជូនទៅសហចៅក្រមស៊ើបអង្កេតដែលមាននៅក្នុងឯកសារខ្ញុំបានជម្រាប-- ដូចខ្ញុំបានបង្ហាញជូននេះ វាអាចជាការសន្និដ្ឋានរបស់លោក។ អ៊ីចឹងមែនទេ?

**ប្រធានអង្គជំនុំ៖**

សូមៗអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

បាទលោកប្រធាន យើងស្ថិតនៅក្នុងស្ថានភាពដូចអម្បាញ់មិញអ៊ីចឹងឯង។ នៅពេលដែលមេធាវីរបស់លោក អៀង សារី មេធាវីជាតិរបស់លោក អៀង សារី ចោទសំណួរដូចគ្នា ដើម្បីឈានទៅដល់ទាញការសន្និដ្ឋានដូចគ្នា គឺថាធ្វើឲ្យសាក្សីនិយាយអ្វីមួយដូចដែលខ្លួនចង់បាន។ នេះជាសំណួរនាំមុខលោកប្រធាន។ សូមអរគុណ។

[១៤:១០:៥៥]

**ប្រធានអង្គជំនុំ៖**

អរគុណ។ ជំទាស់របស់តំណាងសហព្រះរាជអាជ្ញាចំពោះសំណួរចុងក្រោយរបស់មេធាវីការពារក្តីលោក ខៀវ សំផន ចំពោះសាក្សីរូបនេះ មានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរចុងក្រោយរបស់មេធាវីទេ ដោយសារជាសំណួរនាំមុខ។

**លោក គង់ សំអុន៖**

បាទ សូមអរគុណលោកប្រធាន។ ខ្ញុំសូមអស់សំណួរ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទ សូមអញ្ជើញលោកមេធាវី!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។ សូមជម្រាបសួរអស់លោក លោកស្រីចៅក្រម ជម្រាបសួរលោកសាក្សី។ ខ្ញុំឈ្មោះ អង់តា ហ្គីសសេ ខ្ញុំជាសហមេធាវីអន្តរជាតិរបស់លោក ខៀវ សំផន។ ហើយក្នុងខណៈនេះ ខ្ញុំសូមចោទសំណួរចុងក្រោយ ជាចុងក្រោយទៅកាន់លោកនៅរសៀលនេះ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** ខ្ញុំសូមរំឭកលោកថា យើងមានការបកប្រែ បើសិនជាការមានពិបាកក្នុងការយល់សំណួររបស់ខ្ញុំ សូមកុំឲ្យអល់អែកក្នុងការប្រាប់មកខ្ញុំ។ ជាបឋម ខ្ញុំសូមត្រឡប់មកក្រោយវិញ និយាយអំពីប្រវត្តិរបស់លោក។ តើមុខរបរឪពុកម្ដាយលោកនោះអ្វីដែរ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ មុខរបររបស់ឪពុកម្ដាយខ្ញុំ ជាកសិករធ្វើស្រែជាមូលដ្ឋាន បាទ។

**ស៖** លោកសាក្សី តើជាកសិករក្នុងលក្ខខណ្ឌណាដែរ? តើជា គាត់ៗមានម្ចាស់កម្មសិទ្ធិមានដីធ្លី ឬក៏ជាកសិករក្រីក្រទេ?

**ឆ៖** សូមឆ្លើយ ឪពុកម្ដាយខ្ញុំជាកសិករកណ្ដាល មានគោពីរនឹម មានដីស្រែប្រហែលជា២០ អំពក។ ហើយចាំមិនអស់ទេ ប្រហែលប៉ុណ្ណឹងបាទ។

**ស៖** លោកបានប្រាប់ថា កាលពីលោកមានអាយុ១៥ឆ្នាំ លោកបានចេញទៅសិក្សានៅទីក្រុងភ្នំពេញ តើលោករស់នៅទីនោះជាមួយឪពុកម្ដាយលោករហូតដល់អាយុ១៥ឆ្នាំ តើខ្ញុំត្រូវយល់យ៉ាងដូច្នេះ ឬក៏យ៉ាងម៉េច?

[១៥:១៥:៩៩]

**ឆ៖** សូមឆ្លើយ ខ្ញុំមករស់នៅជាមួយបងខ្ញុំ ជាគ្រូបង្រៀនដែរបាទ។ បងមួយទៀតឈ្មោះ នី ឈុំ។

**ស៖** លោកបាននិយាយនៅពេលដែលលោកផ្ដល់សក្ខីកម្ម គឺថាលោកធ្លាប់ជាគ្រូបង្រៀននៅសៀមរាប ហើយតើលោកបង្រៀនទៅក្មេងប្រភេទណាដែរ? តើក្មេងនោះស្ថិតនៅក្នុងមជ្ឈដ្ឋានណាដែរ?

**ប្រធានអង្គជំនុំ៖**

សាក្សីមិនចាំបាច់ឆ្លើយតបទេ! សំណួរនេះមិនពាក់ព័ន្ធនឹងអង្គហេតុដែលចោទប្រកាន់ទៅលើជនជាប់ចោទទេ។

[១៤:១៥:៥៦]

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន សំណួរនេះពាក់ព័ន្ធ ហើយខ្ញុំសូមផ្ដល់មូលហេតុ។ នៅក្នុងក្របខ័ណ្ឌនៃការចោទសំណួរ ខ្ញុំមិនអាចចោទសំណួរនាំមុខបានទេ។ ដូច្នេះខ្ញុំត្រូវៗតែគូសផ្លូវដើរ ដើម្បីទៅដល់ចំណុចណាមួយដែលខ្ញុំចង់បាន។ ដូច្នេះខ្ញុំសូមឲ្យអង្គជំនុំជម្រះមានការអត់ធ្មត់ ហើយយល់ថាហេតុអីបានជាខ្ញុំចោទសំណួរប្រភេទនេះ។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចរួចហើយ លោកស្រីអាចតសំណួរផ្សេងទៀត។ ចៀសវាងឲ្យផុតនូវសំណួរដែលច្រំដែល សំណួរមិនពាក់ព័ន្ធ សំណួរឧបមានវិធី សំណួរនាំមុខជាដើម ឬក៏សំណួរនាំឲ្យសាក្សីផ្ដល់ចម្លើយជាសេចក្ដីសន្និដ្ឋានការយល់ដឹងអត្តនោម័តិផ្ទាល់ខ្លួន។

[១៤:១៧:០៧]

**លោកស្រី អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំបន្តទៅសំណួរ-- ចំណុចមួយទៀតនៃការសួរចម្លើយរបស់ខ្ញុំ។

**សួរដោយលោកស្រី អង់តា ហ្គីសសេ៖**

**ស៖** នៅក្នុងរយៈពេលដែលលោកនៅក្នុងមជ្ឈដ្ឋានកសិករនៅសៀមរាបនោះ ហើយមុននឹងពេលដែលលោកចូលបដិវត្តន៍នៅឆ្នាំ១៩៧០ តើលោកបានធ្លាប់ជួបប្រទះនឹងការទម្លាក់គ្រាប់បែកនៅក្នុងតំបន់នោះដែរឬទេ?

**លោក នី កន៖**

**ឆ៖** សូមឆ្លើយ ក្នុងពេលរដ្ឋប្រហារភ្លាមៗ ការទម្លាក់គ្រាប់បែកមិនទាន់ដល់ជនបទ។ តែដល់ពេលមានការប្រយុទ្ធទូទៅហើយ បានមានការទម្លាក់គ្រាប់បែក។ ឯការទម្លាក់បែកនោះ ក៏ទម្លាក់តាមចាំខ្លះៗ គេរាប់ពីកំពង់ធំទៅ ទៅដល់ព្រំដែនសៀមរាប ហើយច្រើនតែទម្លាក់ផ្ដាច់ស្ពាន។ បាទ សូមជម្រាបជូនប៉ុណ្ណឹងបាទ។

[១៤:១៨:៥២]

**ស៖** លោក នី កន នៅក្នុងការងារជាអ្នកឃោសនិកដល់ប្រជាជននៅតំបន់នោះ នៅក្នុងក្របខ័ណ្ឌនៃការពិភាក្សារបស់លោកជាមួយនឹងប្រជាជន តើការបោកគ្រាប់-- ទម្លាក់គ្រាប់បែកនេះជំរុញឲ្យមនុស្សចូលបដិវត្តន៍ ចូលទៅរណសិរ្សដែរឬទេ?

**ឆ៖** សូមបញ្ជាក់ ជាការដែលខ្ញុំឃើញ ការដែលទម្លាក់គ្រាប់បែកប៉ះពាល់កូនចៅគេ ម៉ែឪគេ ទ្រព្យសម្បត្តិរបស់គេ អាហ្នឹងវាជាប្រឆេះ បញ្ឆេះថែមឲ្យប្រជាជនក្មេង ចាស់ ប្រុស ស្រីកាន់តែចូលរួមបាទ។

[១៤:២០:១០]

**ស៖** នៅពេលដែលលោកផ្តល់សក្ខីកម្ម លោកបានប្រាប់ថាមួយផ្នែកនៃការងារឃោសនារបស់លោកគឺថាក្នុង-- គឺផ្តល់ដំបូន្មាន ឬសេចក្តីណែនាំផ្នែកកសិកម្មទៅប្រជាជន ហើយនិងនិយាយអំពីឯកភាពនៃប្រទេស ឬក៏ភាពគ្រប់គ្រាន់ ឯករាជ្យភាព ហើយនិងការធ្វើឲ្យរីកចម្រើនជីវភាព។ ហើយសំណួរដែលខ្ញុំសួរ ចង់សួរ-- សំណួររបស់ខ្ញុំគឺថាតើការនិយាយដូច្នេះប្រជាជនទទួលយកបានតាមរបៀបណាដែរ?

[១៤:២១:០១]

**ឆ៖** សូមបញ្ជាក់ម្តងទៀតឲ្យច្បាស់បន្តិចបាទ។

**ស៖** ខ្ញុំសូមចោទសំណួរនេះឲ្យងាយស្រួលជាងនេះបន្តិច។ នៅពេលដែលលោកផ្តល់សក្ខីកម្មចំពោះមុខអង្គជំនុំជម្រះ លោកបាននិយាយថា ការងារឃោសនារបស់លោកចំពោះមហាជន គឺថាមានប្រធានបទជាច្រើន លោកបានជម្រាបថា គឺមានការងារពិភាក្សាលើរបៀបបង្កបង្កើនផល និងកសិកម្ម។ លោកក៏បានជម្រាបផងដែរថា លោកជំរុញឲ្យមានឯកភាពជាតិ ការឧបត្ថម្ភខ្លួនដោយខ្លួនឯង ហើយនិងជាទូទៅគឺថាធ្វើយ៉ាងណាឲ្យជីវភាពប្រសើរឡើងជាងមុន។

សំណួរខ្ញុំដូចតទៅនេះ សំណួរទីមួយរបស់ខ្ញុំដូចតទៅនេះ បើតាមបទពិសោធន៍របស់លោក តើការនិយាយបែបនេះ ប្រជាជនទទួលយកតាមរបៀបណា យកការឃោសនារបស់លោកនេះយ៉ាងដូចម្តេចដែរ?

[១៤:២២:៣៤]

**ឆ៖** បាទ សូមឆ្លើយ ដំបូងសូមគូសបញ្ជាក់អំពីឯកភាពជាតិ។ ឯកភាពជាតិនេះ ខ្ញុំមិនបាន

និយាយទេ។ ខ្ញុំនិយាយតែ នយោបាយឯករាជ្យ ទីមួយ។ ទីពីរ លទ្ធផលដែលខ្ញុំខំឃោសនាអប់រំទៅដល់ប្រជាជន គឺប្រជាជនខំដាំដំឡូងជ្វា ដំឡូងមី ធ្វើស្រែប្រាំង លទ្ធផលនេះជាលទ្ធផលទីមួយ ខំដាំ ខំធ្វើតាម។ តែលទ្ធផលទីពីរ បានមកគួរសមដែរ តែមិនគ្រប់គ្រាន់ទេ ពីព្រោះកន្លែងដែលខ្ញុំឃោសនាអប់រំនោះវាត្រូវមួយផ្នែក ប្រជាជនហូបខ្លួនឯង តែមួយផ្នែកឧបត្ថម្ភដល់កងទ័ពដែលរើប្រចាំការនៅម្តុំនោះ។ នេះគឺជាលទ្ធផល។ សូមជម្រាបជូនប៉ុណ្ណឹងបាទ។

**ស៖** លោកបាននិយាយជាច្រើនដង ជាពិសេសក្នុងពេលដែលឆ្លើយសំណួរទៅមេធាវីដើមបណ្តឹងរដ្ឋប្បវេណី គាត់ថា គឺថាមានកង្វះខាតស្បៀង តើលោកអាចពន្យល់ប្រាប់អង្គជំនុំជម្រះបានទេ អំពីការខ្វះខាតផ្នែកទិន្នផល ការបង្កបង្កើនផលនៅក្នុងតំបន់ដែលលោកនៅនោះ ដែលលោកស្គាល់?

[១៤:២៤:៤៩]

**ឆ៖** សូមឆ្លើយ ទិន្នផល បើខ្ញុំយល់ថាជាតួលេខនៃផលដែលបាន។ ផលដែលបានក្នុងពេលនោះ សូមជម្រាបជូន គ្មានបានបូកសរុបអីទេ។ ដូច្នេះ គឺបានតាមជាក់ស្តែង បានប៉ុនណា ប៉ុណ្ណឹង។ ហើយតួលេខជាក់ស្តែង គឺសរុបមិនបាទទេបាទ។ តែគ្រាន់តែខ្ញុំបញ្ជាក់សាចុះសាឡើង ខ្ញុំយល់ថា មិនគ្រប់គ្រាន់តែប៉ុណ្ណឹងបាទ។

**ស៖** សំណួរខ្ញុំច្បាស់លាស់ជាងនេះ អម្បាញ់មិញ ខ្ញុំចង់ដឹងថា តើដោយសារមូលហេតុដែលថាសភាពដី ឬក៏វាមកពីមូលហេតុផ្សេងទៀត?

**ឆ៖** មូលហេតុ សូមជម្រាបបន្ថែម លើកទីមួយ ខ្ញុំបានបញ្ជាក់ថា វាជាមូលហេតុទាក់ទិនដល់រឿងដី។ ដីវាមិនស្មើគ្នា ដីតំបន់ខ្លះវាល្បាយខ្សាច់ ដីតំបន់ខ្លះវាធ្វើបានតែមួយរដូវ ហើយជាមូលហេតុទីមួយ។

[១៤:២៦:៣៨]

មូលហេតុទីពីរ ពេលក៏គ្មានបច្ចេកទេសអី ពេលវេលាអីទៅបណ្តុះបណ្តាលថា ត្រូវដាក់ជី ត្រូវដាក់ដាំបែបនេះ បែបនោះ វាអត់។ នេះជាមូលហេតុចម្បង។ មូលហេតុមួយទៀត ក៏ទម្ងន់រវាងអ្នកស៊ី ហើយអ្នកបង្កើនផលនោះ អ្នកផលិតនោះវាមិនតុល្យភាព ដល់អីចឹងហើយបានខ្ញុំមានសេចក្តីបញ្ជាក់ថា តាមខ្ញុំៗផ្ទាល់ជាបុគ្គលថា មិនគ្រប់គ្រាន់ទេបាទ។ នេះជាមូលដ្ឋានដែលខ្ញុំបានជម្រាបជូនបន្តបន្ទាប់។

**ស៖** តើនៅក្នុងលក្ខខណ្ឌនេះ តើជាការត្រឹមត្រូវទេក្នុងការនិយាយថា ស្ថានភាពនេះពិបាកៗកាន់តែពិបាកថែមទៀត ពីព្រោះយើងស្ថិតនៅក្នុងពេលសង្គ្រាម សម័យសង្គ្រាម តើត្រឹមត្រូវដែរឬទេ

ក្នុងការនិយាយយ៉ាងដូច្នេះ?

[១៤:២៨:១០]

**ឆ៖** ខ្ញុំសូមបញ្ជាក់បន្ថែម គឺអាចបញ្ជាក់បន្ថែមថា វាទាក់ទងនឹងសភាពការណ៍សង្គ្រាមដែរ ព្រោះការប្រមូលផ្តុំកម្លាំងទៅមុខ ទៅក្រោយដឹកជញ្ជូនក៏វាទាក់ទងដែរបាទ។

**សៈ** លោកសាក្សី ឥឡូវនេះ ខ្ញុំសូមចូលទៅចំណុចមួយទៀត លោកបាននិយាយថា នៅក្នុងចន្លោះឆ្នាំ៧៥ ដល់៧០-- អំ! ៧០ ដល់៧៥ លោកនៅក្នុងព្រៃម៉ាគី ហើយលោកក៏បានជម្រាបផងដែរថាលោកត្រូវធ្វើដំណើរជាញឹកញាប់ ដោយមូលហេតុសន្តិសុខ។ សំណួរខ្ញុំដូចតទៅនេះ តើការផ្លាស់ទីញឹកញាប់នេះធ្វើឱ្យលោកមានសន្តិសុខនុ៎ង តាមរបៀបណាដែរទៅ?

**ឆ៖** ន័យសន្តិសុខដែលជម្រាបជូនអង្គសវនាការនេះវាទូលំទូលាយណាស់ ហើយខ្ញុំនិយាយច្រូតកាត់បន្តិចហើយ។ សន្តិសុខពេលនោះ ធំជាងគេ គឺកប៉ាល់ហោះទម្លាក់គ្រាប់បែក។ ទីពីរ ក៏វាទាក់ទងអ្នកដែលគេឃើញថា មិនទុកចិត្តជាផ្នែកស៊ើបការណ៍អីចុះឡើង គេសង្ស័យ។ អ៊ីចឹង គេត្រូវតែផ្លាស់។ ផ្លាស់ខុសតែកន្លះគីឡូ គេរួចខ្លួនហើយ ឬយកល្អ មួយគីឡូពីរគីឡូអីអ៊ីចឹងទៅ គេរួចខ្លួនហើយ។ ទម្រាំកប៉ាល់ហោះហ្នឹង ចាប់ចំណុចបានថ្មីទៀត គេតាមហ្នឹងទៀត។ នេះ ក្នុងសភាវសង្គ្រាម។ ដូច្នេះ ន័យវាទូលំទូលាយ អ៊ីចឹង បានខ្ញុំជម្រាបថា ទាក់ទិននឹងបញ្ហាសន្តិសុខ ត្រូវផ្លាស់កន្លែង បាទ។

**សៈ** នៅពេលដែលលោកឆ្លើយតបទៅនឹងសំណួររបស់សហព្រះរាជអាជ្ញាអន្តរជាតិ គឺខ្ញុំមិនចាំថា ម្សិលមិញ ឬក៏មុនម្សិលមិញទៀតទេ។ លោកបាននិយាយយ៉ាងច្បាស់ថា ការទម្លាក់គ្រាប់បែកហើយលោកសហព្រះរាជអាជ្ញាបានធ្វើការកត់សម្គាល់ថា នៅឆ្នាំ៧៣នោះ លែងមានការទម្លាក់គ្រាប់បែកទៀតហើយ។ ហើយសំណួរខ្ញុំដូចតទៅទនេះ តើលោកដឹងដែរឬទេ ថាទាហាន លន់ នល់ មានកងកប៉ាល់ហោះ ទាហានជើងអាកាស តើលោកដឹងដែរឬទេ?

[១៤:៣១:៥០]

**ឆ៖** សូមជម្រាបជូន គូប្រយុទ្ធជាមួយគ្នា ពេលនុ៎ងមានតែភាគី លន់ នល់ ហើយនិងភាគីខាងរណសិរ្ស។ ដូច្នោះ ភាគីខាង លន់ នល់ ដែលមានអាមេរិកនៅពីក្រោយ ពិតជាមានកប៉ាល់ហោះហើយអ្នកដែលមកទម្លាក់។ ពីព្រោះបើមិនអ៊ីចឹងទេ វាមិនអាចមានការរងគ្រោះ ដូចលោកបានជ្រាបអស់ហើយ។ តែឯកប៉ាល់ហោះនុ៎ង វានៅក្នុងអង្គភាពណា? លេខប៉ុន្មាន? ឈ្មោះអី? ខ្ញុំមិនស្គាល់ទេ បាទ។

**ស៖** សូមអរគុណលោកសាក្សី។ ឥឡូវនេះ ខ្ញុំសូមចោទទៅសួរសំណួរផ្សេងទៀត លោកប៉ុន្មានថ្ងៃកន្លងមកនេះ លោកបាននិយាយអំពីតំណែងផ្សេងៗ ដែលលោកបានកាន់កាប់ ជាពិសេស-- ជាដំបូងក្នុងពេលធ្វើបដិវត្តន៍ ហើយបន្ទាប់មកទៀត នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។ បើសិនជា ខ្ញុំយល់មិនច្រឡំទេ ដំបូងបំផុត លោកជាសាស្ត្រាចារ្យ ហើយបន្ទាប់មកទៀត ទទួលបន្ទុកខាងផ្សព្វផ្សាយអប់រំជាឆ្នាំ ហើយបន្ទាប់មកទៀត លោកធ្វើការនៅក្រសួងការបរទេសនៅក្នុងផ្នែកពិធីការ។ តើខ្ញុំធ្វើសេចក្ដីសង្ខេបនេះ ត្រឹមត្រូវដែរឬទេ?

**ឆ៖** សូមជម្រាប រំឭកឡើងវិញ ខ្ញុំថ្នាក់ឌីប្លូម។ ចេញធ្វើគ្រូ ជាលោកគ្រូបឋមសិក្សា ដូច្នេះមិនមែនសាស្ត្រាចារ្យទេ ហ្នឹងទីមួយ។ ហើយបឋមសិក្សា គឺបង្រៀនកូនក្មេង មិនមែនបង្រៀននិស្សិតទេបាទ។ ទីពីរ សំណួរលោកវែងបន្តិចដែរ ខ្ញុំឆ្លើយអាចមិនអស់ គឺតួនាទីខ្ញុំ ខ្ញុំបានជម្រាបបន្តបន្ទាប់ ថាខ្ញុំជាឃោសនិក បុគ្គលមួយដែលពេលនោះ គេត្រូវការ។ ធម្មតា គ្រូបង្រៀនចេះបង្រៀន ចេះនិយាយ ដូច្នេះជំនាន់នុំង គេត្រូវការអ្នកចេះឃោសនាអី ល្មមប្រជាជនស្ដាប់បាន។ អ៊ីចឹងជាឃោសនិករហូត។ ដល់មកចុងក្រោយបង្អស់នេះ បានមកទទួលនាទីជាពិធីការមួយផ្នែក។ បាទ នេះសូមជម្រាបបានប៉ុណ្ណឹងបាទ។

**ស៖** សូមអរគុណដែលបានបញ្ជាក់បំភ្លឺលោក នី កន។ តើជាការត្រឹមត្រូវដែរទេក្នុងការនិយាយថា ក្រៅពីតំណែងដែលលោកមាននោះ តើលោកពុំមានកាន់តំណែងអ្វីផ្សេងទៀតទេ នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ?

[១៤:៣៥:៥១]

**ឆ៖** ខ្ញុំទទួលតំណែងក្នុងផ្នែកគេហៅថា គណៈផ្នែកអប់រំ ឃោសនាអប់រំ ហើយឃោសនាអប់រំនោះរហូត ពីព្រោះគេត្រូវការដូចខ្ញុំបញ្ជាក់អំមិញអ៊ីចឹង អ្នកដែលមានសមត្ថភាពឃោសនាអប់រំក្នុងតំបន់នីមួយៗគេត្រូវការអ៊ីចឹង។ ដូច្នេះ ខ្ញុំនៅក្នុងតំណែងឃោសនាអប់រំនេះ ប៉ុន្តែវាមិនមែនឃោសនាអប់រំអីទូទាំងភូមិភាគ ឬទូទៅអីទេ វាទៅតាមផ្នែកដែលក្របខ័ណ្ឌដែលគេកំណត់បាទ។

**ស៖** លោកសាក្សី ខ្ញុំយល់ហើយ។ សំណួរខ្ញុំនោះគឺថា ចង់បញ្ជាក់ថា ក្រៅតំណែងដែលលោកមាននោះ តើលោកមានកាន់តំណែងផ្សេងទៀតដែរឬទេ នៅក្នុងកម្ពុជាប្រជាធិបតេយ្យនោះ?

**ឆ៖** ជម្រាបដដែលបាទ។ តំណែងដែលខ្ញុំទទួលហ្នឹង គឺទទួលក្នុងជាមួយនឹងគណៈកម្មការអប់រំហ្នឹងហើយ។ ខ្ញុំជាបុគ្គលមួយនៅជាមួយខាងហ្នឹងបាទ។ ហើយក្រោយមកបានតំណែងច្បាស់--

តំណែងដែលទទួលបន្ទាប់មក ដែលត្រូវដកហូតមកខាងក្រសួងហ្នឹងគឺ ពិធីការបាទ។ បើចន្លោះពេលដែលលោកសួរហ្នឹង គឺប៉ុណ្ណឹងបាទ។

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ឥឡូវនេះម៉ោងបីម្ភៃនាទីហើយ ខ្ញុំត្រូវការពេលបន្តិចទៀតទេ។ តើលោកប្រធានអនុញ្ញាតឲ្យខ្ញុំបន្តសួរតទៅទៀត ហើយយើងអាចរំកិលពេលសម្រាកបន្តិចទៀត ឬក៏យ៉ាងម៉េចលោកប្រធាន?

[១៤:៣៨:១៦]

**ប្រធានអង្គជំនុំ៖**

តើលោកស្រីមេធាវី ត្រូវការពេលវេលាប៉ុន្មានទៀតក្នុងការតាំងសំណួរដេញដោល ចំពោះសាក្សីដើម្បីបញ្ចប់នូវសំណួររបស់លោកស្រី?

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធាន ខ្ញុំត្រូវការពេលតែប្រាំនាទីទេលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សូមលោកស្រីបន្តការតាំងសំណួរឲ្យចប់សំណួររបស់លោកស្រីចុះ!

**កញ្ញា អង់តា ហ្គីសសេ៖**

សូមអរគុណលោកប្រធាន។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី មូលហេតុដែលខ្ញុំចង់ឲ្យលោកបញ្ជាក់ពីតំណែងផ្សេងៗ ដែលលោកកាន់កាប់ពីមុននោះគឺថា ខ្ញុំចង់ឲ្យច្បាស់ថា លោកពុំដែលបានកាន់មុខងារនៅក្នុងការផ្សព្វផ្សាយព័ត៌មាននៅក្រោមរបបកម្ពុជាប្រជាធិបតេយ្យនោះទេ។ តើលោកធ្លាប់ធ្វើការនៅផ្នែកផ្សព្វផ្សាយ-- ផ្នែកទំនាក់ទំនងនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្មាឯល៖**

សូមអរគុណលោកប្រធាន។ ខ្ញុំគិតថា សំណួរនេះមិនច្បាស់លាស់ទេ។ តើផ្នែកទំនាក់ទំនងហ្នឹង

មានន័យថាយ៉ាងម៉េច? ព្រោះថា សាក្សីធ្វើការនៅក្នុងឃោសនាការ ហើយប្រហែលជាមានផ្នែកមួយ ដែលហៅថា ទំនាក់ទំនងហើយ។ អ៊ីចឹងគួរតែចោទសំណួរឡើងវិញ ហើយនិងបំភ្លឺឡើងវិញ ដើម្បីឲ្យ យើងយល់ឲ្យច្បាស់ពីផ្នែក ដែលហៅថាផ្នែកទំនាក់ទំនងនេះ។

[១៤:៤០:០០]

**កញ្ញា អង់តា ហ្គីសសេ៖**

លោកប្រធានមិនមានបញ្ហាអីទេ ខ្ញុំនឹងបំភ្លឺ។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី តើលោកមិនដែលធ្វើការនៅក្នុងផ្នែក ដែលទទួលបន្ទុកក្នុងការផ្ញើទូរលេខ ដែរ ទេឬ? មិនដែលទេឬ ?

**លោក នី កន៖**

**ឆ៖** សូមជម្រាបជូន ក្នុងពេលនោះ តំបន់នៅដាច់ពីគ្នា គេមានការទាក់ទងទូរលេខដែរ តែមិន មែនក្របខ័ណ្ឌពួកខ្ញុំទេ។ ដូច្នេះខ្ញុំមានត្រឹមតែសរសេរជូនតាមសំបុត្រទៅ រួចហើយ-- តែចាំបាច់បាន សរសេរ គឺអ្វីដែលទាក់ទងដល់ការងារ។ ហើយសរសេរទៅ គេយកទៅវាយយ៉ាងម៉េច អាហ្នឹងខ្ញុំមិនដឹង ទៅតាមតែខ្លឹមសារដែរលេគត្រួតពិនិត្យ គេវាយយ៉ាងម៉េចអាហ្នឹងជារឿងមួយទៀតរបស់អ្នកបច្ចេក ទេសបាទ។ ហើយការត្រួតពិនិត្យពីផ្នែកដែលគេទទួលខុសត្រូវ។

[១៤:៤១:២៨]

**ស៖** ដូច្នេះជាការត្រឹមត្រូវក្នុងការនិយាយថា លោកមិនដឹងថានៅក្នុងទូរលេខទាំងអស់នេះថា ត្រូវបានផ្ញើ ឬក៏ទទួលនៅក្នុងលក្ខខណ្ឌណានោះទេ នៅក្នុងការិយាល័យមន្ទីរ៨៧០ នោះ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកតំណាងសហព្រះរាជអាជ្ញា!

សាក្សីកុំអាលទាន់ឆ្លើយតបនឹងសំណួរនេះ!

**លោក វ៉ាំងសង់ វ៉ាយដ៍ ដេស្សាងលេ៖**

លោកប្រធាន យើងសួរ គឺថាចេញពីសំណួរទូទៅចូលទៅសំណួរទាក់ទងនឹងទូរលេខ យើងមិន ដឹងថា នៅក្នុងភូមិភាគបស្ចិម ឬក៏ទីណាទេ។ ព្រោះថាសំណួរដែលពាក់ព័ន្ធនឹងភូមិភាគបស្ចិមនេះអាច ទាក់ទងទៅនឹងក្រសួងការបរទេសដែរ ប៉ុន្តែខ្ញុំមិនច្បាស់ទេ។ ឥឡូវនេះ យើងចូលទៅដល់សំណួរនិយាយ

អំពីសំណួរដែលយោងទៅទូរលេខ ដែលយើងបាននិយាយពីម្សិលមិញ ដែលពាក់ព័ន្ធនឹងក្រសួងការបរទេស ដែលក្នុងនោះមាននិយាយពីមន្ទីរ៨៧០ផងដែរ។ ខ្ញុំគិតថាចន្លោះរវាងសំណួរទាំងពីរនេះ ត្រូវតែមានសំណួរ-- អន្តរសំណួរច្រើនទៀត ដើម្បីឲ្យឈានចូលទៅដល់ប្រធានបទជាក់លាក់មួយ។ ហើយយ៉ាងហោចណាស់ក៏ត្រូវតែបញ្ជាក់ឲ្យលោកសាក្សីឲ្យដឹងអំពីរយៈពេលថា យើងនិយាយអំពីរយៈពេលណានៃរយៈនៃការផ្ញើទូរលេខរវាងតំបន់ទាំងអស់នេះ។ ដូច្នេះ ខ្ញុំហាក់ដូចជាវង្វេងបន្តិចហើយ ថាមិនដឹងថាគាត់យោងទៅរយៈពេលណានោះទេ។ ហើយអ៊ីចឹងសូមអរគុណលោកប្រធាន។ ខ្ញុំសូមបញ្ចប់ត្រឹមហ្នឹង។

[១៤:៤៣:០៨]

**កញ្ញា អង់តា ហ្គីសសេ៖**

ខ្ញុំសូមបញ្ជាក់សំណួរខ្ញុំ ដើម្បីបំភ្លឺទៅដល់លោកសាក្សី។

**សួរដោយកញ្ញា អង់តា ហ្គីសសេ៖**

**ស៖** លោកសាក្សី តើលោកដឹងថានៅក្នុងលក្ខខណ្ឌណាទូរលេខទាំងអស់នេះ ត្រូវបានផ្ញើចេញទៅនៅពេលដែលលោកធ្វើការនៅក្នុងតំបន់-- នៅក្នុងភូមិភាគបស្ចិម?

**លោក នី កន៖**

**ឆ៖** ខ្ញុំសូមជម្រាបជូន តាមខ្ញុំចាំអ្នកដែលមានសិទ្ធិកាន់ទូរលេខពេលនោះគឺមានតែភូមិភាគ។ ឯតំបន់គ្មានទេ។ ស្រុកមកក្រោមទៀត រឹតតែវាគ្មានទៅហើយបាទ។ ដូច្នេះគេមានតែផ្ញើសំបុត្រស្នាមរបស់គេខ្លីៗប៉ុណ្ណឹង។ ហើយភូមិភាគយកទៅវាយសរុបយ៉ាងម៉េចអីយ៉ាងម៉េច អាហ្នឹងនៅលើការទទួលខុសត្រូវរបស់ភូមិភាគបាទ។

**ស៖** បើខ្ញុំយល់ពីសំណួរ-- ចម្លើយរបស់លោក អ៊ីចឹងបានន័យថាលោកមិនដឹងថាគេផ្ញើទូរលេខហ្នឹងយ៉ាងដូចម្ដេចទេ? តើអ៊ីចឹងមែនទេ?

[១៤:៤៤:៤៧]

**ឆ៖** បាទ សូមចម្លើយខ្ញុំដែលឆ្លើយអំមិញហ្នឹងវាលំនាំហ្នឹងហើយ គឺថាខាងក្រោមដឹងតែថាសរសេររាយការណ៍អ៊ីចឹងទៅ រួចខាងលើបញ្ជូនបន្តទៅទៀត យ៉ាងម៉េច អាហ្នឹងនៅលើៗភារកិច្ចខាងលើ។

**ស៖** ហើយចំណុចចុងក្រោយ ដើម្បីបញ្ជាក់ឲ្យច្បាស់។ តើលោកដឹងថា គេផ្ញើទូរលេខយ៉ាង

ម៉េចដែរឬទេ នៅពេលដែលលោកធ្វើការនៅក្រសួងការបរទេសនោះ?

**ឆ៖** ចំពោះសំណួរនេះ គឺវាទាក់ទិននឹងភូមិសាស្ត្រ ហើយវាទាក់ទិននឹងការប្រតិបត្តិជាក់ស្តែងរបស់ក្រសួង។ ពីមុនបើនៅឆ្ងាយ បានគេប្រើទូរលេខ តែបើនៅជិត គេមិនប្រើទេ។ តែខ្ញុំគ្រាន់តែ ចម្លើយខ្ញុំចូលក្នុង (ខ) ដែលអាចសន្និដ្ឋាន អាចជា (ខ) ដែលអាចប្រើពាក្យថាសន្និដ្ឋានហើយ។ ខ្ញុំមិនដឹងពិតនោះយ៉ាងណាទេបាទ។

[១៤:៤៦:៣១]

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ ដែលអាចថាច្បាស់លាស់មែនទែន។ តើនៅក្នុងមុខការរបស់លោក នៅក្នុងក្រសួងការបរទេសនោះ តើការផ្ញើទូរលេខនេះជាមុខការរបស់លោកមួយដែរឬទេ?

**ឆ៖** សុំឆ្លើយ មិនមែនជាមុខការរបស់ខ្ញុំទេបាទ។

**ស៖** សូមអរគុណលោកសាក្សី ហើយសូមអរគុណពីការអត់ធ្មត់របស់លោក ហើយសុំ-- ហើយខ្ញុំលែងមានសំណួរអី ដើម្បីចោទសួរទៅសាក្សីទៀតហើយលោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។

លោកស្រី សែ កុលវត្តី សាក្សីដែលអង្គជំនុំជម្រះបានបម្រុងទុកសម្រាប់ចុងសប្តាហ៍នេះ តើគាត់មានវត្តមានដែរឬទេ នៅក្នុងរសៀលនេះ?

**ក្រឡាបញ្ជី៖**

សូមជម្រាបលោកប្រធាន សាក្សីដែលអង្គជំនុំជម្រះកោះហៅមកផ្តល់សក្ខីកម្មបន្ទាប់ពីសាក្សី នី កន គឺសាក្សីដែលមានរហស្សនាម TCW-583។ សាក្សីរូបនេះមានវត្តមាននៅបន្ទប់រង់ចាំ។ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។ សាក្សីបានបញ្ជាក់ថា តាមសមត្ថភាពដែលគាត់អាចដឹង គឺគាត់មិនមានទំនាក់ទំនងញាតិលោហិត ឬញាតិពន្ធជាមួយនឹងជនជាប់ចោទ ឬភាគីដើមបណ្តឹង រដ្ឋប្បវេណីណាមួយនោះទេ។ សាក្សីបានធ្វើសម្បថរួចហើយ នៅចំពោះមុខអ្នកតាដំបងដែក កាលពីថ្ងៃ២១ ខែឧសភា ឆ្នាំ២០១២។

[១៤:៤៨:១៩]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ អរគុណលោក នី កន ដែលបានចំណាយពេលវេលាដ៏មានតម្លៃចូលរួមនៅក្នុង

ការផ្តល់សក្ខីកម្មតាមការកោះហៅរបស់អង្គជំនុំជម្រះ ហើយប្រកបដោយភាពអំណត់ធ្មត់ និងខិតខំប្រឹងប្រែងឆ្លើយតបទៅនឹងសំណួររបស់ភាគីដែលពាក់ព័ន្ធ ច្រើនសំណួរក្នុងរយៈពេលប៉ុន្មានថ្ងៃកន្លងមកនេះ។ ហើយឥឡូវនេះ ដោយសារកិច្ចដំណើរការនៃការស្តាប់សក្ខីកម្មរបស់លោក ពាក់ព័ន្ធទៅនឹងសំណុំរឿងនេះ ឃើញថាដល់ទីបញ្ចប់ហើយ ហើយអង្គជំនុំជម្រះមិនទំនងជាមិនមានអ្វីត្រូវសាកសួរដល់លោកសាក្សីទៀតទេ។ ហេតុដូច្នេះ លោកសាក្សីអាចវិលត្រឡប់ទៅលំនៅដ្ឋាន ឬក៏គោលដៅដែលលោកចង់ទៅវិញបានហើយ។ ហើយមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីនៃអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ក្នុងការបញ្ជូនសាក្សីវិលត្រឡប់ទៅកាន់ទីលំនៅដ្ឋានរបស់គាត់វិញ ឬក៏ទៅគោលដៅដែលគាត់មានបំណងចង់ទៅ។ សូមប្រកបដោយសុវត្ថិភាព!

អង្គជំនុំជម្រះ សូមជម្រាបជូនភាគី និងសាធារណជនថា នៅម៉ោងបន្ទាប់ពីសម្រាកនេះ គឺអង្គជំនុំជម្រះនឹងបន្តស្តាប់សក្ខីកម្មរបស់សាក្សី TCW-583។ ហើយការតាំងសំណួរចម្បង ហើយនិងដំបូងគេបង្អស់ គឺអង្គជំនុំជម្រះនឹងប្រគល់ទៅឲ្យភាគីតំណាងសហព្រះរាជអាជ្ញា ដើម្បីសួរដេញដោលសាក្សីមុនភាគីដទៃទៀត ក្រោយពីអង្គជំនុំជម្រះសួរនូវសំណួរបឋមមួយចំនួន។

ឥឡូវនេះ ដល់ពេលសមល្មមនឹងសម្រាកហើយ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ចាប់ពីពេលនេះតទៅ រហូតដល់ម៉ោងបួនដប់នាទី សូមអញ្ជើញចូលវិញ-- អ៎! ម៉ោងបីៗដប់នាទី សូមកែតម្រូវ! គឺម៉ោងបីដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចដំណើរការសវនាការ។

សម្រាកចុះ!

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការសម្រាកពីម៉ោង ១៤:៥០ នាទី ដល់ម៉ោង ១៥:១១ នាទី)*

[១៥:១១:០៩]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរនីតិវិធីសវនាការ។

មន្ត្រីរដ្ឋបាលតុលាការអញ្ជើញសាក្សីTCW-583 ចូលមកកាន់កន្លែងផ្តល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការ។

*(សាក្សីចូលមកក្នុងបន្ទប់សវនាការ)*

[១៥:១៣:១២]

មន្ត្រីរដ្ឋបាលតុលាការអាចកិលអានោះទៅមុខបន្តិច ហើយងាកអីចេះ ងាកបញ្ឆិតបន្តិចដើម្បីឲ្យគាត់អាចមើលឃើញភ្លើង ជាសញ្ញាថាក្បាលមីក្រូប្រតិបត្តិការដើម្បីគាត់ទៅឆ្លើយណ៎ា។

សួស្តីលោកសាក្សី ថ្ងៃនេះអង្គជំនុំជម្រះកោះហៅលោកមកផ្តល់សក្ខីកម្ម។ ហើយមុននឹងដំណើរទីមួយ អង្គជំនុំជម្រះសូមណែនាំលោកនៅក្នុងការឆ្លើយតបទៅនឹងសំណួរ ដែលភាគី ឬអង្គជំនុំជម្រះតាំងសំណួរចំពោះលោក ដោយនៅទីនេះប្រើភាសាបី ខ្មែរ អង់គ្លេស និងបារាំង ដែលឆ្លងកាត់ប្រព័ន្ធបកប្រែភាសា។ ដូច្នេះនៅពេលដែលតាំងសំណួរ និងការឆ្លើយតបនេះត្រូវមានគម្លាតគ្នាបន្តិច ដើម្បីរង់ចាំទុកពេលវេលាឲ្យអ្នកបកប្រែភាសាហ្នឹងបកទាន់ ត្រឹមត្រូវ ពេញលេញនូវអ្វីដែលភាគី ឬក៏លោកឆ្លើយ។

ហើយឥឡូវនេះ គឺអង្គជំនុំជម្រះបានរៀបចំជាមួយនឹងខាងផ្នែកខាងបច្ចេកទេស ដើម្បីសម្រួល គឺលោកមិនបាច់ចុចទេ គឺគេនឹងរៀបចំជូន ហើយពេលនោះលោកគ្រាន់តែរង់ចាំមើលភ្លើងក្រហមនៅក្បាលមីក្រូនេះលោកអាចឆ្លើយបានហើយ។ បើមិនទាន់មានសញ្ញាក្បាលក្រហមនេះទេ មានន័យថាក្បាលមីក្រូហ្នឹងមិនទាន់អាចប្រតិបត្តិការបានទេ អ៊ីចឹងគឺលោកកុំអាលទាន់ឆ្លើយ ដើម្បីឲ្យនីតិវិធីនឹងវាប្រព្រឹត្តទៅបានរហ័ស និងជាក់ច្បាស់ បាទទីមួយ។

[១៥:១៤:៤៤]

ហើយទីពីរ អង្គជំនុំជម្រះមុននឹងចាប់ផ្តើមសួរដេញដោលចំពោះលោកនូវសំណួរសារធាតុ អង្គជំនុំជម្រះសូមតាំងសំណួរមួយចំនួនពាក់ព័ន្ធនឹងប្រវត្តិសាវតាររបស់លោក។

**ការតាំងសំណួរដោយចៅក្រម**

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** តើលោកសាក្សីឈ្មោះអ្វីដែរ?

**លោក សគីម លួត៖**

**ឆ៖** សូមគោរពប្រធាន និងលោកស្រីចៅក្រម និងអង្គចៅក្រមទាំងមូល សូមគោរព។ ខ្ញុំបាទឈ្មោះ សគីម លួត ថ្ងៃកំណើតអីហ្នឹង។ ខ្ញុំបាទឈ្មោះ សគីម លួត កើតនៅឆ្នាំ១៩៣១ នៅស្រុកឈូកខេត្តកំពត។

**ស៖** បាទ អរគុណ។ តើក្រៅពីឈ្មោះ សគីម លួត ហ្នឹងតើលោកមានធ្លាប់ប្រើឈ្មោះអ្វីផ្សេងពី

នេះដែរឬទេ? ជាពិសេសនៅក្នុងសម័យកាលធ្វើបដិវត្តន៍៧០-៧៥ ឬវាង៧៩។

[១៥:១៦:០១]

**ឆ៖** បាទ មាន គឺឈ្មោះ មី។

**ស៖** បាទ អរគុណ។ ហើយតើលោកមានទីលំនៅសព្វថ្ងៃនៅទីកន្លែងណាដែរ?

**ឆ៖** ផ្ទះលេខ៤២ ផ្លូវ២៣៤ ផ្សារទួលគោក ភ្នំពេញ អឺ! ផ្សារដើមគរ ខណ្ឌទួលគោក។

**ស៖** បាទ អរគុណ។ តើឪពុករបស់លោក-- ឪពុកបង្កើតរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ វ័ត្ន សគីម។

**ស៖** បាទ អរគុណ។ ចុះម្ដាយបង្កើតរបស់លោកគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ ញ៉ុក សាគុន។

**ស៖** ចុះប្រពន្ធរបស់លោក តើគាត់ឈ្មោះអ្វីដែរ?

**ឆ៖** ឈ្មោះ អ៊ុក សាម៉ាល់។

[១៥:១៧:០៥]

**ស៖** លោកមានកូនប៉ុន្មាននាក់?

**ឆ៖** ខ្ញុំមានកូនបួននាក់។

**ស៖** បាទអរគុណ។ លោក សគីម ល្មុត តាមរបាយការណ៍របស់ក្រឡាបញ្ជីសវនាការអម្បាញ់មិញនេះ គាត់បានរាយការណ៍ថា តាមសមត្ថភាពដែលលោកបានដឹង លោកមិនមានជាប់ញាតិលោហិត ឬក៏ញាតិពន្ធជាមួយគូភាគី មានដើមបណ្ដឹងរដ្ឋប្បវេណី ហើយនិងជនជាប់ចោទទាំងបីរូបនៅក្នុងរឿងក្ដីនេះទេ។ តើរបាយការណ៍របស់ក្រឡាបញ្ជីដែលរាយការណ៍ដូច្នេះ ជាការត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ ជាការត្រឹមត្រូវបាទ។

**ស៖** ហើយក្រឡាបញ្ជីក៏បានរាយការណ៍ថា លោកបានធ្វើសម្បថរួចហើយនៅចំពោះមុខអ្នកតាដំបងដែកមុននឹងលោកចូលមកផ្ដល់សក្ខីកម្មនេះ គឺលោកធ្វើកាលពីថ្ងៃទី២១ កន្លងមក តើជាការពិតដែរឬទេ?

[១៥:១៨:១០]

**ឆ៖** បាទ នេះជាការពិត។

**ស៖** បាទ អរគុណ។ ឥឡូវនេះអង្គជំនុំជម្រះសូមជម្រាបជូនលោកអំពីសិទ្ធិ និងករណីយកិច្ចក្នុង

នាមលោកជាសាក្សីនៅចំពោះមុខអង្គជំនុំជម្រះ។ ក្នុងនាមលោកជាសាក្សីនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការនៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងនេះ លោកអាចបដិសេធក្នុងការឆ្លើយតបទៅនឹងសំណួរ ឬការធ្វើអំណះអំណាងណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង។ សិទ្ធិមិនធ្វើសក្ខីកម្មប្រឆាំងនឹងខ្លួនឯង។ មានន័យថា ដោយសារតែចម្លើយ ឬអំណះអំណាងរបស់លោកនោះ នាំឱ្យលោកនឹងត្រូវទទួលរងការចោទប្រកាន់។

ហើយទន្ទឹមនឹងនេះដែរ គឺអង្គជំនុំជម្រះសូមជម្រាបអំពីករណីយកិច្ចរបស់លោក ក្នុងនាមលោកជាសាក្សី លោកត្រូវតែផ្តល់សក្ខីកម្មក្នុងកិច្ចដំណើរការនីតិវិធីចំពោះមុខអង្គជំនុំជម្រះនេះ គឺត្រូវឆ្លើយតបទៅនឹងសំណួរទាំងឡាយដែលភាគី ឬអង្គជំនុំជម្រះបានតាំងសំណួរចំពោះលោក លើកលែងតែក្នុងករណីឆ្លើយទៅនឹងសំណួរ ឬការធ្វើអត្ថាធិប្បាយណាមួយ ឬច្រើនដែលនាំឱ្យដាក់ពិរុទ្ធភាពលើខ្លួនឯង ដូចអង្គជំនុំជម្រះបានជម្រាបជូនខាងលើអម្បាញ់មិញនេះ។

[១៥:១៩:២២]

ហើយលោកជាសាក្សីត្រូវតែឆ្លើយ តែការណ៍ណាដែលពិត ដែលលោកបានដឹង បានឮ បានឃើញ បានចងចាំ ឬបានឆ្លងកាត់នូវបទពិសោធន៍តាមរយៈការជួបប្រទះ ឬការធ្វើសង្កេតកន្លងមកដោយផ្ទាល់នូវហេតុការណ៍ ព្រឹត្តិហេតុទាំងឡាយដែលពាក់ព័ន្ធនឹងសំណួរដែលភាគី ឬចៅក្រមនៃអង្គជំនុំជម្រះសាលាដំបូងតាំងសំណួរចំពោះលោក។ តើលោកយល់អំពីបញ្ហានេះទេ?

**ឆ៖** បាទ បានយល់ហើយបាទ។

**ប្រធានអង្គជំនុំ៖**

បាទ អរគុណ។ ហើយជាដំបូងនេះ អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីអាចតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ មុនភាគីដទៃទៀត។

សូមអញ្ជើញតំណាងសហព្រះរាជអាជ្ញា!

**លោក វ៉េង ហ៊ាត់៖**

អរគុណលោកប្រធាន។ សូមគោរពលោក លោកស្រីចៅក្រម នៃអង្គជំនុំជម្រះទាំងមូល។ សូមគោរពភាគី ដែលបានចូលរួមនៅក្នុងអង្គសវនាការនេះ និងសូមគោរពប្អូនៗ លោក លោកស្រី ដែលបានចូលរួមស្តាប់នៅខាងក្រៅអង្គសវនាការនេះ។

[១៥:២០:៤៦]

**ការតាំងសំណួរដោយសហព្រះរាជអាជ្ញា**

**សួរដោយលោក វ៉េង ហ៊ត់៖**

សួស្តី លោក ល្អុត ខ្ញុំសូមណែនាំ ខ្ញុំមកពីការិយាល័យសហព្រះរាជអាជ្ញា។ ខ្ញុំឈ្មោះ វ៉េង ហ៊ត់ បាទ។

**ស៖** តើលោកស្តាប់ខ្ញុំឮទេ?

**លោក សគីម ល្អុត៖**

**ឆ៖** បាទ ឮបាទ។

**ស៖** សំណួរដែលខ្ញុំនឹងសួរលោក នៅពេលលើកទីមួយនេះ គឺខ្ញុំចង់ដឹងអំពីរចនាសម្ព័ន្ធថ្នាក់មូលដ្ឋានរបស់កម្ពុជាប្រជាធិបតេយ្យ របៀបនៃការចូលជាសមាជិករបស់បក្ស អាហ្នឹងទីមួយ។ អ៊ីចឹងខ្ញុំសួរលោក លោកស្គាល់ចលនាខ្មែរក្រហមនៅពេលណាដែរ?

**ឆ៖** ខ្ញុំមិនចាំថ្ងៃឆ្នាំច្បាស់ទេ ប៉ុន្តែអាចថាបាននៅក្នុងសម័យសង្គមរាស្ត្រនិយម មុននឹងបន្តិចបន្តួច បាទ។ ខ្ញុំមិនចាំថ្ងៃខែច្បាស់ទេ។

[១៥:២២:៣៥]

**ស៖** របៀបនៃការចូលជាចលនាខ្មែរក្រហមនេះ គេណែនាំលោក ឬក៏របៀបនៃការចូលនេះយ៉ាងម៉េចដែរ? សូមលោកជួយរៀបរាប់ផង។

**ឆ៖** ការចូលនេះ គឺថាតាមមានការណែនាំមិត្តភក្តិផង ហើយក៏ប្រជុំអីជាមួយគ្នាអ៊ីចឹងទៅ។ របៀបអ៊ីចឹងបាទ។

**ស៖** ការណែនាំនេះ គេមកប្រាប់លោកជារបៀបជាសាធារណៈតែម្តង ឬមួយក៏គេណែនាំយើងរបៀបជាសម្ងាត់?

[១៥:២៣:៣០]

**ឆ៖** បាទ វាជាសម្ងាត់ទេ។

**ស៖** នៅក្នុងស្ថានភាពដែលគេណែនាំ ឬក៏ហៅអញ្ជើញលោកចូលបដិវត្តន៍ជាសម្ងាត់ តើគេមានអញ្ជើញលោកទៅធ្វើការប្រជុំអីទេ?

**ឆ៖** *(មីក្រូហ្វូនមិនទាន់ដំណើរការ)* បាទសូមទោស មានការប្រជុំដែរ ជាមួយអ្នកដែលទៅណែនាំ ស្គាល់គ្នាហ្នឹង ហើយជារយៈៗ មានការប្រជុំ។

**ស៖** តើប្រជុំនៅទីកន្លែងណា? ហើយលោកអាចចាំឆ្នាំទេ ពេលនុ៎ង?

**ឆ៖** ខ្ញុំមិនចាំឆ្នាំទេ ប៉ុន្តែការប្រជុំនេះ អាចក៏ម្ដងនៅកន្លែងនេះ ផ្ទះអ្នកនេះ ផ្ទះអ្នកនោះ អ៊ីចឹងទៅ។ ខ្ញុំមិនចាំឆ្នាំទេ។

**ស៖** ពេលនុ៎ងអ្នកណានាំលោកចូលបដិវត្តន៍?

**ឆ៖** ខ្ញុំមិនចាំថា ឈ្មោះអ្នកណាទេ ប៉ុន្តែថា វាមានគ្នាប៉ុន្មាននាក់អ៊ីចឹងទៅ ប្រជុំគ្នាទៅ ហើយបន្តិចម្ដងៗទៅ វានៅក្នុងចលនាហ្នឹងទៅ។ ខ្ញុំមិនចាំថា ឈ្មោះណាៗទេ។

**ស៖** ហើយគេមានប្រាប់លោកថា ចូលបដិវត្តន៍ហ្នឹងដោយសារមូលហេតុអីទេពេលនុ៎ង?

**ឆ៖** ពេលនុ៎ងថា ដូចថាមានបញ្ហាក្នុងសង្គម ហើយត្រូវការឲ្យមានប្រទេសជាតិហ្នឹង រីកចម្រើន អត់អំពើពុករលួយអីអ៊ីចឹង មានតែប៉ុណ្ណឹងបាទ។

**ស៖** ក្នុងពេលចូលបដិវត្តន៍ដំបូង តើគេមានប្រាប់លោក ឬក៏ឲ្យលោករៀបចំប្រវត្តិរូបឬទេ?

**ឆ៖** អត់មានទេ។

**ស៖** ខ្ញុំសួរថយក្រោយបន្តិច។ នៅក្នុងពេលដែលលោកថា ប្រជុំនោះតើពេលនោះគេមានគោលការណ៍ទិតៀន និងស្វ័យទិតៀនហើយឬនៅពេលនុ៎ង?

[១៥:២៧:០៣]

**ឆ៖** ពេលដំបូងឡើងដូចជា ខ្ញុំចាំដូចជា បែបមិនមានអីទេមិនមានទិតៀន ស្វ័យទិតៀនអី។ ខ្ញុំចាំដូចមិនមាន មិនច្បាស់លាស់ទេ ដូចជាមិនមានអីទិតៀន ស្វ័យទិតៀនអីទេ។

**ស៖** ខ្ញុំសួរកៀកបន្តិច។ នៅក្នុងស្ថានភាពដែលលោកបានចូលលើកដំបូងនោះ តើលោកបានជួយអីខ្លះទៅដល់បដិវត្តន៍?

**ឆ៖** ដំបូងនោះដូចជា គ្មានបានជួយអីទេ។ ដំបូងនោះគ្មានទេ។

**ស៖** លោកអាចរៀបរាប់បានទេ តើឆ្នាំណាដែលលោកអាចជួយជាលុយ ជាកាក់ទៅដល់ចលនាបដិវត្តន៍ហ្នឹង?

**ឆ៖** បន្តមកទៀតមកគឺថា នៅរវាងឆ្នាំដែល១៩៥០អីប្លាយហ្នឹង ពេលដែលខ្ញុំមានការងារធ្វើ។ ធ្វើការជា ធ្វើការនៅអាខែងការងារផ្សេងៗអីទៅ នៅរទេះភ្លើង នៅធនាគារហ្នឹងមានចូលជួយជាលុយកាក់ខ្លះ។

**ស៖** លោកចូលធ្វើការនៅធនាគារហ្នឹង នៅឆ្នាំណាដែរ?

ឆ៖ បើមិន១៩៦៣, ៦៤ ប៉ុណ្ណឹង ប្រហាក់ប្រហែលហ្នឹង។ មុនហ្នឹង ខ្ញុំធ្វើនៅរទេះភ្លើង ហើយមុនហ្នឹងទៀត ខ្ញុំធ្វើនៅជាសាស្ត្រាចារ្យពីរបីឆ្នាំដែរ។

[១៥:២៩:៣០]

សៈ លោកមានមុខងារជាអីដែរនៅធ្វើការនៅធនាគារហ្នឹង?

ឆ៖ នៅធនាគារហ្នឹង ដំបូងឡើងបន្ទាប់ពីបានហ្វឹកហ្វឺនប្រាំប្រាំមួយខែ ខ្ញុំត្រូវបានតែងតាំងធ្វើជាប្រធានសាខានៅក្រុងព្រះសីហនុ។ ក្រោយមកគេបញ្ជូនឲ្យទៅហ្វឹកហ្វឺននៅប្រទេសបារាំង ពីរបីខែនៅធនាគារបារាំងមួយ ហើយត្រឡប់មកវិញក៏ធ្វើជាប្រធានផ្នែកឥណទាន គឺថាឲ្យគេខ្ចីលុយខ្ចីកាក់ហ្នឹងខាងផ្នែកខ្ចីលុយខ្ចីកាក់ រហូត។

សៈ ក្នុងពេលដែលលោកបានឡើងកាន់ជាប្រធានផ្នែកខ្ចីលុយខ្ចីកាក់ តើអ្នកណាទទួលខុសត្រូវពីលើលោក ពេលនុ៎ង?

ឆ៖ ពីលើគឺមានលោក ចៅ សៅ គាត់មកពីខាងធនាគារជាតិនៃកម្ពុជា។

សៈ នៅពេលក្នុងនាមលោកជាប្រធានផ្នែកខ្ចីប្រាក់ តើលោកមានសិទ្ធិចាត់ចែងប្រគល់ប្រាក់នេះទៅឲ្យបុគ្គលណាផ្សេងទៀតទេ?

[១៥:៣១:២៤]

ឆ៖ ក្នុងកិច្ចការនេះគឺថា ខាងផ្នែកខាងខ្ញុំនេះគ្រាន់ថា សិក្សាឯកសារដែលភ្ញៀវគេស្នើអីចឹងយើងសិក្សាឯកសារទៅ ហើយបញ្ជូនទៅអគ្គនាយក ហើយនិងប្រធាន ចៅ សៅ ហ្នឹង គាត់សម្រេចជាចុងក្រោយ។ ខ្ញុំមិនមានសិទ្ធិសម្រេចថា ផ្តល់ឲ្យអ្នកនោះបានទេ គ្រាន់តែសិក្សាហើយស្នើទៅថ្នាក់លើ។

សៈ ខ្ញុំសូមសួរលោកបន្តិចទៀតទាក់ទងនឹងអង្គហេតុនេះ ដោយសារលោកជាអ្នកធ្លាប់ផ្តល់លុយឲ្យក្រុមចលនាខ្មែរក្រហម ហើយលោកបានមកកាន់តួនាទីជាអ្នកមានឥទ្ធិពលម្នាក់នៅក្នុងការប្រគល់លុយឲ្យៗទៅបុគ្គលណាដែលៗផ្សេងៗ ទាក់ទងជាមួយនឹងប្រព័ន្ធនៃការសម្រួលទៅដល់ការសម្ងាត់នោះ។ តើមានបុគ្គលដែលលោកស្គាល់នៅក្នុងជួរខ្មែរក្រហមនេះមកខ្ចីលុយហ្នឹងទេ ហើយលោកគិតយ៉ាងម៉េច លោកសម្រួលឲ្យគាត់ដែរពេលហ្នឹង?

ឆ៖ ឥតមានទេបាទ។

សៈ អរគុណលោក។

**ប្រធានអង្គជំនុំ៖**

លោកតំណាងសហព្រះរាជអាជ្ញាជាតិ គួរពិចារណាឡើងវិញអំពីការតាំងសំណួរ ដែលពាក់ព័ន្ធជិតស្និទ្ធទៅនឹងអង្គហេតុទាំងឡាយដែលបង្ហាញនៅក្នុងដីកាដំណោះស្រាយ ដែលអង្គជំនុំជម្រះបានកំណត់យកមកធ្វើសវនាការនៅក្នុងសំណុំរឿង០០២/០១។ ចៀសវាងការសួរដេញដោលនូវបញ្ហាទាំងឡាយដែលវាឆ្ងាយពេកធៀបជាមួយនឹងអង្គហេតុ ដែលត្រូវបានចោទប្រកាន់ ហើយអង្គជំនុំជម្រះកំណត់យកមកសួរដេញដោលនៅក្នុងកិច្ចដំណើរការសវនាការនេះ។

[១៥:៣៣:២៦]

កិច្ចដំណើរការនេះ ជាការពិតហើយក្នុងការសួរដេញដោលពាក់ព័ន្ធទៅនឹងសំណួរមួយចំនួនចំពោះប្រវត្តិសាស្ត្របក្សកុម្មុយនីស្តកម្ពុជា ដែលអាចកើតមុននៅក្នុងអំឡុងពេលយុត្តាធិការ អ.វ.ត.ក គឺមុនថ្ងៃទី១៧ ខែមេសា ឆ្នាំ៧៥ ប៉ុន្តែនោះគឺជាបញ្ហាជាក់ទាក់ទងទៅនឹងប្រវត្តិសាស្ត្រនៃបក្សកុម្មុយនីស្តកម្ពុជាប៉ុណ្ណោះ។ ក្រៅពីនេះ គឺអង្គហេតុដែលមានការពាក់ព័ន្ធខ្លាំង គឺអង្គហេតុដែលស្ថិតនៅក្នុងអំឡុងពេលនៃយុត្តាធិការនៃ អ.វ.ត.ក គឺចាប់ពីថ្ងៃ១៧ មេសា ៧៥ ដល់ ថ្ងៃទី០៦ មករា ឆ្នាំ១៩៧៩ នេះជាអង្គហេតុចម្បងដែលយកមកដោះស្រាយ។ ហើយនៅក្នុងនោះ គឺយើងបានបំបែករួចហើយ គឺអង្គហេតុដែលយើងយកមកធ្វើសវនាការនៅក្នុងដំណាក់កាលនៃដំណើរការសវនាការទីមួយនេះ គឺអង្គហេតុពាក់ព័ន្ធទៅនឹងដំណាក់កាលនៃការជម្លៀសទីមួយ ហើយនិងទីពីរប៉ុណ្ណោះ។ ហើយជាបន្តបន្ទាប់យើងបានកំណត់រួចហើយអំពីវិសាលភាពលម្អិតនៃវគ្គកិច្ចដំណើរការពិភាក្សាដេញដោល។ គប្បីរៀបចំនូវការតាំងសំណួរធ្វើយ៉ាងណាឲ្យងាយយល់ ហើយនិងចំនូវគោលដៅ នូវបញ្ហាដែលបានចោទប្រកាន់នៅក្នុងអង្គហេតុពាក់ព័ន្ធនឹងដីកាដំណោះស្រាយ ដែលចោទប្រកាន់ចំពោះជនជាប់ចោទ។

[១៥:៣៥:០០]

បើពុំដូច្នោះទេ យើងនឹងប្រឹងប្រែងគ្រប់គ្រងដំណើរការសវនាការនេះឲ្យបាន ដោយកាត់មិនឲ្យសាក្សីឆ្លើយ ដើម្បីសន្សំពេលវេលា និងការប្រើប្រាស់ពេលវេលាបែងចែកឲ្យភាគីពាក់ព័ន្ធឲ្យប្រើប្រាស់ពេលវេលាមានប្រសិទ្ធភាពខ្ពស់បំផុត។

ចុចក្បាលមីក្រូ!

**សួរដោយលោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំសួរលោកទាក់ទងទៅនឹងអង្គភាពរដ្ឋបាលវិញម្ដង។ តើលោកដែលឮថាមាន ឮពាក្យថា

"តំបន់រំដោះ" ឬទេ?

**លោក សតឹម ល្មុត៖**

**ឆ៖** បាទ ធ្លាប់ឮ បាទ។

**ស៖** ពេលនុ៎ង ចលនាខ្មែរក្រហមហ្នឹង គេមានរៀបចំជារចនាសម្ព័ន្ធរដ្ឋបាលតាមតំបន់ តាមភូមិភាគ តើលោកបានឮទេ ពេលនុ៎ង?

**ប្រធានអង្គជំនុំ៖**

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលឧបករណ៍ក្បាលមេក្រូចំពោះមុខសាក្សី ដោយដាក់ដើមវាហ្នឹងចំពីមុខគាត់ទៅ ហើយទាញឲ្យខ្ពស់ ហើយទាញបង្អុសពីមុខគាត់ ដាក់ចំហៀងទៅដើម្បីឲ្យគាត់អាចមើលឃើញនូវសញ្ញាភ្លើងនៅក្បាលមីក្រូ។

អញ្ជើញបន្ត លោកតំណាងសហព្រះរាជអាជ្ញា!

[១៥:៣៦:៥៦]

**លោក វ៉េង ហ៊ត់៖**

**ស៖** ខ្ញុំសួរលោកបន្តទៀត នៅក្នុងមធ្យោបាយទំនាក់ទំនងដែលលោកថា វាមានចលនាដែលដឹកនាំរបស់ខ្មែរក្រហមនេះ ហើយបញ្ជាទំនាក់ទំនងហ្នឹងជាសម្ងាត់។ តើលោកសម្ងាត់ហ្នឹងតាមរយៈនីរសារ ឬក៏តាមរយៈក្រៅពីនីរសារ?

**លោក សតឹម ល្មុត៖**

**ឆ៖** អ្ហឺ! សំណួរហ្នឹង ខ្ញុំពិបាកឆ្លើយបន្តិច ពីព្រោះថា មិនដឹងជាទាក់ទងចលនាទូទៅ ឬចំពោះការងារខ្ញុំដែលធ្វើនៅធនាគារនោះ។ ខ្ញុំៗ-- ចង់ឲ្យខ្ញុំឆ្លើយចំណុចណា?

**ស៖** អ្ហឺ! ខ្ញុំសូម-- សូមទោស

**ឆ៖** ខ្ញុំឃើញ វាទាក់ទងការសម្ងាត់ហ្នឹង ថាពេលខ្ញុំធ្វើការ ឬក៏ជា-- ទាក់ទងទូទៅរបស់ចលនាខ្មែរក្រហម? ខ្ញុំសូមឲ្យបញ្ជាក់ ឲ្យខ្ញុំឆ្លើយចំណុចណា?

**ស៖** ខ្ញុំសូមសួរលោកទាក់ទងនឹងចលនាខ្មែរក្រហម ដែលលោកបានចូលនោះណា កិច្ចការទាំងអស់ គឺថាជាសម្ងាត់។ អ៊ីចឹងសម្ងាត់ហ្នឹង គេ--កាលនុ៎ងគេបង្កើតជាក្រុមនីរសារមកប្រាប់លោកហើយឬនៅ?

[១៥:៣៨:២៨]

**ធ៖** កាលនោះគ្មានទេ។

**ស៖** ខ្ញុំសួរដល់តួនាទី និងមុខងាររបស់មេដឹកនាំខ្មែរក្រហមវិញម្តង។ តើលោកស្គាល់ឈ្មោះ ប៉ុល ពត, អៀង សារី, ខៀវ សំផន និងឈ្មោះសម្ងាត់របស់គាត់ទេ?

**ធ៖** ខ្ញុំស្គាល់ តែក៏មិនប៉ានអះអាងថា ពិត១០០ភាគរយដែរ ឮថា-- ព្រោះមិនដែលគេឧទ្ទេសនាមមកថា ខៀវ សំផន ហ្នឹងឈ្មោះអី? ប៉ុល ពត ឈ្មោះអី? ក៏មិនមានប្រកាសអីជាផ្លូវការណ៍ហើយ យ៉ាងទៀត ក្នុងចលនានេះ ខ្ញុំវា វាមិនមែនជាអ្នកដឹកនាំជាន់ខ្ពស់ ហើយមិនមានឋានៈជាដឹកនាំអីទេ ហើយការងារធ្វើធំ គឺខ្ញុំអត់បានដឹងទេ។ តែឮតែថាឈ្មោះលោកទាំងបីនាក់ហ្នឹង វាឈ្មោះអ៊ីចឹង តែដល់យើងក្រោយមក ក៏លោកអន្តរជាតិ ក៏គេថាអ៊ីចឹងឈ្មោះហ្នឹង។ ហើយឲ្យខ្ញុំបញ្ជាក់ថា ច្បាស់តែម្តងខ្ញុំមិនប៉ានបញ្ជាក់ទេ។

**ស៖** លោកឮឈ្មោះហ្នឹងតាមរយៈស្អីពិតប្រាកដ ដែលលោកអាចដឹងបាននោះ?

**ធ៖** មិនមានស្អីពិតប្រាកដទេ។

**ស៖** តើមេដឹកនាំដែលមានឈ្មោះ ប៉ុល ពត, អៀង សារី, នួន ជា, ខៀវ សំផន នេះ នៅពេលដែលប្រជុំនៅឆ្នាំ-- មុនឆ្នាំ១៩៧៥នោះ លោកដែលបានចូលរួមជាមួយគាត់ទេ?

**ធ៖** អត់ដែលបានទេបាទ។

[១៥:៤០:៥២]

**ស៖** អរគុណលោក។ ខ្ញុំសួរទាក់ទងជាមួយនឹងការងាររដ្ឋបាល និងភស្តុភារនៅមុនឆ្នាំ១៩៧៥ម្តង។ តើលោកដែលឮពាក្យថា "មន្ទីរ" ទេ នៅក្នុងសម័យមុនឆ្នាំ១៩៧៥?

**ធ៖** ខ្ញុំៗមិនដែលឮទេបាទ។

**ស៖** តើលោកដែលឮពាក្យ "លេខសម្ងាត់ចំនួនបីខ្ទង់" ដែលគេប្រើថា៨៧០ លោកដែលឮទេពាក្យហ្នឹង? ៨៧០។

**ធ៖** ខ្ញុំមិនដែលឮទេបាទ។

**ស៖** ចុះមន្ទីរ៧១ លោកដឹងទេ?

**ធ៖** ខ្ញុំក៏អត់ដឹងដែរ។

[១៥:៤១:៥៣]

**ស៖** អរគុណលោក។ ខ្ញុំសួរលោកពីគោលនយោបាយទូទៅរបស់កម្ពុជាប្រជាធិបតេយ្យនៅមុន

ឆ្នាំ១៩៧៥ ដដែល។ តើលោកដែលឮពាក្យថា "ផ្តាច់ការបដិវត្តន៍" ទេ?

**ឆ៖** បាទ មិនដែលឮទេបាទ។

**ស៖** ចុះពាក្យ "បីតោន" លោកដែលឮទេ?

**ឆ៖** "បីតោន"នេះធ្លាប់ឮ។ ឮគឺក្នុងសម័យដែលខ្មែរក្រហមកាន់អំណាចហ្នឹង ធ្លាប់ឮថា "បីតោន"ៗ ហ្នឹងធ្លាប់ឮ។

**ស៖** ក្នុងហ្នឹងលោកអាចពន្យល់ទេថា គេចង់សំដៅលើអីដែរ "បីតោន" ហ្នឹង?

**ឆ៖** "បីតោន" ហ្នឹងបានន័យថាមួយហិចតាធ្វើស្រូវឱ្យបានបីតោន។

**ស៖** អរគុណលោក។ តើលោកស្គាល់ឈ្មោះ វ៉ាន់ រិទ្ធ ទេ មុនឆ្នាំ១៩៧៥? វ៉ាន់ រិទ្ធ។

[១៥:៤៣:៤២]

**ឆ៖** ស្គាល់បាទ។

**ស៖** វ៉ាន់ រិទ្ធ នេះគាត់មានសកម្មភាពយ៉ាងណាដែរជាមួយនឹងរបប លន់ នល់ នោះ? លោកអាចជួយពន្យល់បានទេ?

**ឆ៖** ក្នុងរបប លន់ នល់ គាត់ធ្វើជាបុគ្គលិកធនាគាររដ្ឋមួយជាមួយនឹងខ្ញុំដែរ។ ហើយដល់មុននឹងខ្មែរក្រហមចូលភ្នំពេញ គាត់ចេញៗទៅ-- គេហៅថាចេញទៅព្រៃ ចេញទៅកន្លែងតំបន់ចលនាខ្មែរក្រហម ចេញទៅក្រៅ វ៉ាន់ រិទ្ធ។

**ស៖** ហេតុអ្វីបានគាត់-- លោកដឹងមូលហេតុ ហេតុអ្វីបាន វ៉ាន់ រិទ្ធ គាត់ចេញទៅក្រៅទេ?

**ឆ៖** រឿងនេះពេលនោះ ខ្ញុំមិនដឹងថាហេតុអ្វីទេ ប៉ុន្តែក្រោយមកដឹងថា ពេលនុំងខាងរបប លន់ នល់ ហ្នឹងរកចាប់គាត់។ គាត់ក៏គៀសខ្លួនចេញទៅ។ ហើយពេលដែលចេញទៅហ្នឹង ខ្ញុំមិនដឹងមូលហេតុអីទេ ដឹងតែបាត់ទៅតែម្តង។

**ស៖** ខ្ញុំសួរគោលនយោបាយទូទៅដដែល។ តើសត្រូវរបស់បដិវត្តន៍គេសំដៅទៅលោក លន់ នល់ ឬក៏សំដៅទៅលើទាហាន លន់ នល់ ទាំងអស់?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ច្បាស់បានទេ ព្រោះគេនិយាយថា លន់ នល់ៗ អីចឹង មើលទៅទាំងទាហាន ទាំង លន់ នល់។ មិនដឹងជាសំដៅទៅលើបុគ្គលហ្នឹងថា ពេលខ្លះគេនិយាយទាហាន លន់ នល់ ជួនការគេនិយាយ លន់ នល់ អីចឹងទៅ។

[១៥:៤៦:០៥]

**ស៖** លន់ នល់ ហ្នឹងប្រឆាំងជាមួយខ្មែរក្រហមអ៊ីចឹងមែនទេ? ឬក៏យ៉ាងម៉េច លោកពេល ស្ថានភាពជាក់ស្តែងដែលលោកបានដឹង?

**ឆ៖** អានេះ ខ្ញុំពិបាកឆ្លើយបន្តិច ប៉ុន្តែតាមហេតុផលគាត់ប្រឆាំងហើយ ព្រោះខ្មែរក្រហមច្បាំងជាមួយគាត់ គាត់ប្រឆាំងហើយ អានេះតាមហេតុផល ខ្ញុំ។ ត្រង់ចិត្តគំនិតគាត់យ៉ាងម៉េច ខ្ញុំក៏មិនអាចសន្និដ្ឋានបានដែរ។

**ស៖** ពាក្យថា ប្រឆាំងអ៊ីចឹងនៅក្នុងរបបខ្មែរក្រហមគេថា "សត្រូវរបស់បដិវត្តន៍" តើពាក្យហ្នឹងមែនទេ?

**ឆ៖** រួចចុះបើ ប្រឆាំងហ្នឹង មិនបដិវត្តន៍ ក៏ប្រើពាក្យហ្នឹងដែរ ប្រឆាំងហ្នឹង តែដូច-- ចំពោះតែបដិវត្តន៍យ៉ាងម៉េច ខ្ញុំមិនអាចយល់និយមន័យហ្នឹង។ ហើយបើក្នុងរបបមកក្រោយមក គឺថាពេលដែលខ្មែរក្រហមកាន់កាប់គឺថា អ្នកដែលប្រឆាំងហ្នឹង គឺគេសំដៅអ្នកប្រឆាំងបដិវត្តន៍ហ្នឹងហើយ។ អាណាក៏ដោយឲ្យតែ-- មិនថា លន់ នល់ មិន លន់ នល់ ទេ តែប្រឆាំង ប្រឆាំងបដិវត្តន៍ហើយ។

[១៥:៤៧:៤០]

**ស៖** ខ្ញុំសួរលោកម្តងទៀតទេ មិនថា លន់ នល់ ឬក៏អ្នកណាក៏ដោយ តើពេលនុ៎ង គេសំដៅទៅលើទាំងទាហាន លន់ នល់ ទាំងអស់ ឬក៏យ៉ាងម៉េច? លោកអាចពន្យល់បានទេ?

**ឆ៖** ខ្ញុំមិនអាចពន្យល់បានទេ។

**ស៖** អរគុណលោក។ ចុះ "អំណាចជិះជាន់" វិញ តើលោកដែលឮទេ ពាក្យហ្នឹង?

**ឆ៖** ធ្លាប់ឮ។

**ស៖** នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ "អំណាចជិះជាន់" ហ្នឹងគេទៅ-- សំដៅទៅលើអំណាចដូចម្តេចដែរលោក?

[១៥:៤៩:០១]

**ឆ៖** គេសំដៅទៅលើរបបមុនថា ដូចថា ជិះជាន់ប្រជាជនក្រីក្រអីអ៊ីចឹង។

**ស៖** សំដៅទៅលើរបបមុនហ្នឹង គឺសំដៅលើមន្ត្រីរាជការ ឬក៏មន្ត្រីរាជការនៅក្នុងរបប លន់ នល់ ទាំងអស់ ឬមួយក៏យ៉ាងម៉េចដែរលោកពន្យល់ផង?

**ឆ៖** ខ្ញុំមិនអាចពន្យល់បានថា តើវារបប លន់ នល់ មន្ត្រីទាំងអស់។ ខ្ញុំមិនអាចពន្យល់បានទេ ពីព្រោះអ្នកដែលគេគ្រប់គ្រងហ្នឹង គឺមានទស្សនៈនយោបាយផ្សេង។ ខ្ញុំនៅតែខាងក្រោមនេះ ខ្ញុំមិនដឹងជា

អ្នកដឹកនាំហ្នឹង គេមានទស្សនៈ មានអីយ៉ាងម៉េច ខ្ញុំមិនអាចពន្យល់បានទេ បាទ។

**ស៖** បាទ ទាក់ទងនឹងគោលនយោបាយទូទៅនេះដដែល ខ្ញុំសួរសំណួរមួយទៀត។ លោកដែលឮពាក្យថា "ពួកអាក្បត់" ទេ?

**ឆ៖** ធ្លាប់ឮបាទ។

**ស៖** តើពួកអាក្បត់នេះ គេសំដៅទៅលើបុគ្គលណាជាក់លាក់ទេ សូមលោកជួយប្រាប់ផង?

**ឆ៖** ខ្ញុំមិនអាចបញ្ជាក់ជូនបានទេ បាទ។

**ស៖** លោកមានប្រសាសន៍អម្បាញ់មិញថា លោកធ្លាប់ឮ គេនិយាយថា ពួកអាក្បត់។ តើឮតាមមធ្យោបាយអី លោកអាចប្រាប់ផងបានទេ?

**ឆ៖** ខ្ញុំមិនចាំច្បាស់ទេបាទ ពីព្រោះរឿងហ្នឹង វាសាមសិបឆ្នាំជាងមកហើយ។ ខ្ញុំមិនចាំថានរណានិយាយ អ្នកណា បុគ្គលណានិយាយ មិន-- ខ្ញុំធ្លាប់តែឮទេ។

**ស៖** ខ្ញុំសួរទាក់ទងនឹងគោលនយោបាយទូទៅដដែល តើលោកដែលឮពាក្យថា "ក្នុងជួរ និងក្រៅជួរ" ឬទេ?

[១៥:៥២:០៤]

**ឆ៖** ពាក្យនេះ ខ្ញុំមិនដែលឮទេបាទ។

**ស៖** អរគុណលោក។ ខ្ញុំទាក់ទងទៅផ្នែកមួយទៀត គឺគោលនយោបាយអប់រំស្ដីពីទស្សនៈបក្ស។ នៅពេលដែលលោកចូលនៅក្នុងបក្សកុម្មុយនីស្តកម្ពុជា តើគេបង្រៀនមនោគមន៍វិជ្ជាអ្វីខ្លះ ដល់លោក?

**ឆ៖** គឺគេបង្រៀនមនោគមន៍វិជ្ជាម៉ាក្ស-លេនីន។

**ស៖** គេមានប្រគល់ជាសៀវភៅ ឬមួយក៏ជាអ្វីដែរ? ឬក៏គ្រាន់តែនិយាយដើម្បីឲ្យលោកស្ដាប់ទេ?

**ឆ៖** គេគ្រាន់តែនិយាយឲ្យស្ដាប់ទេ មិនដែលបានឲ្យឯកសារអី យកមកមើលអីទេ បាទ។

**ស៖** ពេលនោះ មេដឹកនាំដែលទៅពន្យល់ប្រាប់លោកនោះ គាត់ឈ្មោះអីដែរ លោកចាំទេ?

**ឆ៖** ខ្ញុំមិនចាំទេបាទ។

**ស៖** អរគុណលោក។ ទាក់ទងនឹងការអប់រំនេះ តើលោកដែលបានឮពីសៀវភៅទង់បដិវត្ត ឬក៏ទស្សនាវដ្ដីយុវជនបដិវត្តន៍ឬទេ?

[១៥:៥៤:១២]

**ផ៖** ខ្ញុំមិនដែលឮទេ បាទ។

**ស៖** អរគុណ។ ខ្ញុំសូមសួរលោកមួយទៀត ទាក់ទងជាមួយនឹងគោលការណ៍នៃសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ។ លោកដែលដឹងពាក្យថា "លុបបំបាត់កម្មសិទ្ធិឯកជន" ទេ នៅក្នុងសម័យនៅខ្ញុំសួរមុន ៧៥នេះ តើគេមានបង្រៀនអំពីកម្មសិទ្ធិឯកជន ស្តីពីគោលបំណងនៃការលុបបំបាត់ហ្នឹង លោកដែរឮទេ?

**ផ៖** អត់ដែលឮទេ បាទ។

**ស៖** ចុះពាក្យមួយទៀត ពាក្យ "មិនបំផុសកម្មសិទ្ធិឯកជន" តើលោកដែរឮទេ?

**ផ៖** ពីមុន៧៥ មិនដែលឮពាក្យហ្នឹងទេ ដល់ក្រោយមកធ្លាប់ឮ បំផុសទៅជាឯកជនហ្នឹង។

**ស៖** តើលោកអាចពន្យល់បានទេថា ទ្រព្យសម្បត្តិសួនតួនោះគេសំដៅលើដូចជា មាស ប្រាក់ គោក្របី កង់ វិទ្យុ អីអ៊ីចឹង ឬមួយក៏យ៉ាងម៉េច? សូមលោកពន្យល់ផង។

[១៥:៥៦:០៧]

**ផ៖** បាទគឺរបស់សួនតួនោះគឺ របស់ដូចលោកបានរៀបរាប់អម្បាញ់មិញហ្នឹង អាហ្នឹងគេហៅរបស់សួនតួហើយហ្នឹង។

**ស៖** ទាក់ទងនឹងសិទ្ធិរបស់ពលរដ្ឋនេះដដែល ខ្ញុំសួរលោកបន្តទៀត តើអង្គការមានណែនាំឲ្យយកទ្រព្យសម្បត្តិដាក់រួម ឬក៏ប្រគល់ឲ្យអង្គការទេ?

**ផ៖** មិនបានណែនាំ ប៉ុន្តែជាក់ស្តែងឃើញថាៗ យកមដាក់រួម ដូចនៅនឹងសហករណ៍អីអ៊ីចឹង ឃើញយកដាក់រួម។ កសិករដែលគាត់មានគោអីហ្នឹង ក៏យកមកដាក់រួមប៉ុណ្ណឹង ឃើញជាក់ស្តែងអ៊ីចឹង។

**ស៖** ការចូលបដិវត្តន៍ដំបូង បដិវត្តន៍មានណែនាំថា យើងត្រូវតែស្មោះត្រង់ សូម្បីតែម្ទេសមួយផ្លែក៏ត្រូវសុំប្រជាជនដែរ។ តើលោកដែលឮពាក្យហ្នឹងទេ?

**ផ៖** ពេលដំបូងមិនដែលឮទេ ពីព្រោះថា ពួកខ្ញុំនេះសុទ្ធតែ ច្រើនតែជាបញ្ញាជន។ ដូច្នេះគេមិនដែលអប់រំពីរឿងម្ទេស ពីរឿងអី ប្រហែលគេអប់រំនៅមជ្ឈដ្ឋានប្រជាជនទូទៅមិនដឹង ថាកុំឲ្យលួចម្ទេស លួចអីហ្នឹងអីអ៊ីចឹង ប៉ុន្តែខ្ញុំនៅខាងបញ្ញាជននេះ ផ្នែកបញ្ញាជនមិនមានការអប់រំអ៊ីចឹងទេ។

**ស៖** បាទ តើលោកធ្លាប់ឮ "កងកុមារ" ទេ?

**ផ៖** នៅសម័យខ្មែរក្រហមកាន់កាប់ ធ្លាប់ឮ ហើយក៏ឃើញទៀត មានកងកុមារហ្នឹង។

**ស៖** កងកុមារហ្នឹង គេសំដៅយកកុមារតូចៗហ្នឹង យកទៅធ្វើអីដែរលោក?

[១៥:៥៩:០២]

**ឆ៖** អានេះខ្ញុំនិយាយបានតែក្នុងក្របខ័ណ្ឌសហករណ៍ ដែលខ្ញុំរស់នៅទេ។ កងកុមារហ្នឹង គ្រាន់តែគេយកដាក់កុមារនៅម្តុំអ៊ីចឹងទៅ ហើយធ្វើការអីពិសេសៗនៅក្នុងសហករណ៍ទេ ហើយអត់ឃើញមានទៅណាមកណាទេ។ ត្រង់កន្លែងផ្សេងទៀតខ្ញុំមិនដឹងទេ។

**ស៖** ខ្ញុំសួរបញ្ជាក់លោកមួយសាទៀត កងកុមារហ្នឹងគឺគេសំដៅយកកុមារហ្នឹង ឲ្យទៅធ្វើពលកម្ម តើមានន័យអ៊ីចឹងមែនទេលោក?

**ឆ៖** បាទ មានន័យអ៊ីចឹង ប៉ុន្តែទាំងអស់គ្នាធ្វើពលកម្មទាំងអស់គ្នា ខ្ញុំអីវាចាស់មែនក៏ធ្វើពលកម្ម។ គ្រាន់តែថា កុមារហ្នឹងគេប្រមូលផ្តុំមកនៅម្តុំអ៊ីចឹងទៅនៅសហករណ៍ហ្នឹង ឲ្យដូចបែកពីម្តាយឪពុកអ៊ីចឹងទៅ។ ហើយកុមារតូចៗយប់ឡើងឲ្យមកដេកនៅជាមួយឪពុកម្តាយអ៊ីចឹងទៅ។ ពេលនោះនរណាក៏ពលកម្មដែរ។

**ស៖** បាទ អរគុណលោក។ ខ្ញុំសួរមួយទៀត អំពីកងទ័ពដែលទាក់ទងជាមួយនឹងសិទ្ធិជាមូលដ្ឋានរបស់ពលរដ្ឋ។ តើលោកដែលឮថា កងទ័ពរងរបួសដែរទេ?

**ឆ៖** ចំពោះរឿងកងទ័ពនេះ ខ្ញុំមិនការមានពាក់ព័ន្ធអីទេ គឺថា ដូច្នេះខ្ញុំមិនដែលឮថា រងរបួស តែខ្ញុំជឿ តែទៅច្បាំង គឺថាមានរបួសហើយ។ ប៉ុន្តែក៏មិនមានការអី និយាយអី រាយការណ៍អី ខ្ញុំដឹងច្បាស់លាស់ខ្ញុំមិនមានទេ។

[១៦:០១:០១]

**ស៖** នៅពេលដែលគេរៀបអាពាហ៍ពិពាហ៍ជាមួយកងទ័ព នារីដែលរៀបអាពាហ៍ពិពាហ៍ជាមួយកងទ័ពហ្នឹង តើអង្គការជាអ្នករៀបឲ្យ ឬក៏យ៉ាងម៉េច លោកអាចដឹងទេ ពេលហ្នឹង?

**ឆ៖** *(ឮមិនច្បាស់)*

**ស៖** លោកឆ្លើយមួយសាទៀត។

**ឆ៖** បាទ ខ្ញុំអត់ដឹងទេបាទ។

**ស៖** បាទ។ ចុះចំណែកការរៀបអាពាហ៍ពិពាហ៍នៅក្នុងរបបខ្មែរក្រហមនេះ តើលោកបានដឹងស្ថានភាពយ៉ាងម៉េចដែរទេ?

**ឆ៖** បាទ ក្រៅពីក្នុងរង្វង់សហករណ៍តូចដែលខ្ញុំរស់នៅហ្នឹង ខាងក្រៅខ្ញុំមិនដឹងជាគេរៀបចំរបៀបម៉េច ខ្ញុំមិនដឹងទេបាទ។

**ស៖** អរគុណលោក។ ឥឡូវនេះ ខ្ញុំឈានមកសំណួរទាក់ទងជាមួយនឹងសាសនាវិញម្ដង។ តើលោកដែលឮពាក្យថា សាសនា--

**ប្រធានអង្គជំនុំ៖**

បានហើយឥឡូវ-- លោកតំណាងសហព្រះរាជអាជ្ញា!

បាទ ឥឡូវនេះកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ ឃើញថាដល់ពេលសមល្មមនឹងសម្រាកហើយ។ អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកទៅបន្តធ្វើនៅថ្ងៃស្អែក ថ្ងៃព្រហស្បតិ៍ ទី៣១ ខែឧសភា ឆ្នាំ២០១២ ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។

[១៦:០២:៣៤]

ហើយអង្គជំនុំជម្រះសូមជម្រាបជូនភាគី ហើយនិងសាធារណជនផងដែរថា សវនាការដែលធ្វើនៅថ្ងៃស្អែក អង្គជំនុំជម្រះនឹងបន្តស្ដាប់សក្ខីកម្មសាក្សី សគីម ល្មុត ដែលនឹងតាំងសំណួរដោយតំណាងសហព្រះរាជអាជ្ញា។

លោក សគីម ល្មុត ដំណើរការសវនាការពិភាក្សាដេញដោល ស្ដាប់សក្ខីកម្មរបស់លោកទើបតែជាចាប់ផ្ដើមទេ មិនទាន់ចប់នៅឡើយទេ។ ដូច្នេះសវនាការត្រូវធ្វើបន្តទៅថ្ងៃស្អែកទៀត អង្គជំនុំជម្រះសូមកោះអញ្ជើញលោកមកបន្តផ្ដល់សក្ខីកម្មនៅថ្ងៃស្អែក ដោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយដូចគ្នានេះដែរ អង្គជំនុំជម្រះសូមអញ្ជើញមេធាវីប្រឹក្សាសាក្សីចូលរួម ដើម្បីពិភាក្សា ដើម្បីប្រឹក្សាសាក្សីនៅក្នុងកិច្ចដំណើរការសវនាការស្ដាប់សក្ខីកម្មរូបនេះ-- សាក្សីរូបនេះនៅថ្ងៃស្អែកដែរ។

[១៦:០៣:២៥]

មន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងមន្ត្រីអង្គភាពគាំពារសាក្សី និងអ្នកជំនាញក្នុងការបញ្ជូនសាក្សី សគីម ល្មុត វិលត្រឡប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ និងឲ្យនាំគាត់ត្រឡប់មកកាន់ទីកន្លែងផ្ដល់សក្ខីកម្មនៅក្នុងបន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែក នៅវេលាម៉ោងប្រាំបួន។

បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំង នាំខ្លួនជនជាប់ចោទទាំងបីរូបត្រឡប់ទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញចុះ ហើយនិងឲ្យពួកគាត់ទាំងបីរូបមកកាន់បន្ទប់សវនាការនេះវិញនៅព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន។ ដោយឡែកលោក អៀង សារី ដូចពីម្សិល និងពីព្រឹកមិញអ៊ីចឹង ប្រសិនបើគាត់បង្ហាញជំហរជាក់ច្បាស់នៅក្នុងការលះបង់សិទ្ធិចូលរួមដោយផ្ទាល់នៅក្នុងកិច្ចដំណើរការសវនាការ សូមនៅបន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ ពីបន្ទប់មួយស្ថិតនៅក្រោមបន្ទប់សវនាការនេះ តាម

រយៈពាក្យសុំលះបង់សិទ្ធិចូលរួមដោយផ្ទាល់ក្នុងបន្ទប់សវនាការនេះ ជាលាយលក្ខណ៍អក្សរបានមុនពេលអង្គសវនាការចាប់ផ្ដើមដំណើរការនៅម៉ោងប្រាំបួនព្រឹកនោះ។ អង្គជំនុំជម្រះឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនគាត់មកត្រឹមតែបន្ទប់ឃុំខ្លួនមួយ ដែលនៅក្រោមបន្ទប់សវនាការនេះ ដែលរៀបចំឧបករណ៍សោតទស្សន៍សម្រាប់រូបគាត់បន្តតាមដានកិច្ចដំណើរការសវនាការពីចម្ងាយ។ សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ១៦:០៥ នាទី)*